**សាកលវិទ្យាល័យ ភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**
Université Royale de Droit et des Scienes Economiques
Royal University Of Law and Economics

## សារណាបញ្ចប់ការសិក្សា

# អភិបាលកិច្ចខណ្ឌមានជ័យ
# (ករណីសិក្សាពីឆ្នាំ ២០០៩ ដល់២០១៣)

ស្រាវជ្រាវចាប់ពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៤ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៤

ស្រាវជ្រាវដោយ
និស្សិត **កែវ ច័ន្ទរស្មី**

សាស្ត្រាចារ្យណែនាំ
**បណ្ឌិត សឿន សោភ័ណ**

ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ
ជំនាន់ទី ១៩

ឆ្នាំចូលសិក្សា ២០១០
ឆ្នាំសរសេរសារណា ២០១៤

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំឈ្មោះ **កែវ ច័ន្ទរស្មី** ជានិស្សិតថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ឆ្នាំទី៤ ជំនាន់ទី១៤ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

នាងខ្ញុំសូមគោរព និង ដឹងគុណយ៉ាងជ្រាលជ្រៅចំពោះអ្នកមានគុណទាំងពីរ មិនអាចកាត់ថ្លៃបានគឺលោក ឪពុក **កែវ សារឿន** និងអ្នកម្តាយ **នឹម ម៉ាទីន** ។ ដែលលោកទាំងពីរបានផ្តល់កំណើតកូនឲ្យមានថ្ងៃនេះ ហើយលោកទាំងពីរបានចិញ្ចឹម បីបាច់ ថ្នាក់ថ្នម ថែរក្សាកូនយ៉ាងយកចិត្តទុកដាក់ និងប្រកបដោយព្រហ្មវិហាធម៌ដ៏ថ្លៃថ្លា។ លោកទាំងពីរខ្វាយខ្វល់ពីកូន និង ផ្តល់ជាដំបូន្មាន អប់រំកូនគ្រប់ពេលដើម្បីឲ្យកូនក្លាយជាមនុស្សម្នាក់ដែលសង្គមត្រូវការមិនអាចខ្វះបាន។ ជាងនេះទៅទៀតលោកទាំងពីរបានទំនុកបំរុងកូនក្នុងការសិក្សានេះតាំងពីតូច រហូតដល់បានបញ្ចប់ថ្នាក់បរិញ្ញាបត្រដែលមិនដែលឲ្យកូនលំបាកម្តងណាទេ។

នាងខ្ញុំសូមថ្លែងអំណរគុណជាអតិបរមាចំពោះ ឯកឧត្តមសាកលវិទ្យាធិការ សាស្ត្រាចារ្យ និងបុគ្គលិកទាំងអស់ក្នុងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានចំណាយពេលវេលា និងលះបង់គ្រប់កម្លាំងកាយ និងកម្លាំងចិត្តក្នុងការជួយសម្រួល និងបង្ហាត់បង្រៀននាងខ្ញុំរហូតដល់មានដើមទុនមកថ្ងៃនេះ។

នាងខ្ញុំសូមថ្លែងអំណរគុណចំពោះលោកសាស្ត្រាចារ្យបណ្ឌិត **សឿន សោភ័ណ** យ៉ាងជ្រាលជ្រៅបំផុត ដែលលោកជាសាស្ត្រាចារ្យណែនាំ ក្នុងការសរសេរសារណារបស់នាងខ្ញុំ លោកបានដឹកនាំដោយមិនខ្លាចនឿយហត់ និងយកចិត្តទុកដាក់ចំពោះសារណានេះជាទីបំផុតដោយមិនខ្លាចនឿយហត់ដោយលោកបានលះបង់កម្លាំងកាយចិត្តក្នុងការផ្តល់ជាយោបល់ គោលគំនិត និងយុទ្ធសាស្ត្រផ្សេងៗដល់នាងខ្ញុំតាំងពីដើមរហូតដល់ទីបញ្ចប់នៃសារណានេះ។

នាងខ្ញុំក៏សូមថ្លែងអំណរគុណជាអតិបរមាដល់លោកអភិបាលខណ្ឌមានជ័យ ទាំងអភិបាលខណ្ឌចាស់លោក **គួច ចំរើន** និងលោកអភិបាលខណ្ឌថ្មីលោក **ពេជ្រ កែវមុនី** ។ លោក **ហួត ហ៊ុយ** នាយករដ្ឋបាលខណ្ឌច្បារអំពៅ ជាអតីតនាយករងរដ្ឋបាលខណ្ឌមានជ័យ និងមន្ត្រីក្នុងសាលាខណ្ឌទាំងអស់ក្នុងការសហការយ៉ាងកក់ក្តៅ ផ្តល់ឯកសារគ្រប់បែបយ៉ាង និងការផ្តល់ជាមតិយោបល់យ៉ាងយកចិត្តទុកដាក់ក្នុងការសរសេរសារណានេះ។

ដើម្បីជាការដឹងគុណដល់ លោកឪពុក អ្នកម្តាយ ឯកឧត្តម សាស្ត្រាចារ្យ លោក លោកស្រី ដែលជាអ្នកមានគុណដល់នាងខ្ញុំ នាងខ្ញុំសូមគោរពជូនពរដល់ លោកឪពុក អ្នកម្តាយ ឯកឧត្តម សាស្ត្រាចារ្យ លោក លោកស្រី សូមប្រកបតែពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លាងឃ្លាតឡើយ។

# អារម្ភកថា

ក្រោយពីនាងខ្ញុំ បានសិក្សាថ្នាក់បរិញ្ញាបត្រអស់រយៈពេល៤ឆ្នាំ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចផ្នែកនីតិសាស្ត្រ កន្លងមកនេះ នាងខ្ញុំទទួលបាននូវចំណេះដឹងជាច្រើន ទាំងផ្នែកទ្រឹស្តី និងខាងការអនុវត្តន៍នៅក្នុងផ្នែកនេះ។ យោងទៅតាមចំណេះដឹង នៃការសិក្សាទាំងអស់នេះហើយ បានធ្វើឲ្យនាងខ្ញុំមានឱកាសបានសរសេរ នូវសារណាបញ្ចប់ការសិក្សាមួយ។ នេះគឺជាឱកាសមួយ ដែលនាងខ្ញុំគិតថាវាមានភាពវិសេសវិលាលណាស់ សំរាប់នាងខ្ញុំក្នុងការសរសេរសារណានេះ ព្រោះវាបានឲ្យនាងខ្ញុំមានឱកាសបានវាស់ស្ទង់នូវចំណេះដឹងរបស់នាងខ្ញុំផ្ទាល់ អាចប្រើប្រាស់នូវចំណេះដឹងដែល នាងខ្ញុំមានពីមុន និងធ្វើការស្រាវជ្រាវបន្ថែមទៀត។ ហេតុនេះហើយទើបធ្វើឲ្យនាងខ្ញុំបានសម្រេចចិត្តជ្រើសរើសយកប្រធានបទ "អភិបាលកិច្ចខណ្ឌមានជ័យ" មកធ្វើជាប្រធានបទក្នុងការស្រាវជាវនៃការសរសេរសារណាបញ្ចប់ការសិក្សានេះ។

កម្មវត្ថុចម្បង ដែលនាងខ្ញុំបានសម្រេចចិត្តជ្រើសរើសយកប្រធានបទនេះមកធ្វើការស្រាវជ្រាវ គឺនាងខ្ញុំបានយល់ថាប្រធានបទស្តីពីអភិបាលកិច្ចនេះ គឺមានភាពសំខាន់ណាស់ខាងផ្នែកទ្រឹស្តី ហើយវាជាគោលការណ៍មួយក្នុងការ អភិវឌ្ឍន៍វិស័យរដ្ឋបាល និងកំណែទម្រង់វិស័យផ្សេងៗ នៅកម្ពុជា និងជាយុទ្ធសាស្ត្រស្នូលរបស់រាជរដ្ឋាភិបាលផងដែរ។ ហេតុដូច្នេះហើយទើប សាលាខណ្ឌមានជ័យ ដែលធ្វើការងារក្នុងវិស័យថ្នាក់ក្រោមជាតិនេះ កំពុងតែមានសន្ទុះការអភិវឌ្ឍន៍យ៉ាងខ្លាំងក្លាខាងផ្នែករដ្ឋបាល គឺការផ្តល់ជូនសេវាបំរើជូនប្រជាពលរដ្ឋនេះបាននឹងកំពុងតែអនុវត្តន៍ការគ្រប់គ្រងរដ្ឋបាលរបស់ខ្លួនឲ្យឈានទៅរកអភិបាលកិច្ចល្អ។ គឺគោលការណ៍នៃអភិបាលកិច្ចល្អដែលរួមមានការផ្តល់សេវាសាធារណៈ ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន នីតិរដ្ឋ តម្លាភាព និងការឆ្លើយតបការទទួលខុសត្រូវនិងគណនេយ្យភាព ការចាត់ចែងល្អ និងប្រសិទ្ធភាពខ្ពស់។

ដូច្នេះហើយទើបនាងខ្ញុំសម្រេចចិត្តស្រាវជ្រាវនូវសារណាស្តីពី អភិបាលកិច្ចនៃសាលាខណ្ឌមានជ័យនេះឡើងដើម្បី ជួយពង្រឹងគោលការណ៍នៃអភិបាលកិច្ចក្នុងខណ្ឌនេះឲ្យមានប្រសិទ្ធភាពខ្ពស់ទាំងទ្រឹស្តី និងការអនុវត្តន៍។

ជាចុងបញ្ចប់នាងខ្ញុំក៏សូមអភ័យទោស ចំពោះរាល់កំហុសឆ្គងដោយអចេតនាទាំងឡាយដែលកើតមានក្នុងការសរសេរសារណានេះទាំងខ្លឹមសារ និងអក្ខរាវិរុទ្ធ។ នាងខ្ញុំសូមស្វាគមន៍នូវការរិះគន់ទាំងឡាយណាដែលក្នុងន័យស្ថាបនា និង ការផ្តល់ជាមតិយោបល់ផ្សេងៗក្នុងសារណានេះពីសំណាក់លោក លោកស្រី និងមិត្តអ្នកអានគ្រប់ពេលវេលា។

# មាតិកា

## សេចក្តីផ្តើម ទំព័រ

១. លំនាំបញ្ហានៃការស្រាវជ្រាវ........................................................................................................... ១
២. ចំណោទបញ្ហា................................................................................................................................... ២
៣.ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ ................................................................................... ២
៤. គោលបំណងនៃការស្រាវជ្រាវ.............................................................................................................. ២
៥. វិធីសាស្ត្រស្រាវជ្រាវ..............................................................................................................................៣
៦. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ...............................................................................................................៣

## ជំពូកទី១
## ទិដ្ឋភាពទូទៅនៃអភិបាលកិច្ចល្អ

១.១. និយមន័យនៃអភិបាលកិច្ច .............................................................................................. ៤
១.២. គោលបំណងនៃអភិបាលកិច្ចល្អ ........................................................................................ ៤
១.៣. តួអង្គសំខាន់នៃអភិបាលកិច្ចល្អ......................................................................................... ៥
១.៤. លក្ខណៈនៃអភិបាលកិច្ច.....................................................................................................៧
១.៥. គោលការណ៍នៃអភិបាលកិច្ចល្អ .........................................................................................៧
១.៥.១. គិតពីសេវាសាធារណៈ........................................................................................................៧
១.៥.២. ការចូលរួមរបស់ប្រជាពលរដ្ឋ ............................................................................................ ៨
១.៥.៣. នីតិរដ្ឋ ................................................................................................................................ ៨
១.៥.៤. តម្លាភាព និងការឆ្លើយតប .................................................................................................. ៩
១.៥.៥. ការទទួលខុសត្រូវ និងគណនេយ្យភាព .............................................................................១០
១.៥.៥.១. គណនេយ្យភាពក្នុងន័យវិមជ្ឈការចំពោះថ្នាក់ដឹកនាំ ..........................................១១
១.៥.៥.២. គណនេយ្យភាពក្នុងន័យវិមជ្ឈការចំពោះមុខសាធារណៈជន...............១១
១.៥.៦ .ការចាត់ចែងល្អ និងប្រសិទ្ធភាពខ្ពស់ ............................................................................ ១២
១.៥.៧. ការព្រមព្រាងឯកភាព និងសមធម៌ .................................................................................. ១២
១.៦. អភិបាលកិច្ចក្នុងក្របខណ្ឌគោលនយោបាយច្បាប់.................................................................១៣
១.៦.១. អភិបាលកិច្ចក្នុងក្របខ័ណ្ឌយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល.............១៣
១.៦.២. អភិបាលកិច្ចក្នុងក្របខ័ណ្ឌ ច្បាប់ស្តីពីការគ្រប់គ្រងឃុំ សង្កាត់ .........................១៤
១.៦.៣.អភិបាលកិច្ចក្នុងក្របខ័ណ្ឌច្បាប់ស្តីពី
ការគ្រប់គ្រងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ..................................................១៥
១.៦.៣.១. អំពីគោលការណ៍គ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ.......១៥
១.៦.៣.២..អំពីគណនេយ្យភាពរបស់ក្រុមប្រឹក្សា គណៈអភិបាល និងបុគ្គលិក .....១៧

# ជំពូកទី២
# ស្ថានភាពទូទៅរបស់ខណ្ឌមានជ័យ និង មូលដ្ឋានគតិយុត្តិ


២.១.ប្រវត្តិសង្ខេបរបស់ខណ្ឌមានជ័យ.....១៩
២.២.ស្ថានភាពទូទៅរបស់ខណ្ឌមានជ័យ..... ២១
២.៣.ទីតាំងភូមិសាស្ត្រ..... ២១
២.៤.អំពីប្រជាសាស្ត្រ..... ២១
២.៥.អំពីរចនាសម្ព័ន្ធដឹកនាំ..... ២១
២.៦.អំពីតួនាទី និងភារកិច្ច.....២៣
២.៦.១.សិទ្ធអំណាចរបស់ក្រុមប្រឹក្សាខណ្ឌ.....២៣
២.៦.២.តួនាទីរបស់គណៈអភិបាលខណ្ឌ..... ២៤
២.៦.៣.តួនាទីរបស់អភិបាលខណ្ឌ..... ២៦
២.៦.៤.ទំនាក់ទំនងរវាងក្រុមប្រឹក្សា និងគណៈអភិបាលខណ្ឌ..... ២៨
២.៦.៥.សមាសភាពនៃ គណៈកម្មាធិការបច្ចេកទេស.....៣០
២.៧.ផែនការសកម្មភាព សមិទ្ធផល និង ការពង្រឹងអភិបាលកិច្ចល្អខណ្ឌមានជ័យ.....៣០
២.៧.១.គិតពីសេវាសាធារណៈ.....៣០
២.៧.១.១.ការងារអត្រានុកូលដ្ឋាន.....៣១
២.៧.១.២.ការងារច្រកចេញចូលតែមួយ.....៣១
២.៧.១.៣.សន្តិសុខសណ្តាប់ធ្នាប់សាធារណៈ.....៣២
២.៧.១.៤.ប័ណ្ណមូលនិធិសមធម៌..... ៣៣
២.៧.១.៥.សេវាសុខាភិបាល.....៣៤
២.៧.១.៦.ការកសាងហេដ្ឋារចនាសម្ព័ន្ធក្នុងមូលដ្ឋាន.....៣៥
២.៧.២.ការចូលរួមរបស់ប្រជាពលរដ្ឋ.....៣៦
២.៧.២.១.ការចុះឈ្មោះ និងពិនិត្យបញ្ជីឈ្មោះអ្នកបោះឆ្នោត.....៣៦
២.៧.២.២.ការងាររៀបចំវេទិកាសាធារណៈ.....៣៦
២.៧.២.៣.ការចូលរួមរបស់ប្រជាពលរដ្ឋជានារីក្នុងមូលដ្ឋាន..... ៣៧
២.៧.២.៤.ការងាររៀបចំដែនដី នគរូបនីយកម្ម និងសំណង់..... ៣៧
២.៧.៣.ការពង្រឹងនីតិរដ្ឋ..... ៣៧
២.៧.៤.ការជម្រុញអោយមានតម្លាភាព និងការឆ្លើយតប.....៣៨
២.៧.៥.ការទទួលខុសត្រូវ និង គណនេយ្យភាព.....៣៩
២.៨.សមិទ្ធផលជារួមនៃសាលាខណ្ឌមានជ័យ ក្នុងអាណត្តិទីមួយ.....៤០

## ជំពូកទី៣
## ការវិភាគទៅលើការអនុវត្តអភិបាលកិច្ច នៃសាលាខណ្ឌមានជ័យ

៣.១. ការគិតគូរពីសេវាសាធារណៈ ........ ៤២
៣.១.១ ការវិភាគលើសេវាអត្រានុកូលដ្ឋាន ........ ៤២
៣.១.២.ការវិភាគលើសេវាសុខាភិបាលក្នុងមូលដ្ឋាន ........ ៤៤
៣.១.៣.ការវិភាគលើសេវាអប់រំ ........ ៤៥
៣.២.ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន ........ ៤៧
៣.៣.ការវិភាគលើការទទួលខុសត្រូវ និងគណនេយ្យភាព ........ ៤៩
៣.៤.ការវិភាគលើសមត្ថភាពរបស់មន្ត្រីក្នុងការជម្រុញអភិបាលកិច្ចល្អ ........ ៤៩

## សេចក្តីសន្និដ្ឋាន និងអនុសាសន៍

សេចក្តីសន្និដ្ឋាន ........ ៥២
អនុសាសន៍ ........ ៥៤
**ឯកសារពិគ្រោះ**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

## ១.លំនាំបញ្ហានៃការស្រាវជ្រាវ

ប្រទេសកម្ពុជាធ្លាប់បានឆ្លងកាត់នូវការ ផ្លាស់ប្តូរបបនយោបាយជាច្រើន បើគិតទៅវាប្រហែលជា៦របបរួចមកហើយចាប់តាំងពីសម័យព្រះបាទនរោត្តមសីហានុឆ្នាំ១៩៤៧។ ប៉ុន្តែក្នុងការផ្លាស់ប្តូរនៃរបបនីមួយៗនេះយើងមិនបានឃើញមានការរីកចំរើន និងប្រសិទ្ធភាពនៃការធ្វើកំណែទម្រង់នោះទេ។ ទើបតែចាប់ពីឆ្នាំ១៩៩១ មកការធ្វើកំណែទម្រង់នៃស្ថាប័នរដ្ឋក្លាយជាអាទិភាពដ៏ចម្បងបំផុតរបស់រាជរដ្ឋាភិបាលកម្ពុជាដើម្បីឲ្យស្របទៅ នឹងគោលនយោបាយប្រជាធិតេយ្យសេរី ពហុបក្ស និងឈានទៅអនុវត្តនូវរបបសេដ្ឋកិច្ចទីផ្សារឲ្យកាន់តែមានប្រសិទ្ធភាព។

រាជរដ្ឋាភិបាលបានចាត់ទុក **អភិបាលកិច្ចល្អ** គឺជាប្រធានបទមួយដែលមានសារៈសំខាន់ និងកំពុងតែមានការពិភាក្សាយ៉ាងក្តៅគគុកជុំវិញប្រធានបទនេះ។ លើសពីនេះទៅទៀត វាជាយុទ្ធសាស្ត្រមួយរបស់រាជរដ្ឋាភិបាល ដែលជាយុទ្ធសាស្ត្រស្នូលក្នុងកំណែទម្រង់រដ្ឋបាល។ ទាំងការគ្រប់គ្រងធនធានមនុស្ស ទាំងស្ថាប័ន អង្គភាព និងការផ្តល់សេវាសាធារណៈទាមទារឲ្យមានអភិបាលកិច្ចល្អជាកត្តាចាំបាច់សម្រាប់កិច្ចអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព។ ផ្ទុយទៅវិញ កិច្ចអភិវឌ្ឍន៍ធនធានមនុស្ស ស្ថាប័ន និងការផ្តល់សេវាសាធារណៈ មិនអាចដំណើរការទៅបានល្អ ប្រសិនបើការគ្រប់គ្រងមានលក្ខណៈបរិបាលកិច្ច។ នៅក្នុងសារៈសំខាន់ នៃអភិបាលកិច្ចល្អនេះដែរ រាជរដ្ឋាភិបាលបាន និងកំពុងបន្តអនុវត្តផែនការសកម្មភាពអភិបាលកិច្ចល្អ ដោយបានកំណត់ក្នុងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល និងបានបញ្ចូលគោលការណ៍នៃអភិបាលកិច្ចល្អ ក្នុងក្របខ័ណ្ឌគោលនយោបាយ និងយុទ្ធសាស្ត្រនានារបស់រាជរដ្ឋាភិបាល និងច្បាប់រៀបចំអង្គការ ដើម្បីឆ្ពោះទៅរកការអភិវឌ្ឍន៍ប្រទេសប្រកបដោយជោគជ័យ។

ទន្ទឹមនឹងគ្នានេះដែរ ដើម្បីធ្វើឲ្យវិស័យរដ្ឋបាល ក្នុងសាលាខណ្ឌមានជ័យ អាចចូលរួមចំណែកក្នុងការអភិវឌ្ឍន៍ប្រទេសជាតិឲ្យទទួលនូវចីរភាពពិតៗ វាទាមទារឲ្យសាលាខណ្ឌត្រូវមានការចូលរួមយ៉ាងសកម្មទៅលើវិស័យអភិបាលកិច្ចល្អឲ្យបានស៊ីជម្រៅបំផុត។ ដោយគោរពទៅតាមគោលការណ៍នៃអភិបាលកិច្ចល្អនោះ និងមានការសហការពីថ្នាក់សង្កាត់ដែលជាសេនាធិការផ្ទាល់របស់ខណ្ឌផងដែរ ទើបការអនុវត្តន៍នូវគោលការណ៍អភិបាលកិច្ចល្អនេះមានប្រសិទ្ធភាព។ ដោយយល់ពីសារៈសំខាន់ និងអត្ថប្រយោជន៍ជាច្រើនទាក់ទងនឹងអភិបាលកិច្ចល្អនេះទើបទាមទារឲ្យ រាជរដ្ឋាភិបាល អង្គការ ស្ថាប័ន និងសង្គមស៊ីវិល ខិតខំប្រឹងប្រែងទាំងអស់គ្នាក្នុងការជួយជម្រុញគោលការណ៍នៃអភិបាលកិច្ចល្អនេះ។

## ២.ចំណោទបញ្ហា

ចំណោទបញ្ហាដែលលើកយកមកចោទសួរក្នុងប្រធានបទខាងលើមានដូចខាងក្រោម៖

- តើដំណើរការ នៃការអនុវត្តអភិបាលកិច្ចខណ្ឌមានជ័យ ប្រព្រឹត្តទៅយ៉ាងដូចម្តេច?
- តើមានបញ្ហាប្រឈមអ្វីខ្លះ ក្នុងការអនុវត្តនៃអភិបាលកិច្ចល្អ?

## ៣.ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

ចំពោះដែនកំណត់ និងវិសាលភាពលើប្រធានបទ អភិបាលកិច្ចខណ្ឌមានជ័យនេះ គឺធ្វើការស្រាវជ្រាវ និងសិក្សាទៅលើទ្រឹស្តីជាទូទៅនៃអភិបាលកិច្ចល្អ ច្បាប់ និងលិខិតបទដ្ឋាននានា ដែលមានចែងជាធរមាន និងកំពុងអនុវត្តន៍នាពេលបច្ចុប្បន្នទាក់ទងនឹងអភិបាលកិច្ច។ ប៉ុន្តែក្នុងនោះដែរ យើងបានលើកឡើងពីគោលការណ៍ទូទៅនៃអភិបាលកិច្ចជាច្រើន ប៉ុន្តែយើងបានលើកយកតែគោលការណ៍ចំនួនបួនតែប៉ុណ្ណោះមកធ្វើការវិភាគ លើប្រធានបទនេះគឺ ការគិតគូពីសេវាសាធារណៈ ការចូលរួមរបស់ប្រជាពលរដ្ឋ តម្លាភាព ការទទួលខុសត្រូវ និងគណនេយ្យភាព។ ម្យ៉ាងវិញទៀត យើងបានផ្តោតសំខាន់ទៅលើអភិបាលកិច្ចល្អ នៃសាលាខណ្ឌមានជ័យ ដែលបង្ហាញពីផែនការសកម្មភាពផ្សេងៗ និងទិសដៅអភិបាលកិច្ចល្អរបស់ សាលាខណ្ឌមានជ័យ។ ការស្រាវជ្រាវនេះផ្តោតសំខាន់តែទៅលើសកម្មភាពអភិបាលកិច្ច នៃសាលាខណ្ឌមានជ័យ ក្នុងអាណត្តិទីមួយតែប៉ុណ្ណោះ ពីឆ្នាំ២០០៩ ដល់ឆ្នាំ២០១៣។

## ៤.គោលបំណងនៃការស្រាវជ្រាវ

គោលបំណងដ៏សំខាន់ នៃការចងក្រងរបាយការណ៍ស្រាវជ្រាវនេះឡើង គឺដើម្បីជួយជម្រុញអភិបាលកិច្ចល្អ ក្នុងវិស័យរដ្ឋបាលនៅក្នុងសាលាខណ្ឌមានជ័យ ដែលមានភារកិច្ចយ៉ាងសំខាន់ក្នុងការផ្តល់សេវាសាធារណៈជូនទៅប្រជាពលរដ្ឋ។ ធ្វើយ៉ាងណាឲ្យសេវាសាធារណៈនេះកាន់តែរំកិលខិតជិតប្រជាពលរដ្ឋ និងការបង្កើនប្រសិទ្ធភាពការងារឲ្យកាន់តែមានប្រសិទ្ធភាព ការទទួលខុសត្រូវ តម្លាភាព លើការងារដឹកនាំ និងគ្រប់គ្រងដើម្បីឲ្យឈានទៅរកការសម្រេចផែនការនានានៅពេលបច្ចុប្បន្ន និងពេលអនាគត ដែលគោលបំណងនៃការវិភាគលើប្រធានបទខាងលើនេះរួមមាន៖

- ការវិភាគទៅលើសមិទ្ធផលនានា ដែលសម្រេចបានក្នុងខណ្ឌមានជ័យ ជាពិសេសទាក់ទងទៅនឹងការអនុវត្តលើគោលការណ៍អភិបាលកិច្ចល្អ តាមរយៈសេវាសាធារណៈ ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន ការទទួលខុសត្រូវ និងគណនេយ្យភាព វិភាគលើសមត្ថភាពមន្ត្រី
- វិភាគលើ បញ្ហាប្រឈមមួយចំនួន ដែលកើតមានឡើង ក្នុងដំណើរការអភិវឌ្ឍន៍អភិបាលកិច្ចល្អ

- លើកឡើងជាអនុសាសន៍ ដែលជាសំណូមពរមួយសម្រាប់ជាទស្សនៈវិស័យ ដើម្បីរួមចំណែកក្នុងដំណើរការអនុវត្តអភិបាលកិច្ចល្អក្នុងខណ្ឌមានជ័យដើម្បីឲ្យមានភាពប្រសើរ។

## ៥.វិធីសាស្ត្រស្រាវជ្រាវ

ក្នុងការស្រាវជ្រាវនេះមានភាពប្រសើរឡើងនេះ ទាមទាឲ្យមានការរិះរកគ្រប់មធ្យោបាយដើម្បីប្រមូលនូវទិន្នន័យចាំបាច់សំខាន់ៗ និងព័ត៌មានជុំវិញបញ្ហាពាក់ព័ន្ធ ដើម្បីឲ្យទិន្នន័យទាំងនេះកាន់តែល្អិនល្អន់ និងច្បាស់លាស់ គឺចាំបាច់ត្រូវប្រើប្រាស់នូវប្រភពទិន្នន័យសំខាន់ៗចំនួនពីរគឺ៖

**ទិន្នន័យចម្បង** (Primary Data)

ប្រភពនៃទិន្នន័យចម្បងនេះត្រូវបានរៀបចំ និងបង្កើតឡើងក្រោមរូបភាពនៃការសាកសួរព័ត៌មានផ្ទាល់តាមរយៈការសាកសួរព័ត៌មានពីសំណាក់ថ្នាក់ដឹកនាំនៃស្ថាប័នពាក់ព័ន្ធ ដែលកំពុងតែនឹងបំពេញការងាររបស់ខ្លួន និងការសាកសួរទៅកាន់ប្រជាពលរដ្ឋដោយផ្ទាល់។

**ទិន្នន័យបន្ទាប់បន្សំ** (Secondary Data )

ចំណែកទិន្នន័យបន្ទាប់បន្សំនេះវិញ គឺត្រូវបានរៀបចំឡើងក្រោមការប្រមូលផ្តុំនូវរាល់ឯកសារពាក់ព័ន្ធមួយចំនួនដែលមានជាធរមាន។

## ៦.រចនាសម្ព័ន្ធនៃការសិក្សាស្រាវជ្រាវ

ដើម្បីឲ្យការសិក្សាស្រាវជ្រាវនេះទទួលបាននូវលទ្ធផលល្អ ប្រកបដោយប្រសិទ្ធភាពខ្ពស់នោះ គឺទាមទារឲ្យមានការកំណត់ជារចនាសម្ព័ន្ធដ៏ជាក់លាក់មួយ ដើម្បីឲ្យមានភាពងាយស្រួលក្នុងការសិក្សាស្រាវជ្រាវ។ របាយការណ៍ស្រាវជ្រាវនេះរួមមាន **បី ជំពូក** សំខាន់ៗគឺ៖

**សេចក្តីផ្តើម**

**ជំពូកទី១** ៖ ទិដ្ឋភាពទូទៅនៃអភិបាលកិច្ចល្អ

**ជំពូកទី២** ៖ ស្ថានភាពទូទៅរបស់សាលាខណ្ឌមានជ័យ និងមូលដ្ឋានច្បាប់

**ជំពូកទី៣** ៖ ការវិភាគលើការអនុវត្តអភិបាលកិច្ចនៃសាលាខណ្ឌមានជ័យ

**សេចក្តីសន្និដ្ឋាន**

**អនុសាសន៍**

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# ជំពូកទី១
# ទិដ្ឋភាពទូទៅនៃអភិបាលកិច្ចល្អ

## ១.១.និយមន័យនៃអភិបាលកិច្ច

**អភិបាលកិច្ច** ជាពាក្យផ្សំបង្កើតមកពីពាក្យបាលី គឺ **អភិបាល + កិច្ច** មានន័យថា

- **អភិបាល** ៖គឺជាអ្នកគ្រប់គ្រង អ្នកបីបាច់ថែរក្សា។[1]
- **កិច្ច** ៖មានន័យថា ការដែលត្រូវធ្វើ អំពើ ការរវល់។ [2]

ជារួម **អភិបាលកិច្ច** គឺជារបៀបរបបនៃការគ្រប់គ្រង ឬចាត់ចែង ឬការដឹកនាំចាត់ចែងឲ្យមានសណ្ដាប់ធ្នាប់ល្អ ដោយឈរលើគោលការណ៍ច្បាប់ក្នុងការអនុវត្តន៍។ ប៉ុន្តែពាក្យថា អភិបាលកិច្ចនេះមានន័យទូលំទូលាយណាស់ គឺវាអាស្រ័យទៅលើស្ថានភាពអនុវត្តន៍ និងដោះស្រាយទៅតាមទស្សនៈវិស័យការងារផ្សេងៗពីគ្នា។ នៅពេលបច្ចុប្បន្ននេះគេតែងប្រើពាក្យ អភិបាល និងកិច្ចនេះសម្រាប់ពិពណ៌នានូវផែនការសកម្មភាពអ្នកដឹកនាំ និងអ្នកចាត់ចែងនៃអង្គភាពណាមួយ។

អភិបាលកិច្ច ត្រូវបានគេឲ្យនិយមន័យផ្សេងៗពីគ្នា អាស្រ័យស្ថានភាពជាក់ស្តែង។ ជាសាមញ្ញអភិបាលកិច្ចមានអត្ថន័យថា ៖

- អភិបាលកិច្ច គឺជាវិធីសាស្ត្រ ដែលរដ្ឋ ស្ថាប័ន អង្គភាព ប្រើប្រាស់ក្នុងការគ្រប់គ្រងសេដ្ឋកិច្ច សង្គមកិច្ច និងសន្តិសុខ ដើម្បីផលប្រយោជន៍រួមរបស់ប្រជាពលរដ្ឋ។
- ស្រដៀងគ្នានេះដែរ កម្មវិធីអភិវឌ្ឍន៍ប្រជាជាតិ ១៩៩៧ (UNDP1997) បានឲ្យនិយមន័យថា អភិបាលកិច្ចជាការប្រើប្រាស់អំណាចខាងនយោបាយ សេដ្ឋកិច្ច និងរដ្ឋបាលដើម្បីគ្រប់គ្រងកិច្ចការរបស់ប្រទេស។

សរុបជារួមមកនិយមន័យនៃអភិបាលកិច្ច ទោះបីស្ថិតក្នុងក្របខ័ណ្ឌណាក៏ដោយ ក៏ជាការផ្តោតសំខាន់ទៅលើវិធីសាស្ត្រក្នុងការគ្រប់គ្រង និងប្រើប្រាស់ធនធានរបស់អង្គភាព ឬស្ថាប័នដើម្បីបម្រើផលប្រយោជន៍ទូទៅរបស់ប្រជាពលរដ្ឋឲ្យចំទិសដៅ និងមានប្រសិទ្ធភាព។

## ១.២.គោលបំណងនៃអភិបាលកិច្ចល្អ

គោលបំណងនៃអភិបាលកិច្ចល្អ គឺដើម្បីគ្រប់គ្រងសេដ្ឋកិច្ច សង្គមកិច្ច និងវិបត្តិទាំងឡាយតាមមធ្យោបាយមួយដែលផ្តល់នូវប្រយោជន៍យ៉ាងច្រើនបំផុតដល់ប្រជាពលរដ្ឋ។ ដើម្បីសម្រេចគោលបំណងខាងលើនេះ គេទទួលស្គាល់ជាទូទៅថា អភិបាលកិច្ចទាមទារនូវការអភិវឌ្ឍន៍ ធនធានមនុស្ស

[1] សម្តេចសង្ឃរាជ ជួន ណាត "វចនានុក្រមខ្មែរ" ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត ១៩៦៧-១៩៦៨ ទំព័រទី១៦៦៩

[2] សម្តេចសង្ឃរាជ ជួន ណាត "វចនានុក្រមខ្មែរ" ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត ១៩៦៧-១៩៦៨ ទំព័រទី៣៨

ប្រកបដោយនិរន្តរភាព។ ការអភិវឌ្ឍន៍ធនធានមនុស្សប្រកបដោយនិរន្តរភាពផ្តោតលើកិច្ចការសំខាន់ៗ ដូចខាងក្រោម៖

- ត្រូវផ្តល់សេវាថែទាំសុខភាពល្អសមស្រប និងគ្រប់គ្រាន់សម្រាប់ប្រជាពលរដ្ឋទាំងអស់ ដើម្បីជួយឲ្យពួកគេមានសុខភាពមាំមួន និងអាយុយឺនយូរ។ នេះជាកត្តាដែលធ្វើឲ្យប្រជាពលរដ្ឋមានសុខុមាលភាព និងថាមពលគ្រប់គ្រាន់ដើម្បី ចូលរួមយ៉ាងពេញលេញក្នុងសកម្មភាពសេដ្ឋកិច្ច និងសង្គម។
- ត្រូវមានសេវាអប់រំល្អសមស្រប និងគ្រប់គ្រាន់សម្រាប់ប្រជាពលរដ្ឋទូទៅ ដើម្បីឲ្យពួកគេមានចំណេះដឹង និងជំនាញពេញលេញ ក្នុងការបង្កើតឱកាសឲ្យបានច្រើន និងសមស្របបំផុតសម្រាប់ខ្លួនគេ។
- ត្រូវបង្កើតឲ្យឱកាសសម្រាប់ប្រជាពលរដ្ឋទូទៅ ដើម្បីទទួលបាននូវផលប្រយោជន៍ពីសកម្មភាពសេដ្ឋកិច្ច និងមានការងារធ្វើ ដើម្បីរកបានប្រាក់ចំណូលគ្រប់គ្រាន់សម្រាប់បំពេញតម្រូវការជាមូលដ្ឋាន ដូចជា ស្បៀងអាហារ សំលៀកបំពាក់ ជម្រក ជាដើម សម្រាប់ពួកគេផ្ទាល់ និងក្រុមគ្រួសាររបស់ពួកគេ។

ចំណុចសំខាន់ទាំង បី ខាងលើនេះ ត្រូវបានអនុវត្តតាមមធ្យោបាយដែលធានាបាននូវការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាព និងការថែរក្សាបរិស្ថាន ។ ជាងនេះទៅទៀត ក្នុងគោលការណ៍អភិបាលកិច្ចល្អនេះដែរ ក៏មានអត្ថប្រយោជន៍មួយចំនួនចំពោះអ្នកដឹកនាំដូចជា៖

- ប្រជាពលរដ្ឋមានការពេញចិត្តទៅ និងការដឹកនាំ
- មានភាពរុងរឿងជាទូទៅ
- ប្រទេសមានសន្តិសុខសណ្តាប់ធ្នាប់
- មន្ត្រីរបស់រាជរដ្ឋាភិបាលនឹងទទួលបាននូវការគោរព និងរង្វាន់
- អ្នកដឹកនាំខាងនយោបាយត្រូវបានប្រជាពលរដ្ឋពេញចិត្ត និងបោះឆ្នោតឲ្យ។[3]

## ១.៣.តួអង្គសំខាន់នៃអភិបាលកិច្ចល្អ

កាលពីមុនគេយល់ឃើញថា មានតែរដ្ឋាភិបាលមួយគត់ដែលជាតួអង្គនៃអភិបាលកិច្ច។ ប៉ុន្តែបច្ចុប្បន្ននេះ មានគំនិតថ្មីៗជាច្រើនបានបង្ហាញឲ្យឃើញថា ផ្នែកឯកជន និងអង្គការសង្គមស៊ីវិលផ្សេងៗទៀតក៏បានដើរតួនាទីយ៉ាងសំខាន់ក្នុងការគ្រប់គ្រងសេដ្ឋកិច្ច និងសង្គមកិច្ចរបស់ប្រទេសផងដែរ។

[3] អគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន នៃក្រសួងមហាផ្ទៃ "អភិបាលកិច្ចល្អ" ឆ្នាំ២០០៨ ទំព័រទី៣

ជាពិសេសស្ថាប័នស្ថាប័នទាំងឡាយដែលមានភារកិច្ចជាអ្នកសម្រេចចិត្តនោះ ត្រូវតែបើកទ្វារទូលំទូលាយឲ្យ អង្គការសង្គមស៊ីវិល និងផ្នែកឯកជនចូលរួម ទើបការសម្រេចចិត្តនោះ ឆ្លើយតបនឹងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ ហើយគេនិងពេញចិត្តអនុវត្តតាម ព្រោះគេយល់ថា អ្វីដែលកើតពីការសម្រេចចិត្តនោះ គឺជាសំលេងរបស់ពួកគេមួយផ្នែកដែរ។

ដូចនេះ តួអង្គសំខាន់ក្នុងអភិបាលកិច្ចមាន **បី** គឺៈ

- រដ្ឋ (ស្ថាប័ននយោបាយ និងរដ្ឋាភិបាល ជាតួអង្គសំខាន់ជាងគេ)
- ផ្នែកឯកជន
- សង្គមស៊ីវិល

ឥទ្ធិពលនៃតួអង្គផ្នែកឯកជន និងសង្គមស៊ីវិលមានភាពខុសគ្នា ពីប្រទេសមួយទៅប្រទេសមួយអាស្រ័យលើលក្ខខណ្ឌមួយចំនួន ដូចជា ប្រព័ន្ធនយោបាយលក្ខណៈអំណោយផលខាងធនធានធម្មជាតិប្រជាពលរដ្ឋ ទីតាំងភូមិសាស្ត្រប្រវត្តិសាស្ត្រវប្បធម៌ និងកម្រិតនៃការអភិវឌ្ឍសេដ្ឋកិច្ច។ជាក់ស្តែងនៅក្នុងប្រទេសខ្លះ ផ្នែកឯកជន និងសង្គមស៊ីវិល មានអំណាច និងវិសាលភាពយ៉ាងធំធេង ប៉ុន្តែនៅប្រទេសមួយចំនួនផ្សេងទៀត ផ្នែកឯកជន និងសង្គមស៊ីវិលនេះ មានអំណាចឱកាស និងឥទ្ធិពលតិចតួចទៅលើកិច្ចការប្រទេសជាតិ។

អភិបាលកិច្ចល្អ ជាវិធីសាស្ត្រ ឬមធ្យោបាយ ដែលរដ្ឋ ស្ថាប័ន អង្គភាព ប្រើប្រាស់ក្នុងការគ្រប់គ្រងសេដ្ឋកិច្ច សង្គមកិច្ច និងសន្តិសុខ ដើម្បីបម្រើផលប្រយោជន៍រួមរបស់ប្រជាពលរដ្ឋ ដោយបំពេញបាននូវគោលការណ៍ទាំង ៨ ខាងក្រោមនេះៈ

**តារាងទី១ៈ** គោលការណ៍ទាំង ៨ នៃអភិបាលកិច្ចល្អ




**ប្រភព**ៈ http://kdevevelop.wordpress.com

## ១.៤.លក្ខណៈនៃអភិបាលកិច្ច

ប្រភេទទាំង ៤ នៃអភិបាលកិច្ច ត្រូវបានគេយកមកពិនិត្យថ្លឹងថ្លែងដូចតទៅ៖

- **អភិបាលកិច្ចសេដ្ឋកិច្ច** គឺជាដំណាក់កាលនានានៃការសម្រេចចិត្ត ដែលប៉ះពាល់ដោយផ្ទាល់ឬដោយប្រយោលទៅលើសកម្មភាពដទៃទៀត ។ អភិបាលកិច្ចសេដ្ឋកិច្ចនេះ មានឥទ្ធិពលយ៉ាងខ្លាំងទៅលើ បញ្ហាសង្គមដូចជា ភាពត្រឹមត្រូវ ភាពក្រីក្រ និង គុណភាពនៃជីវភាព។
- **អភិបាលកិច្ចនយោបាយ** បានដល់ការសម្រេចចិត្ត និងការអនុវត្តន៍គោលនយោបាយរបស់នីតិប្រទេស (Legitimate state) និងប្រទេសដែលប្រើអំណាចផ្តាច់ការ (Authoritative state) ។ រដ្ឋត្រូវតែធ្វើឲ្យមានការបែងចែកឲ្យដាច់ស្រឡះរវាងអំណាចនីតិបញ្ញត្តិ នីតិប្រតិបត្តិ និងអំណាចតុលាការ ត្រូវប្រកាន់យកគោលនយោបាយពហុភាព និងអនុញ្ញាត្តិឲ្យពលរដ្ឋធ្វើការបោះឆ្នោតដោយសេរី។
- **អភិបាលកិច្ចរដ្ឋបាល** គឺជាប្រព័ន្ធនៃការអនុវត្តន៍គោលការណ៍នយោបាយ តាមរយៈអង្គការសាធារណៈ ដែលមានប្រសិទ្ធភាពឯករាជ្យ មានការទទួលខុសត្រូវ និងមានភាពចំហរ។
- **អភិបាលកិច្ចជាប្រព័ន្ធ** គឺជាអភិបាលកិច្ចដែលក្រសោបដំណើរការ និងរចនាសម្ព័ន្ធសង្គមដែលធ្វើឲ្យមានទំនាក់ទំនងផ្នែកនយោបាយសង្គម សេដ្ឋកិច្ច ដើម្បីការពារវប្បធម៌ ជំនឿសាសនា និងតំលៃសីលធម៌ និងដើម្បីប្រើប្រាស់សមត្ថភាពរបស់ពួកគេក្នុងការកសាងជីវភាពឲ្យបានខ្ពង់ខ្ពស់ ។ ប្រព័ន្ធអភិបាលកិច្ចរៀបចំនេះ គេច្រើនតែជួបប្រទះនៅក្នុងប្រទេសរីកចំរើន ដែលនៅក្នុងប្រទេសនោះ ធនធានមនុស្សមានការអភិវឌ្ឍន៍ខ្ពស់ និងមានការគោរពច្បាប់ត្រឹមត្រូវ និងមានគុណភាពខ្ពស់។[4]

## ១.៥.គោលការណ៍នៃអភិបាលកិច្ច

### ១.៥.១.គិតពីសេវាសាធារណៈល្អ

សេវាសាធារណៈ គឺជាសកម្មភាពទាំងឡាយណាដែលធ្វើឡើងដោយស្ថាប័នមានសមត្ថកិច្ច និងស្ថាប័នមានសមត្ថកិច្ច ក្នុងគោលដៅបម្រើផលប្រយោជន៍សាធារណៈ ។ នៅក្នុងលទ្ធិប្រជាធិតេយ្យ រដ្ឋាភិបាលត្រូវបានបង្កើតឡើងដោយឆន្ទៈរបស់ប្រជាពលរដ្ឋ ដោយតាមរយៈការបោះឆ្នោតដោយសេរីតម្លាភាព និងយុត្តិធម៌។ នេះជាទស្សនៈដែលចែងថា រដ្ឋាភិបាលកើតឡើងដើម្បីបម្រើប្រជាពល

[4] អគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ "អភិបាលកិច្ចល្អ" ឆ្នាំ២០០៨ ទំព័រទី៤

រដ្ឋ ពុំមែនសម្រាប់ប្រើអំណាចត្រួតត្រាពលរដ្ឋទេ។ ការបម្រើ (ឬការផ្តល់សេវា) គឺមិនមែនជាការប្រើអំណាចត្រួតត្រាទេ។ ព្រោះអំណាចដែលបានកើតឡើងមានមកនោះ វាបានកើតឡើង ពីអំណាចដោយផ្ទាល់របស់ប្រជាពលរដ្ឋក្នុងការជ្រើសរើសអ្នកដឹកនាំរបស់ខ្លួន ដើម្បីធ្វើការដឹកនាំប្រកបដោយភាពរីកចំរើន ។ ដូចនេះគ្រប់ស្ថាប័នទាំងអស់ដែលបង្កើតឡើងក្នុងកម្មវត្ថុសម្រាប់បម្រើប្រជាពលរដ្ឋត្រូវតែកំណត់នូវយុទ្ធសាស្ត្រមួយក្នុងការផ្តល់សេវាសាធារណៈ ដោយធ្វើយ៉ាងណាធ្វើឲ្យសេវាសាធារណៈ នេះកាន់តែខិតជិតប្រជាពលរដ្ឋតាមរយៈកំណែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាល។

### ១.៥.២.ការចូលរួមរបស់ប្រជាពលរដ្ឋ

#### ក.ការចូលរួមពីប្រជាពលរដ្ឋដោយផ្ទាល់

ក្នុងរបបប្រជាធិបតេយ្យប្រជាពលរដ្ឋ មានសិទ្ធិចូលរួមដោយផ្ទាល់ពាក់ព័ន្ធកិច្ចការសាធារណៈ និង កិច្ចអភិវឌ្ឍន៍មូលដ្ឋានដូចជាការៈ

- បោះឆ្នោត
- ចូលរួមក្នុងគណបក្សនយោបាយ
- ឈរឈ្មោះបោះឆ្នោត
- បង្កើតសមាគម
- ធ្វើការសម្រេចចិត្ត និងអនុវត្តសេចក្តីសម្រេចចិត្តនៃសកម្មភាពអភិវឌ្ឍន៍មូលដ្ឋាន។

#### ខ.ការចូលរួមតាមរយៈអ្នកតំណាង

អ្នកតំណាង ត្រូវបំពេញតួនាទីជាអ្នកតំណាងដោយឆន្ទៈ និងរាល់ការសម្រេចចិត្ត គឺដើម្បីផលប្រយោជន៍ប្រជាពលរដ្ឋដែលខ្លួនតំណាងឲ្យ។ អ្នកត្រូវបានជ្រើសរើសតាមវិធីផ្សេងៗទៅតាមលក្ខណៈ និងស្ថានភាពជាក់ស្តែងដូចជាៈ

- ការបោះឆ្នោតសកល ឬអសកល (សមាជិកសភា ឬសមាជិកព្រឹទ្ធសភាក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់)
- ការតែងតាំង និងជ្រើសតាំងជាដើម។

### ១.៥.៣.នីតិរដ្ឋ

នីតិរដ្ឋ ក្នុងន័យអភិបាលកិច្ច គឺទាមទាឲ្យមានឯកសារក្របខណ្ឌច្បាប់គ្រប់គ្រាន់ គឺលិខិតគតិយុត្តដែលរួមមាន ច្បាប់ ព្រះរាជក្រឹត្យ ប្រកាស សេចក្តីសម្រេច សេចក្តីណែនាំ ដីកា និងលិខិតបទដ្ឋាននានា ដើម្បីបម្រើ និងការពារផលប្រយោជន៍សាធារណៈ ហើយច្បាប់ទាំងនេះត្រូវបានអនុវត្តដោយមិនលំអៀង។ លើសពីនេះច្បាប់ទាំងនេះត្រូវតែការពារសិទ្ធិមនុស្ស ជាពិសេសក្រុមដែលងាយរងគ្រោះ ឬក្រុមភាគតិច។ ដូច្នេះត្រូវតែមានប្រព័ន្ធតុលាកាឯករាជ្យ និងយុត្តិធម៌ និងសមត្ថភាពពង្រឹងការអនុវត្តន៍ច្បាប់ដោយមិនលំអៀង និងមិនពុករលួយ។

**នីតិរដ្ឋក្នុងន័យអភិបាលល្អផ្តោតទៅលើ៖**

- **មានឯកសារក្របខណ្ឌច្បាប់ គោរពច្បាប់ និងអនុវត្តច្បាប់**
  - គោលការណ៍ ៖ តាមការវិវត្តន៍របស់សង្គម និងតាមតម្រូវការនៃការគ្រប់គ្រងរដ្ឋ
  - ច្បាប់ផ្ទៃក្នុង ៖ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាសបទបញ្ជា
  - ច្បាប់អន្តរជាតិ ៖ សន្ធិសញ្ញា អនុសញ្ញា កតិកាសញ្ញា ពិធីសារ
- **មានប្រព័ន្ធទទួលខុសត្រូវ**
  - ខាងអំណាចនយោបាយ ៖ សភា រដ្ឋាភិបាល ប្រមុខរដ្ឋ
  - ខាងអំណាចនីតិប្រតិបត្តិ ៖ រដ្ឋបាល អាជ្ញាធរដែនដី មន្ត្រីរាជការ
  - ខាងអំណាចតុលាការ ៖ ជាអ្នកធ្វើឲ្យគោរពច្បាប់ ចៅក្រម
- **មានប្រព័ន្ធយុត្តធម៌**
  - គោលការណ៍ ឯករាជ្យ និង យុត្តិធម៌
  - ប្រព័ន្ធក្នុងតុលាការ
    - \+ តុលាការខេត្ត ក្រុង និងតុលាការយោធា
    - \+ សាលាឧទ្ធរណ៍
    - \+ តុលាកាកំពូល
  - ប្រព័ន្ធក្រៅតុលាការ
    - \+ ការចចារ
    - \+ សន្ធានកម្ម ឬការផ្សះផ្សា
    - \+ មជ្ឈត្តវិនិច្ឆ័យ។[5]

### ១.៥.៤.តម្លាភាព និងការឆ្លើយតប

តម្លាភាព មានន័យថា ភាពបើកចំហរសាធារណៈជនត្រូវតែអាចមើលឃើញ ដឹង ឮ នូវអ្វី រាជរដ្ឋាភិបាលកំពុងធ្វើ ។ ជាទូទៅការងាររដ្ឋាភិបាល គឺជាការងាររបស់ប្រជាជន ហើយមិនត្រូវមានការលាក់បាំងទេ ។ រាជរដ្ឋាភិបាលត្រូវតែបើកចំហរជូនប្រជាពលរដ្ឋធ្វើអភិបាលកិច្ច ហើយផ្សព្វផ្សាយព័ត៌មានអំពីអ្វី ដែលរាជរដ្ឋាភិបាលកំពុងធ្វើ ។ ការធ្វើដូចនេះ អាចឲ្យប្រជាពលរដ្ឋមើលឃើញថាអ្វីៗដែលរដ្ឋាភិបាលកំពុងធ្វើ និងរៀបចំធ្វើ គឺក្នុងនាមប្រជាពលរដ្ឋ ហើយឆ្លើយតបទៅនឹងផលប្រយោជន៍ប្រជាពលរដ្ឋ ។ រាជរដ្ឋាភិបាលអនុវត្តគោលនយោបាយតម្លាភាពដោយផ្តល់ព័ត៌មាន

[5] អគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន នៃក្រសួងមហាផ្ទៃ "អភិបាលកិច្ចល្អ" ឆ្នាំ២០០៨ ទំព័រទី៧

ទៅឲ្យសារព័ត៌មាន ដោយការឆ្លើយតបដោយចេតនាទៅនឹងសំណួរ ឬសំណើរសុំព័ត៌មានពីសំណាក់អ្នកកាសែតពីសំណាក់សមាជិកសភា ពីសំណាក់សាធារណៈជន ហើយនឹងដោយមានការបោះផ្សាយឯកសារជាច្រើន ដែលពន្យល់អំពីអ្វីដែលរាជរដ្ឋាភិបាលកំពុងធ្វើ ។ ការឆ្លើយតបក្នុងន័យនេះមានន័យថា ការខិតខំប្រឹងប្រែងរបស់អង្គភាព ស្ថាប័ន ដើម្បីបម្រើដល់ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធទាំងអស់ដោយស្មើរភាពគ្នា និងមិនរើសអើង។ ដោយការឆ្លើយតបអាចជា៖

- ការបំពេញសេវាកម្មជូនប្រជាពលរដ្ឋតាមការស្នើរសុំ
- ដំណោះស្រាយដែលស្តែងឡើងតាមសកម្មភាព ដើម្បីដោះស្រាយបញ្ហា ឬការលំបាកនានា
- ការឆ្លើយបំភ្លឺអំពីមូលហេតុដែលមិនអាចឈានដល់ការធ្វើសកម្មភាព ដើម្បីដោះស្រាយបញ្ហា ឬការលំបាកទាំងនោះ ព្រមទាំងជំរាបអំពីសំណើរសុំអន្តរាគមន៍នេះដល់ប្រជាពលរដ្ឋដែលពាក់ព័ន្ធ និងបញ្ហា ឬការលំបាកទាំងនោះ។

### ១.៥.៥.ការទទួលខុសត្រូវ និង គណនេយ្យភាព

ការទទួលខុសត្រូវ មានន័យថា រាជរដ្ឋាភិបាលទទួលខុសត្រូវចំពោះសាធារណៈជននូវអ្វីដែលខ្លួនធ្វើ ។ គណនេយ្យភាព មានន័យថា រាជរដ្ឋាភិបាលត្រូវតែពន្យល់ និងបញ្ជាក់អំពីសកម្មភាព និងសេចក្តីសម្រេចរបស់ខ្លួនជូនសាធារណៈជន ។

គណនេយ្យភាពចំពោះប្រព័ន្ធវិមជ្ឈការ មានន័យថា ជាការអនុវត្តន៍តួនាទី និងភារកិច្ចនៅក្នុងដំណើរការ និងអនុវត្តសេចក្តីសម្រេចចិត្ត ហើយទទួលខុសត្រូវចំពោះទង្វើរបស់ខ្លួនដោយរាយ-ការណ៍ព្រមទាំងបញ្ជាក់ពីមូលហេតុនូវអ្វីដែលខ្លួនបានសម្រេច និងអនុវត្ត។ មិនមែនមានតែរដ្ឋាភិបាល ស្ថាប័ន និងអង្គភាពរដ្ឋាភិបាលប៉ុណ្ណោះទេដែលមានគណនេយ្យភាព អង្គការសង្គមស៊ីវិល និងក្រុមហ៊ុនឯកជន ក៏ត្រូវមានគណនេយ្យភាពជាសាធារណៈ ចំពោះអ្នកពាក់ព័ន្ធទាំងអស់របស់ខ្លួនផងដែរពិសេសចំពោះអ្នកដែលទទួលរងនូវផលប៉ះពាល់នៃការសម្រេចចិត្ត។

មន្ត្រីសាធារណៈទាំងអស់ ក៏មានការទទួលខុសត្រូវផ្ទាល់ខ្លួន ចំពោះអ្វីដែលខ្លួនធ្វើដែរ។ ហេតុនេះ មន្ត្រីសាធារណៈត្រូវមានគណនេយ្យភាពចំពោះថ្នាក់ដឹកនាំ និងគណនេយ្យភាពចំពោះមុខសាធារណៈជន។ មន្ត្រីសាធារណៈទាំងអស់ ត្រូវមានគណនេយ្យភាពចំពោះសាធារណៈជន ពីព្រោះពួកគេបានតែងតាំងឡើងដើម្បីបម្រើសាធារណៈជន។ កាលពីមុនគេសង្កេតឃើញថា មន្ត្រីរាជការត្រូវបានតែងតាំងឡើងដើម្បីដឹកនាំប្រជាពលរដ្ឋ។ ប៉ុន្តែបច្ចុប្បន្ននេះតួនាទីរបស់មន្ត្រីរាជការ គឺផ្តោតទៅលើការផ្តល់សេវាជូនប្រជាពលរដ្ឋ។

**១.៥.៥.១.គណនេយ្យភាពក្នុងន័យវិមជ្ឈការចំពោះថ្នាក់ដឹកនាំ**

សមាជិកម្នាក់ៗត្រូវមានគណនេយ្យភាពចំពោះមុខថ្នាក់ដឹកនាំរបស់ខ្លួនតាមលំដាប់ថ្នាក់ និង អ្នកផ្តល់ធនធានថវិកា គឺដូចជាក្នុងករណីជាក់ស្តែងមួយមេឃុំ បានស្នើសុំឲ្យស្មៀនឃុំ សង្កាត់ យករបាយការណ៍ប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាសង្កាត់ ទៅឲ្យអង្គភាពរដ្ឋបាលមូលដ្ឋាន ខេត្ត រាជធានី។ សកម្មភាពដែលស្មៀនឃុំសង្កាត់ចុះទៅរាយការណ៍នេះទៅឲ្យអង្គភាពរដ្ឋបាលមូលដ្ឋាន ខេត្ត រាជធានី ជាការបំពេញតួនាទី និងភារកិច្ចរបស់ស្មៀន ឃុំ សង្កាត់។ នៅពេលត្រឡប់មកដល់ឃុំ សង្កាត់វិញ ស្មៀនឃុំ សង្កាត់ត្រូវរាយការណ៍ជូនមេឃុំ និងសង្កាត់ថាគាត់បានប្រគល់របាយការណ៍នេះទៅឲ្យមន្ត្រីរដ្ឋបាលនៃអង្គភាពរដ្ឋបាលមូលដ្ឋាន ខេត្ត រាជធានី ១០ មិថុនា ម្សិលមិញនេះព្រមទាំងបញ្ជាក់ផងដែរថាមន្ត្រីរូបនោះបានចុះហត្ថលេខាទៅលើសៀវភៅបញ្ជូនលិខិត។ ស្មៀន ឃុំ សង្កាត់ យកសំបុត្រទៅឲ្យអង្គភាពរដ្ឋបាលមូលដ្ឋាន និងរាយការណ៍ជូនមេឃុំ សង្កាត់ មានន័យថាស្មៀនមានគណនេយ្យភាពចំពោះមេឃុំ និងចៅសង្កាត់។

**១.៥.៥.២.គណនេយ្យភាពក្នុងន័យវិមជ្ឈការចំពោះមុខសាធារណៈជន**

មន្ត្រីសាធារណៈទាំងអស់ ត្រូវមានគណនេយ្យភាពចំពោះសាធារណៈជន ពីព្រោះពួកគេត្រូវបានតែងតាំងឡើងដើម្បីសាធារណៈជន។ កាលពីមុនជារឿយៗគេសង្កេតឃើញថាមន្ត្រីរាជការត្រូវបានតែងតាំងឡើង ដើម្បីដឹកនាំប្រជាពលរដ្ឋ ប៉ុន្តែបច្ចុប្បន្ននេះតួនាទីរបស់មន្ត្រីរាជការត្រូវបានតែងតាំងឡើងដើម្បីផ្តល់សេវាជូនប្រជាពលរដ្ឋ។ ដូច្នេះពួកគេត្រូវមានគណនេយ្យភាពចំពោះមុខប្រជាពលរដ្ឋទូទៅ។ ដូចគ្នានេះដែរ ចំពោះភ្នាក់ងារឯកជនដែលផ្តល់សេវាកម្មដល់អតិថិជនរបស់ខ្លួនមិនត្រឹមតែមានគណនេយ្យភាពចំពោះអតិថិជនរបស់ខ្លួនតែប៉ុណ្ណោះទេ ប៉ុន្តែក៏ត្រូវមានគណនេយ្យភាពចំពោះសាធារណៈជនទូទៅផងដែរ។ ព្រោះថាការព្យាយាមផ្តល់ផលប្រយោជន៍ និងតម្រូវចិត្តដល់អតិថិជនក្រុមណាមួយអាចធ្វើឲ្យមានផលប៉ះពាល់ដល់ក្រុមផ្សេងទៀត ឬសាធារណជនទូទៅ។ គឺចំពោះនីតិវិធីនៃការអនុវត្តន៍ផ្ទាល់គឺ ក្រុមប្រឹក្សាឃុំ សង្កាត់ សម្រេចប្រើប្រាស់ថវិកាមូលនិធិឃុំសង្កាត់សម្រេចប្រើប្រាស់ថវិកាមូលនិធិឃុំ សង្កាត់ ដើម្បីសាងសង់ផ្លូវលំមួយខ្សែប្រវែង ៣ គីឡូម៉ែត្រក្នុងភូមិមួយ។ សកម្មភាពដែលក្រុមប្រឹក្សាឃុំ សង្កាត់ធ្វើសេចក្តីសម្រេចអំពី ការប្រើប្រាស់មូលនិធិឃុំ សង្កាត់ និងអនុវត្តការកសាងផ្លូវលំនេះ គឺជាការបំពេញតួនាទី និងភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ។

- បន្ទាប់ពីការសម្រេច ក្រុមប្រឹក្សាឃុំ សង្កាត់ ជំរាបជូនប្រជាពលរដ្ឋ
- ដំណើរការ និងមូលហេតុនៃការធ្វើសេចក្តីសម្រេចចិត្តក្នុងការសាងសង់ផ្លូវលំ
- ផ្តល់ចម្លើយសមរម្យដល់ អ្នកពាក់ព័ន្ធទាំងឡាយ ដែលទទួលផលប៉ះពាល់ពីការសាងសង់ផ្លូវលំនោះ

- លទ្ធផលនៃការសាងសង់ផ្លូវលំនោះ

ក្រុមប្រឹក្សាឃុំ សង្កាត់សម្រេចប្រើប្រាស់មូលនិធិឃុំ សង្កាត់ និងរាយការណ៍ជូនប្រជាពលរដ្ឋ មានន័យថា ក្រុមប្រឹក្សាឃុំ សង្កាត់ មានគណនេយ្យភាពចំពោះប្រជាពលរដ្ឋ និងសាធារណៈជន។

### ១.៥.៦.ការចាត់ចែងល្អ និងប្រសិទ្ធភាពខ្ពស់

ការចាត់ចែងល្អ គឺជាប្រធានបទទាំងមូលសម្រាប់ធ្វើការសិក្សាដ៏យូរអង្វែង។ ប៉ុន្តែនិយាយដោយសង្ខេបការចាត់ចែងល្អនេះមានលក្ខណៈដូចគ្នាទោះរាជរដ្ឋាភិបាលក្តី អង្គការក្តី។ នេះមានន័យថា រាជរដ្ឋាភិបាលមានប្រព័ន្ធមួយសម្រាប់ប្រតិបត្តិការប្រកបដោយប្រសិទ្ធភាព និងមានភាពស័ក្តិសិទ្ធិ គឺថាបានទទួលលទ្ធផលទាន់ពេល និងមិនខ្ជះខ្ជាយធនធាន។

ការចាត់ចែងល្អវាផ្សារភ្ជាប់ទៅនិងប្រសិទ្ធភាពខ្ពស់ផងដែរ ។ ប្រសិទ្ធភាពខ្ពស់ក្នុងន័យអភិបាលកិច្ចល្អមានន័យថា ជាដំណើរការ និងរចនាសម្ព័ន្ធគ្រប់គ្រងក្នុងការប្រើប្រាស់ធនធានឲ្យអស់លទ្ធភាព និងសន្សំសំចៃខ្ពស់ ដើម្បីបង្កើតលទ្ធភាពមានគុណភាពខ្ពស់ បរិមាណច្រើន អាចបម្រើផលប្រយោជន៍ជាអតិបរមា និងបានឆ្លើយតបទៅនឹងតម្រូវការពិតរបស់សង្គម។ គោលគំនិតនៃប្រសិទ្ធភាពខ្ពស់នៅក្នុងបរិបទអភិបាលកិច្ចល្អក៏រាប់បញ្ចូលផងដែរ ចំពោះការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាពនិងការពារបរិស្ថាន។ ដើម្បីឲ្យមានប្រសិទ្ធភាពខ្ពស់ក្នុងការអនុវត្តន៍ត្រូវពិចារណាលើចំណុចមួយចំនួនដូចខាងក្រោម៖

- ការប្រើប្រាស់ធនធាន (ធនធានមនុស្ស ថវិកា ហិរញ្ញវត្ថុ សម្ភារៈពេលវេលា) ឲ្យបានត្រឹមត្រូវ
- ការអនុវត្តន៍សកម្មភាពដែលជាអាទិភាពខ្ពស់
- ជៀសវាងការអនុវត្តន៍នូវការិយាធិបតេយ្យ
- ការគិតគូររយៈពេលវែងលើការប្រើប្រាស់ធនធានធម្មជាតិ
- គ្មានអំពើពុករលួយ
- ការសម្រេចចិត្តបែបវិមជ្ឈការ។

### ១.៥.៧.ការព្រមព្រៀងឯកភាព និងសមធម៌

ការព្រមព្រៀងឯកភាពគ្នា ក្នុងន័យអភិបាលកិច្ចល្អ គឺជាកាពិចារណាដោយទូលំទូលាយ និងវែងទៅលើការសម្រេចចិត្តដោយមានការឯកភាពគ្នាលើជំរើស និងវិធីសាស្ត្រមួយដែលបម្រើផលប្រយោជន៍សាធារណៈ។

សមធម៌ក្នុងន័យអភិបាលកិច្ចល្អ គឺមានន័យថា ក្រុម ឬជនគ្រប់រូបទាំងអស់ជាពិសេស គឺជនជាតិភាគតិច និងក្រុមដែលងាយរងគ្រោះមានឱកាសគ្រប់គ្រាន់ក្នុងការចូលរួម និងបញ្ចេញមតិ

យោបល់លើកឡើងនូវតម្រូវការពិតអនុវត្តសកម្មភាព និងទទួលផលប្រយោជន៍សមស្រប ដើម្បីកែលម្អ និងថែរក្សាសុខុមាលភាពរបស់ពួកគេ។ សុខុមាលភាពផ្តោតជាសំខាន់ទៅលើភាពសប្បាយរីករាយ ភាពសុខស្រួល សុវត្ថិភាព សុខភាព គុណភាពនៃជីវភាព។ សុខុមាលភាពរបស់បុគ្គលមិនគ្រាន់តែគិតលើផ្នែករូបរាងកាយប៉ុណ្ណោះទេ ត្រូវគិតដល់ផ្នែកជំនឿ សាសនា ស្មារតី អារម្មណ៍ ផ្លូវចិត្ត ព្រមទាំងភាពគ្រប់គ្រាន់នៃជីវភាពរស់នៅផងដែរ។

## ១.៦.អភិបាលកិច្ចក្នុងក្របខណ្ឌគោលនយោបាយច្បាប់

### ១.៦.១.អភិបាលកិច្ចក្នុងក្របខណ្ឌយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល

រាជរដ្ឋាភិបាលនៃនីតិកាលទី៤នៃរដ្ឋសភា បន្តអនុវត្តគោលនយោបាយ នៃយុទ្ធសាស្ត្រចតុកោណសំដៅលើកស្ទួយកិច្ចអភិវឌ្ឍន៍លើគ្រប់វិស័យរបស់កម្ពុជា។

គោលការណ៍កំណែរទម្រង់សំខាន់ៗ ក្នុងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ផ្តោតលើអភិបាលកិច្ចល្អ ជាស្នូលសំដៅលើកំណែទម្រង់វិស័យ ៤ សំខាន់ៗៈ

កំណែទម្រង់រដ្ឋបាលសាធារណៈ:

- កំណែទម្រង់ប្រព័ន្ធច្បាប់ និងតុលាការ
- ការប្រយុទ្ធប្រឆាំង និងអំពើពុករលួយ
- កំណែទម្រង់កងកំលាំងប្រដាប់អាវុធ

កំណែទម្រង់រដ្ឋបាលសាធារណៈ:ផ្តោតលើការធានាផ្តល់សេវាសាធារណៈ:ជូនប្រជាពលរដ្ឋៈ

- **ទីមួយ** សេវាពាក់ព័ន្ធនឹងអធិបតេយ្យភាពរបស់ប្រជាពលរដ្ឋ( ដូចជា អត្រានុកូលដ្ឋាន លិខិតអនុញ្ញាតិផ្សេងៗប័ណ្ណកម្មសិទ្ធិដីធ្លី)
- **ទីពីរ** សេវាពាក់ព័ន្ធនិងការវិនិយោគ
- **ទីបី** សេវាមូលដ្ឋាន (អប់រំ និងសុខាភិបាល)
- **ទីបួន** សេវាពាក់ព័ន្ធ និងចំនូលចំណាយរបស់រដ្ឋ។

នីតិវិធីនៃការទទួលសេវាសាធារណៈ ត្រូវធ្វើឲ្យសាមញ្ញតាមរយៈច្រកចេញចូលតែមួយ ការកាត់បន្ថយការិយាធិបតេយ្យ ព្រមទាំងបង្កើតការិយាល័យប្រជាពលរដ្ឋ ។ ការអនុវត្តន៍ គោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ តាមរយៈការរៀបចំរដ្ឋបាលដែនដី នៃព្រះរាជាណាចក្រកម្ពុជាតាមរយៈច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់។ ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ តាមគោលការណ៍រដ្ឋបាលឯកភាពដើម្បីបង្កើតជម្រុញ និងធ្វើឲ្យមានចីរភាពដល់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យ។ រដ្ឋបាល

ឯកភាពនេះជួយគាំទ្រឃុំសង្កាត់ ដើម្បីអភិវឌ្ឍន៍មូលដ្ឋាន និងចូលរួមពង្រឹងលទ្ធិមូលដ្ឋាននៅមូលដ្ឋាន។ កំណែទម្រង់ច្បាប់ និងតុលាការ រាជរដ្ឋាភិបាលជម្រុញធានានូវឯករាជ្យភាព អព្យាក្រឹតភាពនៃប្រព័ន្ធតុលាការ ។ ក្នុងគោលដៅនេះឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម មានដំណើរប្រព្រឹត្តទៅដោយឯករាជ្យពិតប្រាកដ។ ដើម្បីកំណែទម្រង់ច្បាប់ តុលាការ រាជរដ្ឋាភិបាលរៀបចំគំរោងជាអទិភាពនូវបណ្តាច្បាប់ជាមូលដ្ឋាន ដើម្បីដាក់ឆ្លងរដ្ឋសភាមានជាអាទិ៍ ច្បាប់លក្ខន្តិៈចៅក្រម ច្បាប់ស្តីពីការរៀបចំអង្គការ តុលាការ ក្រមព្រហ្មទណ្ឌ នីតិវិធីព្រហ្មទណ្ឌ ក្រមរដ្ឋប្បវេណី នីតិវិធីរដ្ឋប្បវេណី ច្បាប់ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃសាការី ច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃអាជ្ញាសាលា។ ច្បាប់ និងលិខិតបទដ្ឋានមួយចំនួនទៀត និងត្រូវបង្កើតដើម្បីបំពេញបន្ថែមទៅលើក្របខណ្ឌគតិយុត្តបច្ចុប្បន្ន។ ជាពិសេសរាជរដ្ឋាភិបាល និងរៀបចំឲ្យមានតុលាកាឯកទេសមួយតាមតម្រូវការចាំបាច់ មានជាអាទិ៍ តុលាការពាណិជ្ជកម្ម តុលាការអនីតិជន តុលាការការងារ តុលាការរដ្ឋបាល។

ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ដោយជម្រុញការអនុម័តច្បាប់ស្តីពី ការប្រយុទ្ធប្រឆាំងនិងអំពើពុករលួយ និងការបង្កើតស្ថាប័ន ឯករាជ្យ អព្យាក្រឹត្យមួយ សម្រាប់ប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ព្រមទាំងជម្រុញប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាពក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ពិសេសតាមរយៈការពង្រឹងការងារសវនកម្ម និងលទ្ធកម្មសាធារណៈក៏ដូចជា ជម្រុញអនុវត្តកំណែទម្រង់ដែលមានការពាក់ព័ន្ធគ្រប់វិស័យ ដើម្បីធានានូវអភិបាលកិច្ចល្អ។ ពិសេសការអនុវត្តន៍ផែនការសកម្មភាពអភិបាលកិច្ចរបស់រាជរដ្ឋាភិបាល ដែលត្រូវបានរៀបចំឡើងដោយមានការចូលរួមយ៉ាងទូលំទូលាយពីសំណាក់ ក្រសួង ស្ថាប័នរដ្ឋ សង្គមស៊ីវិល និងដៃគូរផ្តល់ជំនួយ។

កំណែទម្រង់កងកំលាំងប្រដាប់អាវុធ ដោយបន្តអនុវត្តគោលនយោបាយដែលបានលើកឡើងក្នុងសៀវភៅ ស របស់កងយោធពលខេមរភូមិន្ទ។ កំណែទម្រង់កងយោធពលខេមរភូមិន្ទ បង្កើតនូវប្រព័ន្ធគ្រប់គ្រងកងយោធពលខេមរភូមិន្ទ ប្រព័ន្ធបណ្តុះបណ្តាល និងកិច្ចសហប្រតិបត្តិការនៃវិស័យកងទ័ព។ រាជរដ្ឋាភិបាល និងជម្រុញអនុវត្តគោលនយោបាយកំណែទម្រង់នគរបាលជាតិ ដោយផ្តោតជាអទិភាពពិសេសទៅលើការរៀបចំឲ្យប្រើប្រាស់នូវប្រព័ន្ធបៀវត្សរបស់នគបាល និងកងទ័ពឲ្យមានភាពរលូនជាមួយប្រព័ន្ធបៀវត្សមន្ត្រីរាជការស៊ីវិល។

### ១.៦.២.អភិបាលកិច្ចល្អ ក្នុងក្របខណ្ឌច្បាប់ស្តីពីការគ្រប់គ្រងឃុំ សង្កាត់

ច្បាប់ស្តីពីការគ្រប់គ្រងឃុំ សង្កាត់មានគោលដៅកំណត់ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជា តាមនយោបាយវិមជ្ឈការ។ ឃុំសង្កាត់ជានីតិបុគ្គល។

រដ្ឋបាលឃុំសង្កាត់មានតួនាទីជម្រុញ និងគាំពារអភិបាលកិច្ចល្អ ដោយចាត់ចែងប្រើប្រាស់ធនធានដែលមានប្រកបដោយ ចីរភាពសម្រាប់សេចក្តីត្រូវការជាមូលដ្ឋានក្នុងឃុំសង្កាត់របស់ខ្លួន បម្រើផលប្រយោជន៍រួមរបស់ប្រជាពលរដ្ឋ និងគោរពផលប្រយោជន៍របស់ជាតិស្របតាមនយោបាយទូទៅរបស់រដ្ឋ។

ប្រព័ន្ធនៃអភិបាលកិច្ចមូលដ្ឋានត្រូវអនុវត្តនូវថ្នាក់ឃុំ សង្កាត់ ។ អំណាចដឹកនាំ និងគ្រប់គ្រងឃុំ សង្កាត់ បានមកដោយការបោះឆ្នោតជាទូទៅ ជាសកល ដោយសេរី និងយុត្តិធម៌ ដោយស្មើភាព ដោយចំពោះ ដោយសំងាត់ក្នុងក្របខណ្ឌនៃឃុំ សង្កាត់ នីមួយៗ។

រដ្ឋបាលឃុំ សង្កាត់មានតួនាទីពីរប្រភេទ គឺតួនាទីបម្រើការការងារមូលដ្ឋានសម្រាប់ផលប្រយោជន៍ ឃុំសង្កាត់ និងប្រជាពលរដ្ឋក្នុងឃុំសង្កាត់របស់ខ្លួន និងតួនាទីជាភ្នាក់ងារតំណាងរដ្ឋក្រោមការ ចាត់តាំង ឬការប្រគល់អំណាចរបស់អាជ្ញាធររដ្ឋ។ ឧទាហរណ៍ តួនាទីអភិវឌ្ឍន៍មូលដ្ឋាន ក្រុមប្រឹក្សាឃុំ សង្កាត់ រៀបផែនការអភិវឌ្ឍន៍ ដោយមានការចូលរួមពីសំណាក់អ្នកពាក់ព័ន្ធ ដូចជាប្រជាពលរដ្ឋ និងសង្គមស៊ីវិល ដើម្បីធានានូវអភិបាលកិច្ចនៃការគ្រប់គ្រងចាត់ចែងកិច្ចការមូលដ្ឋានប្រកបដោយប្រសិទ្ធភាពខ្ពស់តម្លាភាព និងការចូលរួម។

ឃុំ សង្កាត់ជាអង្គការតំណាងប្រជាពលរដ្ឋក្នុងឃុំ សង្កាត់របស់ខ្លួន និងមានបេសកកម្មបម្រើផលប្រយោជន៍ទូទៅក្នុងឃុំ សង្កាត់របស់ខ្លួន។ ក្រុមប្រឹក្សា ឃុំ សង្កាត់ ត្រូវមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋក្នុងឃុំ សង្កាត់ របស់ខ្លួន។

ក្រុមប្រឹក្សា ត្រូវមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាលចំពោះការប្រតិបត្តិច្បាប់ រដ្ឋធម្មនុញ្ញ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋាន។

### ១.៦.៣.អភិបាលកិច្ចក្នុងក្របខណ្ឌច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

#### ១.៦.៣.១.អំពីគោលការណ៍គ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវគ្រប់គ្រងតាមគោលការណ៍នៃរដ្ឋបាលឯកភាពដើម្បីបង្កើនជម្រុញ និងធ្វើឲ្យមានចីរភាពដល់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យ តាមរយៈនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ។

ការអភិវឌ្ឍន៍តាមបែបប្រជាធិតេយ្យ គឺជាបញ្ហាសំខាន់ក្នុងអភិបាលកិច្ចល្អ។ ការអភិវឌ្ឍន៍តាមបែបប្រជាធិតេយ្យ គឺជាការអភិវឌ្ឍន៍ ដែលមានដំណើរការដោយមានលក្ខណៈដូចខាងក្រោម៖

- ភាពជាអ្នកតំណាង (Public representation) ក្រុមប្រឹក្សាដែលត្រូវអនុវត្តការងារក្នុងនាម និងធ្វើជាអ្នកតំណាងឲ្យប្រជាពលរដ្ឋទាំងអស់នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។
- ស្វ័យភាពរបស់មូលដ្ឋាន(Local autonomy) ស្ថានភាពដែលក្រុមប្រឹក្សាអាចជាម្ចាស់ការចាត់ចែងគ្រប់គ្រងនូវ ការដែលបានប្រគល់ និងធ្វើប្រតិភូកម្មឲ្យដោយច្បាប់នេះប្រកបដោយប្រសិទ្ធភាព ។

- ការពិគ្រោះយោបល់ និងការចូលរួម(Consultation participate)ជាដំណើរការនៃការវិវត្តការងារ និងការធ្វើសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា ដែលក្រុមប្រឹក្សាត្រូវជួប និងពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋនៅមូលដ្ឋាន។
- លើកទឹកចិត្ត និងសម្របសម្រួល ឲ្យមានការចូលរួមរបស់ប្រជាពលរដ្ឋនៅក្នុងមូលដ្ឋាន នៅគ្រប់ផ្នែកទាំងអស់នៃអភិបាលកិច្ចដើម្បីស្វែងយល់ និងឆ្លើយតបតម្រូវការប្រជាពលរដ្ឋ។
- ឆ្លើយតប និងគណនេយ្យភាព ( Responsiveness and accountability) ក្នុងនាមជាតំណាងប្រជាពលរដ្ឋ ក្នុងមូលដ្ឋានក្រុមប្រឹក្សាត្រូវឆ្លើយតបទៅនឹងប្រជាពលរដ្ឋរបស់ខ្លួន ក្នុងការធ្វើគោលនយោបាយ សេចក្តីសម្រេចចិត្ត សកម្មភាព និងការបំពេញសកម្មភាពរបស់ខ្លួនប្រកបដោយ ការទទួលខុសត្រូវនូវអ្វីដែលខ្លួនបានអនុវត្ត។ ក្រុមប្រឹក្សាក៏ត្រូវទទួលខុសត្រូវផងដែរនូវ ចំពោះមុខរាជរដ្ឋាភិបាល ក្នុងការប្រតិបត្តិតាម រដ្ឋធម្មនុញ្ញ និងច្បាប់នានា។
- លើកកម្ពស់គុណភាពជីវិតរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន (Promotion of life quality of the local resident)សំដៅលើកិច្ចខំប្រឹងប្រែងដើម្បីបង្កើត និងធ្វើឲ្យមាននិរន្តរភាពនូវបរិយាកាសមួយប្រកបដោយសន្តិភាព សុវត្ថិភាព និងសុខមាលភាព។
- លើកកម្ពស់ជាសុខភាព និងគុណភាពជីវិតនៃប្រជាពលរដ្ឋក្នុងមូលដ្ឋាន។
- លើកកម្ពស់ការអភិវឌ្ឍន៍សង្គម និងសេដ្ឋកិច្ច
- លើកស្ទួយសមធម៌ (Promotion of Equity) ការគិតគូ និងយកចិត្តទុកដាក់ជាពិសេសទៅលើតម្រូវការខុសៗគ្នារបស់ស្ត្រី បុរស យុវជន និងកុមារព្រមទាំងតម្រូវការ ខុសៗគ្នារបស់ក្រុមងាយរងគ្រោះរាប់បញ្ចូលទាំងប្រជាពលរដ្ឋក្រីក្រ។
- តម្លាភាព និងសុច្ចរិតភាព(Transparency and Integrity) គឺជាការចាត់ចែង និងគ្រប់គ្រងកិច្ចការនានារាប់បញ្ចូលទាំងកិច្ចការហិរញ្ញវត្ថុ ដោយអនុលោមតាមបទដ្ឋានខ្ពស់បំផុតនៃសុច្ចរិតភាព និងច្បាប់ក្នុងលក្ខណៈបើកចំហរ តម្លាភាព ភាពចូលរួម ភាពឆ្លើយតប។
- វិធានការប្រឆាំង និងអំពើពុករលួយ និងការរំលោភអំណាច (Measure to fight Corruption and Abuse of Power) គឺជាការប្រកាន់យកនូវវិធាននៃច្បាប់ ព្រមទាំងការប្រឆាំង និងរាយការណ៍ពីអំពើពុករលួយ និងការរំលោភអំណាច។

រាជរដ្ឋាភិបាល គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងក្រុមប្រឹក្សាទាំងអស់នៅរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវសម្រេចឲ្យបាននូវគោលបំណងរួមក្នុងការបង្កើត ជម្រុញធ្វើឲ្យមានចីរភាពដល់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យ។[6]

**១.៦.៣.២.អំពីគណនេយ្យភាពរបស់ក្រុមប្រឹក្សា គណៈអភិបាល និងបុគ្គលិក**

**ក.គណនេយ្យភាពចំពោះប្រជាពលរដ្ឋ**

ក្រុមប្រឹក្សាត្រូវមានគណនេយ្យភាពចំពោះ ប្រជាពលរដ្ឋទាំងអស់អំពីជំរើសជាអាទិភាព ដើម្បីធ្វើសេចក្តីសម្រេច ធានាបានការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

ក្រុមប្រឹក្សា អាចធ្វើការអង្កេតលើករណីទាំងឡាយ ដែលខ្លួនយល់ឃើញថាមានសារៈសំខាន់ដល់ប្រជាពលរដ្ឋ ដែលជាតំណាង ព្រមទាំងអាចផ្សព្វផ្សាយលទ្ធផលនៃការធ្វើការអង្កេតនោះរួចហើយ ត្រូវផ្តល់គោលការណ៍ណែនាំដល់គណៈអភិបាល និងអភិបាល។

ក្រុមប្រឹក្សាត្រូវរៀបចំផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រអនុវត្តន៍ផែនការអភិវឌ្ឍន៍ ដើម្បីធានាឲ្យមានតម្លាភាព និងគណនេយ្យភាពចំពោះ ប្រជាពលរដ្ឋទាំងអស់នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

ក្រុមប្រឹក្សាត្រូវថា តើចែងកិច្ចការហិរញ្ញវត្ថុឲ្យមានតម្លាភាព និងមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋខ្លួន។

**ខ.គណនេយ្យភាពចំពោះរាជរដ្ឋាភិបាល**

ក្រុមប្រឹក្សាត្រូវមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាលចំពោះរាជរដ្ឋាភិបាលនូវការប្រតិបត្តិបត្តិតាមរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និង លិខិតបទដ្ឋាននានា។

ក្រុមប្រឹក្សាត្រូវគ្រប់គ្រងហិរញ្ញវត្ថុរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាពចំពោះប្រជាពលរដ្ឋរបស់ខ្លួន និងចំពោះរាជរដ្ឋាភិបាល។

**គ.ការទទួលខុសត្រូវ និងគណនេយ្យភាពចំពោះថ្នាក់ដឹកនាំ**

បុគ្គលិកទាំងអស់ត្រូវមានការទទួលខុសត្រូវ និងគណនេយ្យភាពដោយផ្ទាល់ចំពោះប្រធានគ្រប់គ្រងផ្ទាល់របស់ខ្លួន និងត្រូវមានការទទួលខុសត្រូវ និងគណនេយ្យភាពដោយប្រយោលចំពោះនាយករដ្ឋបាល អភិបាល គណៈអភិបាល និងក្រុមប្រឹក្សាតាមឋានានុក្រម។

**ឃ.គោលការណ៍ប្រតិបត្តិជាមូលដ្ឋានសម្រាប់មន្ត្រីរដ្ឋាភិបាល**

រាជរដ្ឋាភិបាលសម័យទំនើបមានការប្រតិបត្តិ ឬក្រមសីលធមិសម្រាប់មន្ត្រីរបស់ខ្លួន។ ក្រមទាំងនោះកំណត់ពីចរិយាត្រូវ និងខុស ហើយតម្រូវឲ្យមន្ត្រីទាំងនេះប្រកាន់នូវចរិយាល្អ។ ថ្នាក់លើត្រូវត្រួត

[6] អគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ "អភិបាលកិច្ចល្អ" ឆ្នាំ២០០៨ ទំព័រទី៥-១៤

ពិនិត្យលើមន្ត្រីរបស់ខ្លួនដើម្បីឲ្យដឹងច្បាស់ថាមន្ត្រីទាំងនោះគោរពតាមបទបញ្ជាទាំងនោះរឺទេ។ ការរំលោភទៅលើក្រមចរិយាធម៌ត្រូវទទួលទោសវិន័យដោយរួមបញ្ចូលទាំងការបណ្តេញចេញ ឬនៅក្នុងករណីធ្ងន់ធ្ងរជាច្រើនទៀតត្រូវប្តឹងចោទប្រកាន់ពីបទឧក្រិដ្ឋ។ នេះជាគោលការណ៍មូលដ្ឋានដ៏សំខាន់បំផុត ដែលគូសបញ្ជាក់ពីចរិយាសម្បត្តិរបស់មន្ត្រីមានន័យថា មន្ត្រីនីមួយៗធ្វើការក្នុងនាមប្រជាពលរដ្ឋ។ មន្ត្រីគ្រប់រូបត្រូវបានគេសង្ឃឹមថា និងធ្វើការយ៉ាងខ្លាំងក្លា និងការផ្តល់ការខិតខំយ៉ាងត្រឹមត្រូវចំពោះការងារ។ មន្ត្រីរដ្ឋាភិបាលត្រូវផ្តល់សេវានានា ដោយពុំមានការផ្តល់ភាពអនុគ្រោះពិសេសចំពោះ មិត្តភក្តិ ញាត្តិសន្តាន សមាជិករបស់គណបក្សណាមួយ ផលប្រយោជន៍ពាណិជ្ជកម្មពិសេស ឬ អ្វីផ្សេងទៀតឡើយ ហើយរដ្ឋាភិបាលជា រដ្ឋាភិបាលរបស់ប្រជាពលរដ្ឋគ្រប់រូបដោយឥតប្រកាន់បក្សពួក។ មន្ត្រីគ្រប់រូបត្រូវគោរពត្រូវតែប្រតិបត្តិតាម រដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យអនុក្រឹត្យ និងលិខិតបទដ្ឋាននៅគ្រប់កាលៈទេសៈ។ មន្ត្រីមិនត្រូវសម្រេចកិច្ចការនានាដោយបំពានដោយទំនើងចិត្ត ដោយផ្ទាល់ខ្លួន និងដោយរំលោភបំពានអំណាចឡើយ។ ប្រជាពលរដ្ឋដែលរដ្ឋាភិបាលអញ្ជើញឲ្យចូលមកធ្វើការប្រាស្រ័យទាក់ទង ត្រូវតែទទួលដោយការស្វាគមន៍ ការគួរសម និងភាពថ្លៃថ្នូរ។មន្ត្រីរដ្ឋាភិបាលមិនត្រូវយកការិយាល័យរបស់ខ្លួនដើម្បីទទួលសំណូក និងមិនត្រូវប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋ ដើម្បីផលប្រយោជន៍ខ្លួន ឬចូលរួមក្នុងការប្រព្រឹត្តិអំពើពុករលួយបែបណាមួយឡើយ។

# ជំពូកទី២

# ទិដ្ឋភាពទូទៅរបស់ខណ្ឌមានជ័យ និងមូលដ្ឋានគតិយុត្ត

## ២.១.ប្រវត្តិសង្ខេបរបស់ខណ្ឌមានជ័យ

យោងតាមរយៈការសិក្សាស្រាវជ្រាវ និងការសាកសួរដោយផ្ទាល់ពីមន្ត្រីចាស់ៗ ដែលបានចូលបម្រើការងារតាំងពីក្រោយថ្ងៃរំដោះ **០៧ មករា ១៩៧៩** បានឲ្យដឹងថា នៅថ្ងៃទី**១៧ មេសា ១៩៧៥** ប្រជាជនភ្នំពេញទាំងអស់បានព័ទ្ធ និងប្រមូលផ្តុំដោយខ្មែរក្រហម បង្ខំឲ្យជំលៀសចេញពីទីក្រុងទៅបង្កបង្កើនផលតាមជនបទ ។ រយៈពេល **៣ឆ្នាំ ៨ខែ ២០ថ្ងៃ** ទីក្រុងភ្នំពេញត្រូវបានគេបោះបង់ចោលដោយគ្មានការថែទាំ ឬជួសជុលការខូចខាតដោយសង្គ្រាមឡើយ ដែលក្នុងអំឡុងពេលនោះគេបានឲ្យឈ្មោះទីក្រុងភ្នំពេញជាទីក្រុងខ្មោច។ ក្រោយថ្ងៃរំដោះ ៧ មករា ១៩៧៩ ប្រជាជនបានចូលមករស់នៅតិចតួចបំផុតនៅតាមជាយក្រុង ដែលមកពីចំរុះខេត្ត ក្រុងនានា។ ដោយសារតែរបបកម្ពុជាប្រជាធិបតេយ្យបានបំផ្លិចបំផ្លាញគ្មានសល់ នៅពេលដែលប្រជាពលរដ្ឋចូលមករស់នៅមានជីវភាពលំបាកខ្លាំងណាស់ដូចជាបញ្ហា អគ្គីសនី ទឹកស្អាត សន្តិសុខសណ្តាប់ធ្នាប់ គឺគ្មានជីវភាពខ្វះខាត ខ្វះចំណីអាហារថ្នាំសង្កូវ មន្ទីរពេទ្យ សាលារៀនជាដើម។ ប៉ុន្តែចាប់ពីឆ្នាំ ១៩៨០ មក ជីវភាពនៅទីក្រុងក៏ចាប់ផ្តើមជាបណ្តើរៗឡើងវិញ។ក្រដាសប្រាក់រៀលថ្មីក៏បានត្រូវបោះពុម្ពឡើង ដោយមានប្រភេទជាកាក់ និងក្រដាសប្រាក់រៀលឲ្យចរាចរ ក្នុងខេត្ត ក្រុងនានាទូទាំងប្រទេស។ មធ្យោបាយធ្វើដំណើរនៅពេលនោះ គឺមានតែម៉ូតូកង់ឌុប ឬរ៉ឺម៉កធាក់ជើងតែប៉ុណ្ណោះ ទើបក្រោយមកមានរ៉ឺមក ម៉ូតូ ស៊ីក្លូ រថយន្ត។[7]

ដើមសត្សវត្សទី៨០ ហេដ្ឋារចនាសម្ព័ន្ធទីក្រុងភ្នំពេញ ត្រូវបានស្តារឡើងវិញតាមទីកន្លែងផ្សេងៗ ចំពោះការកសាងសមិទ្ធផលផ្សេងៗ គឺពុំមានលក្ខណៈធ្វើជាដុំកុំភួនទេ គឺរៀបចំស្តារនូវអ្វីដែលមានការខូចខាតកាលពីអំឡុងឆ្នាំ១៩៧៥ តែប៉ុណ្ណោះ។ ប្រជាជនមួយចំនួនបានធ្វើមាតុភូមិនិវត្តន៍មានគ្រប់សមាសភាពបាន ធ្វើការរស់នៅជាអចិន្ត្រៃយ៍នៅទីក្រុងភ្នំពេញជាងនេះទៅទៀត ក៏មានអ្នកនយោបាយរបស់គណបក្សនានា ដោយរួមទាំងកងកម្លាំងប្រដាប់អាវុធរបស់គេរួមជាមួយផង។ បន្តបន្ទាប់មកក្រុងភ្នំពេញកាន់តែមានសភាពស្មុកស្មាញឡើងៗ ហើយប្រជាពលរដ្ឋកាន់តែមានភាពស្មុកស្មាញឡើងឥតឈប់ឈរ រួមទាំងការធ្វើចំណាកស្រុក ភូមិ ដើម្បីមករស់នៅរកការងារធ្វើប្រកបរបរចិញ្ចឹមជីវិត ជាហេតុធ្វើឲ្យមានការលំបាកក្នុងការគ្រប់គ្រង បូករួមទាំងការខ្វះខាតខាងធនធានមនុស្ស និងធនធានហិរញ្ញវត្ថុក្នុងការស្តារ និងស្ថាបនាប្រទេសជាតិ។ មានន័យថាក្នុងអំឡុងពេលនេះ

[7] ហ៊ួត ហ៊ុយ របាយការណ៍បញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ "ការរៀបចំ និងការប្រព្រឹត្តទៅនៃសាលាខណ្ឌមានជ័យ" ទំព័រទី៤

ច្បាប់ និងបញ្ញាតិផ្សេងៗហាក់បីដូចជា គ្មានអ្នកណាខ្វល់ និងប្រតិបត្តិ។ ឯសណ្តាប់ធ្នាប់ក៏មានការសុាំញ៉ាំរញ៉េរញ៉ៃ ទោះបីជាពេលនោះសមត្ថកិច្ចខិតខំប្រឹងប្រែងគ្រប់បែបយ៉ាងក៏ដោយក៏ស្ថានការគ្មានការផ្លាស់ផ្តូរជាដុំកំភួនឡើយ។

ទឹកដីខណ្ឌមានជ័យត្រូវបាន បង្កើតឡើងដោយការច្របាច់បញ្ចូល ៤ គឺសង្កាត់ច្បារអំពៅ ស្ថិតនៅត្រើយខាងកើតទន្លេមេគង្គក្រោម និងសង្កាត់៣ទៀត ស្ថិតនៅត្រើយខាងលិច មានសង្កាត់ចាក់អង្រែ សង្កាត់បឹងទំពុន និងសង្កាត់ស្ទឹងមានជ័យ។

មកដល់ ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ ១៩៨៧ ទីតាំងនេះ ត្រូវបានបង្កើតឲ្យទៅជាស្រុក គឺស្រុកមានជ័យ មានឃុំចំនួន ៨ ចំណុះ គឺ

- ឃុំនិរោធ
- ឃុំច្បារអំពៅទី១
- ឃុំច្បារអំពៅទី១
- ឃុំព្រែកប្រា
- ឃុំចាក់អង្រែលើ
- ឃុំចាក់អង្រែក្រោម
- ឃុំបឹងទំពុន
- ឃុំស្ទឹងមានជ័យ ស្ថិតនៅជាយក្រុងភ្នំពេញ។

បើយោងតាមព្រះរាជក្រឹត្យលេខ នស/រកត/០៩១០/៧៦៣ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១០ ស្តីពី ការកែសម្រួលព្រំប្រទល់រដ្ឋបាលរវាងរាជធានីភ្នំពេញ និងខេត្តកណ្តាល ដោយបានកាត់យកឃុំចំនួន ២០នៃខេត្តកណ្តាល មកបញ្ចូលក្នុងរាជធានីភ្នំពេញ ដោយក្នុងនោះឃុំមួយចំនួនត្រូវបានកាត់ចូលក្នុងខណ្ឌមានជ័យផងដែរ រួមមាន៖ ឃុំវាលស្បូវ ឃុំព្រែកឯង ឃុំក្បាលកោះ និង ឃុំព្រែកថ្មី។[8]

ក៏ប៉ុន្តែនៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៣ រាជរដ្ឋាភិបាល បានចេញអនុក្រឹត្យ ស្តីពី ការបង្កើតខណ្ឌច្បារអំពៅ នៃរាជធានីភ្នំពេញ ដោយកាត់យកសង្កាត់ចំនួន ៨ ពីខណ្ឌមានជ័យ រួមមាន៖ សង្កាតអំពៅទី១ សង្កាត់ច្បារអំពៅទី២ សង្កាត់និរោធ សង្កាត់ព្រែកប្រា សង្កាត់វាលស្បូវ សង្កាត់ព្រែកឯង សង្កាត់ក្បាលកោះ និងសង្កាត់ព្រែកថ្មី។[9]

[8] ព្រះរាជក្រឹត្យលេខ នស/រកត/០៩១០/៧៦៣ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១០ ស្តីពី ការកែសម្រួលព្រំប្រទល់រដ្ឋបាលរវាងរាជធានីភ្នំពេញ និងខេត្តកណ្តាល

[9] អនុក្រឹត្យ ស្តីពី ការបង្កើតខណ្ឌច្បារអំពៅ នៃរាជធានីភ្នំពេញ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៣

សរុបជារួមមក បច្ចុប្បន្ន ខណ្ឌមានជ័យ ត្រូវនៅសល់ចំនួន **៤សង្កាត់** គឺ

- សង្កាត់ចាក់អង្រែលើ
- សង្កាត់ចាក់អង្រែក្រោម
- សង្កាត់បឹងទំពុន
- សង្កាត់ស្ទឹងមានជ័យ

## ២.២.ស្ថានភាពទូទៅរបស់ខណ្ឌមានជ័យ

ខណ្ឌមានជ័យ គឺជាបណ្តុំនៃការរស់នៅរបស់ប្រជាពលរដ្ឋគ្រប់ស្រទាប់វណ្ណៈ ដោយក្នុងនោះរួមមានកសិករឧស្សាហកម្ម អាជីវកម្ម ពាណិជ្ជកម្ម ប្រមាណជា ៦០% មន្ត្រីរាជការ ទាហាន នគរបាល ប្រមាណ ៣០% និងព្រះសង្ឃ កម្មករប្រមាណ១០%។

## ២.៣.ទីតាំងភូមិសាស្ត្រ

ខណ្ឌមានជ័យ មានទីតាំងស្ថិតនៅប៉ែកខាងត្បូងឈៀងខាងកើតរាជធានីភ្នំពេញ មានផ្ទៃក្រឡាសរុប ១១.១០៨.៤ ហិចតា ស្មើនឹង ១១១.១៨៤ គីឡូម៉ែត្រក្រឡាដែលមានព្រំប្រទល់ជាប់៖

- ខាងកើតទល់នឹង : ស្រុកកៀនស្វាយ និងស្រុកល្វាឯម ខេត្តកណ្តាល
- ខាងលិចទល់នឹង : ខណ្ឌដង្កោ រាជធានីភ្នំពេញ
- ខាងត្បូងទល់នឹង : ស្រុកតាខ្មៅ ខេត្តកណ្តាល
- ខាងជើងទល់នឹង :ខណ្ឌចំការមន ខណ្ឌទួលគោក និងខណ្ឌសែនសុខ រាជធានីភ្នំពេញ។

## ២.៤.អំពីប្រជាសាស្ត្រ

ស្ថិតិប្រជាពលរដ្ឋក្នុងខណ្ឌមានជ័យ សរុបមានចំនួន ៥១.៩៣៩គ្រួសារ មនុស្សចំនួន ២៨២.០០៨នាក់ ស្រី ១៥២.០៩១ នាក់ ក្នុងនោះអាយុ ១៨ ឆ្នាំឡើង ចំនួន ២០៩.១៤៦នាក់ ស្រី ១១៣.០៤៩ នាក់ ចែកជា ១២ សង្កាត់ មាន ៨៣ ភូមិ។

## ២.៥.អំពីរចនាសម្ព័ន្ធដឹកនាំ

អនុលោមតាមប្រកាសលេខ ៣៤៨ ប្រក ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០០០ របស់ក្រសួងមហាផ្ទៃ ស្តីពីតួនាទីភារកិច្ច របៀបរបបការងារ និងរចនាសម្ព័ន្ធ នៃសាលាស្រុក-ខណ្ឌ បានចែងថា ខណ្ឌ-ស្រុក នីមួយៗត្រូវដឹកនាំដល់អភិបាលស្រុក-ខណ្ឌ ០១រូប អមដោយអភិបាលរង ស្រុក-ខណ្ឌ ០៣ រូប ជាជំនួយការប៉ុន្តែ ដោយសារទីក្រុងភ្នំពេញ ជារាជធានីនៃព្រះរាជាណាចក្រកម្ពុជា តាមរយៈក្រសួងមហាផ្ទៃ បានបន្ថែមអភិបាលរងខណ្ឌមួយចំនួនទៀតឲ្យទៅបំពេញកាងារនៅតាមសាលាខណ្ឌទាំង៧ របស់ក្រុងភ្នំពេញ។ ដោយឡែកខណ្ឌមានជ័យ មានអភិបាល ០១ រូប អមដោយអភិបាលរងចំនួន ១១ រូប។[10]

[10] ប្រកាសលេខ ៣៤៨ ប្រក ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០០០ របស់ក្រសួងមហាផ្ទៃ ស្តីពីតួនាទីភារកិច្ច របៀបរបបការងារ និងរចនាសម្ព័ន្ធ នៃសាលាស្រុក-ខណ្ឌ

អភិបាលខណ្ឌទទួលខុសត្រូវរួមលើកិច្ចការរដ្ឋបាលដែនដី និងទទួលបន្ទុកផ្ទាល់លើកិច្ចការសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈក្នុងខណ្ឌរបស់ខ្លួន។ ចំណែកអភិបាលរងខណ្ឌ០១រូប ទទួលបន្ទុកការងារ រដ្ឋបាលទូទៅ ០១រូប ទទួលបន្ទុកការងារសង្គមកិច្ច និង០១រូបទៀត ទទួលការងារសេដ្ឋកិច្ច និងទទួលភារកិច្ចផ្សេងៗទៀត តាមកាប្រគល់ភារកិច្ចរបស់អភិបាលខណ្ឌ ។ ម្យ៉ាងទៀតសាលាខណ្ឌត្រូវគ្រប់គ្រងដោយប្រធាន ០១រូប ហៅថាប្រធានមន្ទីរខណ្ឌ អមដោយអនុប្រធាន០១រូប ជាជំនួយការ។ ប្រធានមន្ទីរខណ្ឌ ត្រូវបំពេញការងារក្រោមការដឹកនាំអភិបាលរងខណ្ឌ ក្នុងការដឹកនាំ សំរបសំរួលការងាររបស់នានាចំណុះសាលាខណ្ឌ។ អនុប្រធានមន្ទីរមានភារកិច្ច ជំនួយការឲ្យប្រធានមន្ទីរខណ្ឌអនុវត្តការងារតាមការប្រគល់ភារកិច្ចរបស់ប្រធានមន្ទីរខណ្ឌ និងជំនួសប្រធានមន្ទីរខណ្ឌពេលអវត្តមាន។ សាលាខណ្ឌមានការិយាល័យចំណុះ០៣ គឺការិយាល័យរដ្ឋបាលទូទៅ ការិយាល័យសង្គមកិច្ច និងការិយាល័យសេដ្ឋកិច្ច។ ការិយាល័យចំណុះសាលាខណ្ឌនីមួយៗ ដឹកនាំដោយប្រធានការិយាល័យ ០១ រូបអមដោយអនុប្រធានការិយាល័យ ០១ រូបជាជំនួយការ។

**តារាងទី២៖** រចនាសម្ព័ន្ធរដ្ឋបាលខណ្ឌ

## រចនាសម្ព័ន្ធរដ្ឋបាលខណ្ឌ




*__ប្រភព__៖ ក្រសួងមហាផ្ទៃ សៀវភៅណែនាំ "ការិយាល័យច្រកចេញចូលតែមួយ" ឆ្នាំ២០១១*

## ២.៦.អំពីតួនាទី និង ភារកិច្ច

នៅក្នុងរចនាសម្ព័ន្ធនៃរដ្ឋបាលខណ្ឌមានជ័យ ត្រូវបានបង្កើតឲ្យមាននូវក្រុមប្រឹក្សា និង គណៈអភិបាល ។ ក្រុមប្រឹក្សាខណ្ឌត្រូវបានបង្កើតឡើងដោយការបោះឆ្នោត។ ពួកគេជាអ្នកតំណាងសាធារណៈជាអ្នកការពារ និងជាអ្នកបម្រើឲ្យផលប្រយោជន៍ឲ្យប្រជាពលរដ្ឋទាំងអស់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

### ២.៦.១.សិទ្ធិអំណាចរបស់ក្រុមប្រឹក្សាខណ្ឌ

រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវមានក្រុមប្រឹក្សារបស់ខ្លួន ដែលត្រូវបានជ្រើសរើសឡើងតាមការបោះឆ្នោតអសកលរបស់តាមនីតិវិធីដែល កំណត់ក្នុងច្បាប់ស្តីពី ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលហៅកាត់ថា **ក្រុមប្រឹក្សា**។[11] ក្រុមប្រឹក្សាមានអាណត្តិប្រាំឆ្នាំ(០៥ឆ្នាំ) ហើយត្រូវផុតកំណត់នៅពេលក្រុមប្រឹក្សាថ្មីចូលកាន់តំណែង។ អាណត្តិរបស់ក្រុមប្រឹក្សាត្រូវគិតចាប់ពីថ្ងៃបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា និងផុតកំណត់នៅថ្ងៃបោះឆ្នោតបន្ទាប់។[12]

ក្រុមប្រឹក្សាខណ្ឌមានសិទ្ធិអំណាចពីរគឺៈ

- សិទ្ធិអំណាចធ្វើសេចក្តីសម្រេចខាងបញ្ញាត្តិ
- សិទ្ធិអំណាចធ្វើសេចក្តីសម្រេចខាងប្រតិបត្តិ

ប្រធានក្រុមប្រឹក្សាខណ្ឌក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន មានសិទ្ធិចុះហត្ថលេខា និងប្រថាប់ត្រារដ្ឋបាលខណ្ឌលើៈ

- ដីកា ឬសេចក្តីសម្រេចដែលក្រុមប្រឹក្សាខណ្ឌបានអនុម័តរួច
- សេចក្តីសម្រេចបង្កើតគណៈកម្មាធិការ ឬ អនុគណៈកម្មាធិការ ឬ ក្រុមការងារ តាមការសម្រេចរបស់អង្គប្រជុំក្រុមប្រឹក្សាខណ្ឌ
- កំណត់ហេតុប្រជុំដែលអង្គប្រជុំក្រុមប្រឹក្សាខណ្ឌបានអនុម័ត
- សំណើរដេកហូត អភិបាលខណ្ឌ ឬអភិបាលរងខណ្ឌចេញពីមុខដំណែងតាមការប្រជុំរបស់ក្រុមប្រឹក្សាខណ្ឌ
- លិខិតអញ្ជើញប្រជុំក្រុមប្រឹក្សាខណ្ឌ
- ប្រតិទិនកិច្ចប្រជុំសាមញ្ញ របស់ក្រុមប្រឹក្សាខណ្ឌសម្រាប់រយៈពេល១២ខែ
- សំណើរសុំផ្លាស់ប្តូរសមាជិកក្រុមប្រឹក្សាខណ្ឌ

---

[11] មាត្រា ៨ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឆ្នាំ២០០៨

[12] មាត្រា ១៥ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឆ្នាំ២០០៨

- កិច្ចការដទៃទៀតតម្រូវដោយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា។
- គណៈអភិបាលខណ្ឌ ត្រូវជួបក្រុមប្រឹក្សាខណ្ឌរបស់ខ្លួនក្នុងការរៀបចំឯកសាខាងលើនេះ លើកលែងតែឯកសារសម្រាប់រៀបចំកិច្ចប្រជុំទាក់ទងនិងសំណើរដកហូតអភិបាលខណ្ឌ ឬ អភិបាលរងខណ្ឌចេញពីមុខតំណែង។[13]

## ២.៦.២.តួនាទីរបស់គណៈអភិបាលខណ្ឌ

ខណ្ឌនីមួយៗត្រូវមានគណៈអភិបាលខណ្ឌមួយ ដែលរួមមានអភិបាលខណ្ឌ និងអភិបាលរងខណ្ឌមួយចំនួន ដែលត្រូវបានតែងតាំងឡើងស្របតាមលក្ខខណ្ឌនៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។ អភិបាលខណ្ឌ និងអភិបាលខណ្ឌរងមិនមែនជាសមាជិកក្រុមប្រឹក្សាខណ្ឌឡើយ។

គណៈអភិបាលខណ្ឌមានតួនាទី និង ភារកិច្ចដូចជា៖

- គណៈអភិបាលខណ្ឌត្រូវធ្វើការសិក្សាស្រាវជ្រាវ ដើម្បីផ្តល់យោបល់ជូនក្រុមប្រឹក្សាខណ្ឌ អំពីកិច្ចការនានា ដែលពាក់ព័ន្ធនិងអំណាចបញ្ញត្តិ និងអំណាចប្រតិបត្តរបស់ក្រុមប្រឹក្សាខណ្ឌ ដើម្បីឲ្យក្រុមប្រឹក្សាខណ្ឌធ្វើការពិភាក្សា និងក្នុងការអនុម័តក្នុងកិច្ចប្រជុំសាមញ្ញ ឬ វិសាមញ្ញ។
- ការពិនិត្យមុខងារ ភារកិច្ច និងធនធានទាំងអស់ដែលបានធ្វើប្រតិភូកម្មមកឲ្យក្រុមប្រឹក្សាខណ្ឌ និងរបៀបរបប បែបបទ នីតិវិធីនៃការអនុវត្តន៍មុខងារ ភារកិច្ច និងការចាត់ចែងធនធានទាំងនោះ។
- ការរៀបចំយុទ្ធសាស្ត្រ និងការរៀបចំរចនាសម្ព័ន្ធ ប្រព័ន្ធ និងធនធាន ដើម្បីទទួលយកមុខងារ ភារកិច្ច និងធនធាន ដែលបានធ្វើប្រតិភូកម្មពីរដ្ឋបាលរាជធានីស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ផែនការអនុវត្តន៍រយៈពេល៥ឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលប្រចាំឆ្នាំ ដើម្បីដាក់បញ្ចូលទៅក្នុងផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលប្រចាំឆ្នាំរបស់រាជធានី
- ក្របខណ្ឌចំណាយរយៈពេលមធ្យម និងការធ្វើបច្ចុប្បន្នភាព
- ការងារហិរញ្ញវត្ថុ ថវិកា និងទ្រព្យសម្បត្តិរបស់ខណ្ឌ
- ការបង្កើត ការកែសម្រួល ឬការរំសាយការិយាល័យនានា

[13] មាត្រា ៣០ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឆ្នាំ២០០៨

- ការងារបុគ្គលិក និងក្របខណ្ឌ
- ការរៀបចំតួនាទី ភារកិច្ច និងលក្ខខណ្ឌការងាររបស់បុគ្គលិក
- ការកំណត់នីតិវិធីរដ្ឋបាល និងហិរញ្ញវត្ថុសម្រាប់ការិយាល័យ និងបុគ្គលិករបស់ក្រុមប្រឹក្សាខណ្ឌ
- ការកំណត់យុទ្ធសាស្ត្រ ដើម្បីអភិវឌ្ឍន៍សមត្ថភាពដល់ក្រុមប្រឹក្សាខណ្ឌ គណៈអភិបាលខណ្ឌ និងបុគ្គលិករបស់ក្រុមប្រឹក្សាខណ្ឌ
- ការរៀបចំរបាយការណ៍ប្រចាំឆ្នាំ ដាក់ជូនក្រុមប្រឹក្សាខណ្ឌពិនិត្យ និងអនុម័តមិនឲ្យលើសពី ៩៥ ថ្ងៃ បន្ទាប់ពីដំណាច់ឆ្នាំនីមួយៗដែលពាក់ពន្ធ័នឹងៈ
  - ដីកា និងសេចក្តីសម្រេចនានាដែលបានដាក់ចេញដោយក្រុមប្រឹក្សាខណ្ឌ និងសកម្មភាពលទ្ធផលនៃការអនុវត្តន៍
  - បញ្ហាហិរញ្ញវត្ថុ និងថវិកា
  - ការវាយតម្លៃអំពីការបំពេញការងាររបស់គណៈអភិបាលខណ្ឌ និងបុគ្គលិករបស់ក្រុមប្រឹក្សាខណ្ឌ
  - វិធានការចាំបាច់ ដើម្បីធ្វើឲ្យប្រសើរឡើងនូវការអនុវត្តន៍ការងាររបស់ក្រុមប្រឹក្សាខណ្ឌ
  - វិធានការចាំបាច់ដើម្បីលើកកម្ពស់សមភាពយេនឌ័រ
  - កិច្ចការផ្សេងៗទៀត និងក្រុមប្រឹក្សាខណ្ឌយល់ឃើញថាចាំបាច់ ត្រូវដាក់បញ្ចូលក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់ខ្លួន
- របាយការណ៍ប្រចាំខែ ត្រីមាស និងឆមាស
- ការបង្កើតគណៈកម្មាធិការ ឬ អនុគណៈកម្មធិការ ឬក្រុមការងារនានា តាមការចាំបាច់ដើម្បីជួយដល់ការអនុវត្តន៍ការងាររបស់ក្រុមប្រឹក្សាខណ្ឌ
- ការរៀបចំយុទ្ធសាស្ត្រផ្សព្វផ្សាយព័ត៌មានដល់សាធារណជន ដូចជាការរៀបចំក្តារព័ត៌មាន ការបិទផ្សាយពត៌មាននៅលើក្តារព័ត៌មាន និងការស្វះស្វែងរកមធ្យោបាយស្វះស្វែងរកព័ត៌មានក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- កិច្ចការផ្សេងៗទៀត ដែលកំណត់ដោយច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា និងដែលតម្រូវឲ្យក្រុមប្រឹក្សាខណ្ឌរបស់ខ្លួន
- នៅពេលបានទទួលរបាយការណ៍ ឬព័ត៌មានការរំលោភអំណាច គណៈអភិបាលខណ្ឌត្រូវធ្វើការស៊ើបអង្កេតជាបន្ទាន់។ ប្រសិនបើរកឃើញថាមានការរំលោភអំណាចពិត

ប្រាកដមែន គណៈអភិបាលខណ្ឌ ត្រូវធ្វើសេចក្តីរាយការណ៍ជាបន្ទាន់ទៅក្រុមប្រឹក្សាខណ្ឌ និងធ្វើសេចក្តីរាយការណ៍ជូនក្រុមប្រឹក្សារាជធានី។[14]

## ២.៦.៣.តួនាទីរបស់អភិបាលខណ្ឌ

អភិបាលខណ្ឌមានតួនាទីជាតំណាងក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាលក្នុងខណ្ឌ។ ក្នុងតួនាទីជាតំណាងក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាលអភិបាលខណ្ឌត្រូវៈ

- ថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ លើកកម្ពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋក្នុងខណ្ឌអំពីច្បាប់ និងធនធានឲ្យមានការអនុវត្តន៍ច្បាប់ ព្រមទាំងធនធានឲ្យមានការការពារ និងគោរពសិទ្ធិមនុស្សចំពោះប្រជាពលរដ្ឋទាំងអស់នៅក្នុងខណ្ឌ
- ធ្វើជាប្រធានគណៈបញ្ជាការឯកភាពខណ្ឌ ក្នុងការដឹកនាំ សម្របសម្រួលការិយាល័យ អង្គភាពពាក់ពន្ធ័នានា និងសង្កាត់នៅក្នុងខណ្ឌ ដើម្បីធានារក្សាសន្តិសុខសណ្តាប់ធ្នាប់ និង របៀបរៀបរយសាធារណៈនៅក្នុងខណ្ឌ
- ណែនាំដល់ការិយាល័យ អង្គភាព និងទីភ្នាក់ងារនានារបស់ក្រសួង ស្ថាប័នដែលប្រចាំនៅក្នុងខណ្ឌឲ្យអនុវត្តនូវ តួនាទីភារកិច្ចរបស់ខ្លួន ឲ្យបានត្រឹមត្រូវស្របតាមច្បាប់គោលនយោបាយជាតិ និងលិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធ និងការិយាល័យ អង្គភាព និងទីភ្នាក់ងារនីមួយៗ។
- សម្របសម្រួល និងតម្រង់ទិសដៅដល់ការិយាល័យ អង្គភាព និងទីភ្នាក់ងាររបស់ក្រសួងស្ថាប័ននានា ដែលប្រចាំកានៅខណ្ឌដើម្បី ឆ្លើយតបនូវតម្រូវការជាអទិភាពរបស់មូលដ្ឋាន។ ក្នុងករណីកិច្ចការទាំងឡាយណាដែលមានការពាក់ព័ន្ធច្រើនវិស័យអភិបាលខណ្ឌត្រូវសម្របសម្រួលការិយាល័យ អង្គភាពទីភ្នាក់ងារពាក់ព័ន្ធដើម្បី សហការគ្នាអនុវត្តន៍កិច្ចការទាំងនោះ ដោយផ្អែកតាមគោលការណ៍ រាជរដ្ឋាភិបាល ច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា និងតម្រូវការអាទិភាពរបស់មូលដ្ឋាន។ តាមរយៈគណៈកម្មាធិការសម្របសម្រួលតម្រង់ទិសការិយាល័យ អង្គភាព និងទីភ្នាក់ងារនានារបស់ក្រសួង ស្ថាប័ន ដែលប្រចាំការនៅខណ្ឌក្នុងសមាហរណកម្មផែនការ និងថវិការបស់ខ្លួន ដើម្បើឆ្លើយតបទៅនិងតម្រូវការជាអទិភាពរបស់ខណ្ឌ។
- ពិនិត្យ វាយតម្លៃ ផ្តល់មូលវិចារណ៍ និងដាក់ពិន្ទុប្រធានការិយាល័យ អង្គភាពនៃក្រសួងស្ថាប័ននានាដែលប្រចាំនៅក្នុងខណ្ឌ

[14] ហៀង សាង "សមត្ថ និងរបៀបរបបការងារនៅរដ្ឋបាលថ្នាក់ក្រោមជាតិ" បោះពុម្ពឆ្នាំ២០១១ ទំព័រទី៣១១

- ពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាខណ្ឌជាមុន ក្នុងការផ្តល់យោបល់ទៅលើបេក្ខភាពដែលស្នើរតែងតាំងជាប្រធានការិយាល័យ អង្គភាពនៃក្រសួងស្ថាប័ននានាប្រចាំនៅខណ្ឌរបស់ខ្លួន។ ក្នុងករណីមិនគាំទ្របេក្ខភាពដែលស្នើរតែងតាំងខាងលើនេះ អភិបាលខណ្ឌត្រូវរាយការណ៍ជាលាយលក្ខណ៍អក្សរ ដោយបញ្ជាក់ពីមូលហេតុនៃការមិនគាំទ្រនេះជូនអភិបាលរាជធានី ដើម្បីឲ្យអភិបាលរាជធានីធ្វើការសម្របសម្រួលជាមួយប្រធានមន្ទីរអង្គភាពសាមីជាមុន មុននឹងធ្វើសេចក្តីរាយការណ៍ជូនរដ្ឋមន្ត្រី ឬប្រធានស្ថាប័នសាមី។
- រាយការណ៍ជាលាយលក្ខណ៍អក្ស និងជាបន្ទាន់ទៅអភិបាលរាជធានីក្នុងករណីពិនិត្យមើលឃើញភាពមិនប្រក្រតីដែលកើតមានក្នុងការិយាល័យ អង្គភាព ឬទីភ្នាក់ងារណាមួយរបស់ក្រសួងស្ថាប័ន ដែលប្រចាំនៅក្នុងខណ្ឌរបស់ខ្លួន ក្នុងករណីប្រធានការិយាល័យប្រធានអង្គភាព និងអ្នកទទួលខុសត្រូវនៃការិយាល័យអង្គភាព បានប្រព្រឹត្តខុសឆ្គងពីតួនាទីភារកិច្ចរបស់ខ្លួន ។ អភិបាលរាជធានី ត្រូវណែនាំដល់មន្ទីរ អង្គភាពខ្សែបណ្តោយសាមី នៅថ្នាក់រាជធានី ដើម្បីស្រាវជ្រាវអំពីបញ្ហានេះ ឬអាចចាត់តាំងគណៈកម្មាធិកា ឬក្រុមការងារ ដែលមានការចូលរួមពីរដ្ឋបាលខណ្ឌពាក់ព័ន្ធឲ្យធ្វើការស៊ើបអង្កេតលើករណីនេះជាបន្ទាន់ ដើម្បីធ្វើសេចក្តីរាយការណ៍ជូនរដ្ឋមន្ត្រី ឬប្រធានស្ថាប័នសាមី
- មានសិទ្ធិស្នើរជាលាយលក្ខណ៍អក្សទៅអភិបាលរាជធានី ដើម្បីចាត់វិធានការផ្លាស់ប្តូរ ឬដកហូតពីមុខតំណែងនូវប្រធានការិយាល័យ ឬប្រធានអង្គភាព ឬអ្នកទទួលខុសត្រូវនៃទីភ្នាក់ងារណាមួយរបស់ក្រសួងស្ថាប័នដែលប្រព្រឹត្តខុសច្បាប់ ។

ជាការពិតណាស់ដែលអាចនិយាយបានថា សង្កាត់ជាសេនាធិការរបស់ខណ្ឌ គឺរដ្ឋបាលខណ្ឌនិងរដ្ឋបាលរាជធានីមានទំនាក់ទំនងគ្នាយ៉ាងស្អិតរមួត ក្នុងការទំនាក់ទំនងការងាររដ្ឋបាលនេះ ដែលក្នុងទំនាក់ទំនងនេះមានដូចជា៖

- ក្រុមប្រឹក្សាខណ្ឌត្រូវរៀបចំឲ្យមានការពិគ្រោះយោបល់សមស្របជាមួយក្រុមប្រឹក្សាសង្កាត់ដើម្បី៖
  - ធ្វើការសម្របសម្រួលឲ្យមានកិច្ចសហប្រតិបត្តិការក្នុងចំណោមសង្កាត់នានា ក្នុងខណ្ឌដើម្បីលើកកម្ពស់ការឆ្លើយតបនូវតម្រូវការរបស់ប្រជាពលរដ្ឋ
  - ប្រមូលផ្តុំសេចក្តីត្រូវការនានារបស់ប្រជាពលរដ្ឋ ដែលបានលើកឡើងដោយក្រុមប្រឹក្សាសង្កាត់ ហើយដែលក្រុមប្រឹក្សាសង្កាត់មិនអាចឆ្លើយតបបានដើម្បីពិគ្រោះពិភាក្សាជាមួយក្រុមប្រឹក្សាសង្កាត់ពាក់ព័ន្ធខិតខំឆ្លើយតាមតម្រូវការទាំងនោះ

- គាំទ្រសមត្ថភាពចាំបាច់ដល់ក្រុមប្រឹក្សាសង្កាត់ ដើម្បីឲ្យក្រុមប្រឹក្សាសង្កាត់ក្នុងខណ្ឌមានសមត្ថភាពទទួលបាននូវមុខងារ និងភារកិច្ចដែលត្រូវធ្វើប្រតិភូកម្មកាន់តែច្រើនថែមទៀតពីក្រុមប្រឹក្សារាជធានី សំដៅឆ្លើយតបតម្រូវការរបស់ប្រជាពលរដ្ឋ។

– ដើម្បីធានាឲ្យក្រុមប្រឹក្សាខណ្ឌ លើកកម្ពស់ក្នុងការបង្កើត និងការជម្រុញនិងការធ្វើឲ្យមានចីរភាពដល់ ការអភិវឌ្ឍន៍តាមបែបប្រជាធិតេយ្យ ក្រុមប្រឹក្សាសង្កាត់ត្រូវទទួលខុសត្រូវ

- ក្នុងការផ្តល់យោបល់ និងការពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាខណ្ឌ ដើម្បីធានាថា ក្រុមប្រឹក្សាខណ្ឌនៅតែឆ្លើយតបទៅ និងសេចក្តីត្រូវការរបស់ ប្រជាពលរដ្ឋ និងមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋទាំងអស់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ផ្តល់អនុសាសន៍ដល់ក្រុមប្រឹក្សាខណ្ឌ អំពីតម្រូវការនានារបស់ប្រជាពលរដ្ឋដែលក្រុមប្រឹក្សាសង្កាត់មិនអាចដោះស្រាយបានដោយសមត្ថភាព និងធនធានដែលខ្លួនមាន
- ធ្វើសហប្រតិបត្តិការឲ្យបានពេញលេញជាមួយក្រុមប្រឹក្សាខណ្ឌ ក្នុងការលើកកម្ពស់ការផ្តល់សេវា និងការអភិវឌ្ឍន៍ក្នុងមូលដ្ឋាន

– ក្រុមប្រឹក្សាខណ្ឌនីមួយៗត្រូវសម្របសម្រួល និងធ្វើកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយក្រុមប្រឹក្សាសង្កាត់ និងសហគមន៍ ប្រជាពលរដ្ឋក្នុងខណ្ឌរបស់ខ្លួនដើម្បីកំណត់ជាអាទិភាពក្នុងការផ្តល់សេវា ការអភិវឌ្ឍន៍ និងសំណើរ ឬសំណូមពរនានារបស់ប្រជាពលរដ្ឋក្នុងខណ្ឌរបស់ខ្លួន ដើម្បីដាក់បញ្ជូនក្នុងផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ និង កម្មវិធីវិនិយោគបីឆ្នាំរំកិលប្រចាំឆ្នាំរបស់រាជធានី

– ក្រុមប្រឹក្សាត្រូវធ្វើការគាំទ្រ ដល់ក្រុមប្រឹក្សាសង្កាត់ ដើម្បីធានាថាក្រុមប្រឹក្សាសង្កាត់អនុវត្តន៍នូវមុខងារ និងភារកិច្ចក្នុងក្របខ័ណ្ឌនៃអំណាច ដែលបានធ្វើប្រតិភូកម្មឲ្យលើមូលដ្ឋាននៃការគោរពរដ្ឋធម្មនុញ្ញ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា ហើយត្រូវធានាថាក្រុមប្រឹក្សាសង្កាត់បានអនុវត្តមុខងារ និងភារកិច្ចនេះក្នុងការឆ្លើយតបបានយ៉ាងប្រសើរបំផុត នូវសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ។

### ២.៦.៤.ទំនាក់ទំនងរវាងក្រុមប្រឹក្សា និងគណៈអភិបាលខណ្ឌ

ទំនាក់ទំនងរវាងក្រុមប្រឹក្សាខណ្ឌ និងគណៈអភិបាលខណ្ឌមានដូចជា៖

– អំណាចបញ្ញាតិ និងអំណាចប្រតិបត្តិទាំងអស់ដែលក្រុមប្រឹក្សាខណ្ឌបានសម្រេចគណៈ-អភិបាលត្រូវទទួលខុសត្រូវអនុវត្តន៍ក្នុងនាម ក្រុមប្រឹក្សាខណ្ឌរបស់ខ្លួន។ ដូច្នេះគណៈ-

អភិបាលខណ្ឌ គឺជាអ្នកអនុវត្តន៍ទាំងសេចក្តីសម្រេចខាងបញ្ញត្តិ និងខាងប្រតិបត្តិរបស់ក្រុមប្រឹក្សាខណ្ឌ

- គណៈអភិបាលខណ្ឌត្រូវមាន គណនេយ្យភាពចំពោះក្រុមប្រឹក្សាខណ្ឌរបស់ខ្លួនអំពីការអនុវត្តន៍សេចក្តីសម្រេចនានារបស់ក្រុមប្រឹក្សាខណ្ឌ និងមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាលអំពីការអនុវត្តន៍តាមរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋាននានាគណៈអភិបាលខណ្ឌ ត្រូវធ្វើសេចក្តីរាយការណ៍ជូនក្រុមប្រឹក្សាខណ្ឌរបស់ខ្លួនរៀងរាល់កិច្ចប្រជុំសាមញ្ញ ឬ វិសាមញ្ញរបស់ក្រុមប្រឹក្សាខណ្ឌ[15]

ក្រៅពីទំនាក់ទំនងនានាដូចបានរៀបរាប់ខាងលើ ទំនាក់ទំនងរវាង ក្រុមប្រឹក្សាខណ្ឌក៏បានកំណត់ក្នុងតួនាទី ភារកិច្ច និងរបៀបរបបការងាររបស់ក្រុមប្រឹក្សាខណ្ឌគណៈអភិបាលខណ្ឌផងដែរ។

ក្រុមប្រឹក្សាខណ្ឌមានកាតព្វកិច្ចបង្កើតគណៈកម្មាធិការពិគ្រោះយោបល់ចំនួន **បី** គឺៈ

- គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស
- គណៈកម្មាធិការពិគ្រោះយោបលើកិច្ចការនារី
- គណៈកម្មាធិការលទ្ធកម្ម

ក្រៅពីគណៈកម្មាធិការទាំងបី ខាងលើក្រុមប្រឹក្សាខណ្ឌអាចបង្កើត គណៈកម្មាធិការបន្ថែមផ្សេងទៀតតាមការចាំបាច់។ គណៈកម្មាធិការដែលបង្កើតបន្ថែមនេះមិនត្រូវមានតួនាទី និងភារកិច្ចត្រួតគ្នាជាមួយនឹងតួនាទីភារកិច្ចរបស់គណៈកម្មាធិការជា កាតព្វកិច្ចទាំងបីខាងលើនេះទេ។ ជាមួយគ្នានេះដែរក្រុមប្រឹក្សាខណ្ឌអាចបង្កើតអនុគណៈកម្មាធិការ ឬក្រុមការងារផ្សេងៗទៀតតាមការស្នើរសុំរបស់គណៈកម្មាធិការ ឬគណៈអភិបាលខណ្ឌ។ ហើយក្នុងការរៀបចំបង្កើតគណៈកម្មាធិការនានារបស់ ក្រុមប្រឹក្សាខណ្ឌត្រូវពិនិត្យ និងពិចារណាទៅលើចំណុចមួយចំនួនដូចខាងក្រោមៈ

- ក្រុមប្រឹក្សាខណ្ឌអាចតែងតាំងសមាជិកក្រុមប្រឹក្សាខណ្ឌ អភិបាលខណ្ឌ គណៈអភិបាលខណ្ឌអភិបាលរងខណ្ឌ តំណាងក្រុមប្រឹក្សាសង្កាត់ បុគ្គលិករបស់ក្រុមប្រឹក្សាខណ្ឌ តំណាងសហគមន៍ប្រជាពលរដ្ឋ និងអ្នកពាក់ពន្ធនានាតាមការចាំបាច់ សម្រាប់សមាជិកគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារដែលខ្លួនបាន បង្កើតឡើង
- ក្រុមប្រឹក្សាខណ្ឌអាចរំសាយគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការអារ និងអាចបញ្ឈប់សមាជិកណាម្នាក់ពីគណៈកម្មាធិការ ឬ អនុគណៈកម្មាធិការ ឬ ក្រុមការងារដែលខ្លួនបានបង្កើតឡើង មានការចាំបាច់ ឬ តាមសំណើររបស់គណៈកម្មាធិការ ឬគណៈអភិបាលខណ្ឌ។

[15] ហៀង សាង "សមត្ថ និងរបៀបរបបការងារនៅរដ្ឋបាលថ្នាក់ក្រោមជាតិ" បោះពុម្ពឆ្នាំ២០១១ ទំព័រទី៣២០

### ២.៦.៥.សមាសភាពនៃគណៈកម្មាធិការបច្ចេកទេស

- អភិបាលខណ្ឌ ជាប្រធាន
- អភិបាលរងខណ្ឌ ០១រូប ជាអនុប្រធាន
- នាយករដ្ឋបាលសាលាខណ្ឌ ជាសមាជិកអចិន្ត្រៃយ៍
- សមាជិកក្រុមប្រឹក្សាខណ្ឌយ៉ាងតិច ០២ រូប ជាសមាជិក
- ប្រធានការិយាល័យអង្គភាពនៃក្រសួងស្ថាប័ននានា រាជរដ្ឋាភិបាលដែលប្រចាំនៅខណ្ឌ សមាជិក
- ប្រធានការិយាល័យទាំងអស់ក្នុងសាលាខណ្ឌ ជាសមាជិក
- ចៅសង្កាត់ទាំងអស់ក្នុងខណ្ឌ ជាសមាជិក
- តំណាងគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្រ្តី
- និងកុមាររបស់ក្រុមប្រឹក្សាខណ្ឌ ០១ រូបជា សមាជិក

សមាសភាព អនុប្រធានគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស ត្រូវស្នើរដោយអភិបាលខណ្ឌ និងក្រុមប្រឹក្សាខណ្ឌត្រូវចេញសេចក្តីសម្រេចទទួលស្គាល់សមាសភាពប្រធានអនុប្រធាន និងសមាជិកគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស ហើយសេចក្តីសម្រេចនេះត្រូវចុះហត្ថលេខាដោយប្រធានក្រុមប្រឹក្សាខណ្ឌ។

ការិយាល័យចំណុះឲ្យសាលាខណ្ឌ ៖

- ការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ
- ការិយាល័យផែនការ និងអភិវឌ្ឍន៍
- ការិយាល័យអន្តរវិស័យ

## ២.៧.ផែនការសកម្មភាព និងសមិទ្ធផលសាលាខណ្ឌមានជ័យ

### ២.៧.១.គិតពីសេវាសាធារណៈ

សេវាសាធារណៈ គឺជាសេវាចម្បងនៅក្នុងចំនោមសេវាផ្សេងៗដែលមានក្នុងខណ្ឌមានជ័យ។ ក្នុងនេះដែរក្នុងខណ្ឌមានជ័យបានបង្កើតឡើងទើបតែបានមួយអាណត្តិតែប៉ុណ្ណោះ ប៉ុន្តែខណ្ឌនេះបានគិតគូរពីវិស័យសេវាសាធារណៈនេះជាវិស័យអាទិភាពក្នុងការបម្រើជូនប្រជាពលរដ្ឋ តាមរយៈការធ្វើឲ្យសេវាសាធារណៈកាន់តែមានភាពងាយស្រួល និងសាមញ្ញតាមរយៈការបង្វិតរដ្ឋបាលសាធារណៈបច្ចុប្បន្នឲ្យកាន់តែខិតជិតទៅរកប្រជាពលរដ្ឋ ។ តាមរយៈការដាក់ឲ្យអនុវត្តតាម ៖

- អនុក្រឹត្យលេខ ៦២ អនក្រ/បក/ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ ២០១២ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការកំណត់ថ្លៃជាវសំបុត្រអត្រានុកូលដ្ឋាន និងថ្លៃតែម
- ការបង្កើតឲ្យមាននូវការិយាល័យច្រកចេញចូលតែមួយតាមរយៈប្រកាសអន្តរក្រសួងលេខ៣៨៥ ប្រ/ក ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការផ្តល់សេវារដ្ឋបាលនៅថ្នាក់ក្រោមជាតិ
- អនុក្រឹត្យស្តីពី ការកែសម្រួលចំណុច ក និង ខ មាត្រា៥៩ ថ្មីស្ទួននៃអនុក្រឹត្យលេខ ១៧ អនក្រ/បក ចុះថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០០៤ ស្តីពីការកែសម្រួលអនុក្រឹត្យ ស្តីពីអត្រានុកូលដ្ឋាន ឆ្នាំ ២០០៥

នេះគឺជាទិសដៅដាក់ឲ្យអនុវត្តន៍ស្តីពីអត្រានុកូលដ្ឋាន ដើម្បីបង្ករភាពងាយស្រួល និងរហ័សជាងមុននៃអត្រានុកូលដ្ឋាន។

### ២.៧.១.១.ការងារអត្រានុកូលដ្ឋាន

**តារាងទី៣៖** ការចេញសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋាន

| ល.រ | ការបរិយាយ | ចំនួន | | | | | |
|---|---|---|---|---|---|---|---|
| | | ២០០៩ | ២០១០ | ២០១១ | ២០១២ | ២០១៣ | សរុប |
| ១ | សេចក្តីចម្លងសំបុត្រកំណើត | ១៧៥ | ១៤៤ | ៣៨៤ | ៣៥១ | ៤៦២ | ១,៥១៦ |
| ២ | សេចក្តីចម្លងសំបុត្របញ្ជាក់កំណើត | ១,៣២០ | ១,៣១៤ | ៣,៥០១ | ៣,៤៣៩ | ៣,៩១៦ | ១៣,៤៩០ |
| ៣ | សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ | ២៩ | ២៨ | ៧៦ | ៨៤ | ១២៤ | ៣៤១ |
| ៤ | សេចក្តីចម្លងសំបុត្រមរណៈភាព | ១៣ | ១៦ | ២៥ | ២៩ | ២១ | ១០៤ |

<u>ប្រភព៖</u> *របាយការណ៍របស់ក្រុមប្រឹក្សាខណ្ឌមានជ័យអាណត្តិទី១*

### ២.៧.១.២ការងារច្រកចេញចូលតែមួយ

ដោយអនុវត្តន៍ទៅតាមសេចក្តីសម្រេច របស់រាជរដ្ឋាភិបាលក្រសួងមហាផ្ទៃបានដាក់ចេញនូវប្រកាសស្តីពីការបង្កើតការិយាល័យច្រកចេញចូលតែមួយទៅតាមបណ្តា ក្រុង ស្រុក ខណ្ឌ ។ ក្នុងការបង្កើតឡើងនូវការិយាល័យច្រកចេញចូលតែមួយនៅថ្នាក់ ក្រុង ស្រុក ខណ្ឌ មានគោលបំណងសំខាន់ៗដូចខាងក្រោម ៖

- លើកកម្ពស់គោលការណ៍អភិបាលកិច្ចល្អ ការកែទម្រង់ប្រពន្ធ័រដ្ឋបាល ដោយពង្រីកវិសាលភាពសេវាកម្មដែលផ្តល់ដោយរដ្ឋបាលក្រុង ស្រុក ខណ្ឌ ឲ្យបានទូលំទូលាយតាមរយៈការប្រមូលផ្តុំសេវាកម្មទាំងអស់ ក្នុងក្របខណ្ឌសមត្ថកិច្ចរបស់ ក្រុង ស្រុក ខណ្ឌ ដែលបានផ្តល់ជូនអតិថិជននៅក្នុងកន្លែងតែមួយ។

- កែលម្អការផ្តល់សេវារដ្ឋបាល កាត់បន្ថយអំពើពុករលួយ និងបង្កើនការជឿទុកចិត្តពីប្រជាពលរដ្ឋលើប្រព័ន្ធរដ្ឋបាល។
- លើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋ ក្នុងការផ្តល់មតិយោបល់ និងការរិះគន់ស្ថាបនាដើម្បីកែលម្អប្រព័ន្ធរដ្ឋបាល ។
- បង្វិតរដ្ឋបាលឲ្យនៅកៀកជិតប្រជាពលរដ្ឋ បង្កភាពងាយស្រួលក្នុងការផ្តល់ សេវាឲ្យបានឆាប់រហ័ស ប្រកបដោយប្រសិទ្ធភាព គុណភាព តម្លាភាព ឆ្លើយតបទាន់ពេលវេលាទៅនឹងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ។

**អត្ថន័យនៃការិយាល័យច្រកចេញចូលតែមួយ**

ការិយាល័យច្រកចេញចូលតែមួយគឺជា:

- កន្លែងផ្តល់សេវារដ្ឋបាល ដែលប្រជាពលរដ្ឋត្រូវការចាំបាច់ឲ្យបានទាន់ពេលវេលា មានតម្លាភាព និងតាមនីតិវិធីសាមញ្ញ
- កន្លែងប្រមូលផ្តុំសេវារដ្ឋបាល និងនីតិវិធីរដ្ឋបាលមួយចំនួននៅកន្លែងតែមួយ
- កន្លែងដែលអតិថិជនមកទទួលទម្រង់បែបបទ និងទទួលពត៌មានគ្រប់គ្រាន់ច្បាស់លាស់ស្តីពីការផ្តល់សេវារដ្ឋបាលផ្សេងៗ និងការបង់កម្រៃសេវា ឬអាករផ្សេងៗ
- កន្លែងផ្តល់លទ្ធផលសម្រេចជាផ្លូវការ លើសេចក្តីស្នើសុំដល់អតិថិជន។[16]

**២.៧.១.៣. សន្តិសុខសណ្តាប់ធ្នាប់សាធារណៈ**

លើកកម្ពស់ចលនាមហាជន ចូលរួមការពារសន្តិសុខសុវត្ថិភាពនៅក្នុងមូលដ្ឋានឲ្យបានភ្លៀវភ្លា ដើម្បីពង្រឹងខឿនសន្តិសុខឲ្យកាន់តែរឹងមាំ តាមរយៈការបន្តជម្រុញចលនា នៃការអនុវត្តគោលនយោបាយ "ភូមិ-សង្កាត់មានសុវត្ថិភាព" ទាំងប្រាំចំណុច ឲ្យមាននិរន្តភាព និងសកម្មនៅគ្រប់មូលដ្ឋានទូទាំងខណ្ឌ ព្រមទាំង ពង្រឹងវិធានការទប់ស្កាត់ និងបង្ក្រាបបទល្មើសព្រហ្មទណ្ឌគ្រប់ប្រភេទ ដើម្បីបង្កភាពកក់ក្តៅក្នុងការរស់នៅ ការធ្វើដំណើរការដើរហើរ និងប្រកបមុខរបររបស់ប្រជាពលរដ្ឋ ក្នុងនោះយើងសង្កេតឃើញដែលគោលនយោបាយ ៥ ចំណុច នោះរួមមានដូចជាះ

- គ្មានសកម្មភាពលួចឆក់ ប្លន់
- គ្មានការដាំដុះ ការផលិត ការចរាចរ ការជួញដូរ ការចែកចាយ និងការប្រើប្រាស់គ្រឿងញៀន
- គ្មានអំពើអនាចារ ការជួញដូរស្ត្រី និងកុមារ រួមទាំងអំពើហិង្សាក្នុងគ្រួសារ

[16] ក្រសួងមហាផ្ទៃ "ការិយាល័យចក្រចេញចូលតែមួយ" ឆ្នាំ២០១១ ទំព័រទី៨

- គ្មានក្មេងទំនើង
- គ្មានការលេងល្បែងស៊ីសងខុសច្បាប់គ្រប់ប្រភេទ ការប្រើប្រាស់អាវុធខុសច្បាប់ និងបទល្មើសគ្រប់ប្រភេទ។[17]

ចំពោះសភាពការណ៍បទល្មើសព្រហ្មទណ្ឌវិញ សាលាខណ្ឌមានជ័យបានយល់ថា កាលណាមានការមិនគោរពច្បាប់នៃប្រទេសមានការកើនឡើងនៅក្នុងមូលដ្ឋាន ដូចនេះវាអាចនិងធ្វើឲ្យមាននូវភាពអនាធិបតេយ្យ អសន្តិសុខនៅក្នុងមូលដ្ឋាន ហេតុដូច្នេះហើយទើបសាលាខណ្ឌមានជ័យបានខិតខំក្នុងការកាត់បន្ថយ និងព្យាយាមក្នុងការលុបបំបាត់ គឺបង្កានិងទប់ស្កាត់នូវអំពើទាំងនេះ និងបំបាត់នូវក្មេងទំនើងនៅមូលដ្ឋានស្ទើរតែគ្មាន។ តាមរយៈការចុះទៅដោះស្រាយទាន់ពេលវេលា ការឆែកនូវអាវុធជាតិផ្ទុះ ការចុះយាមល្បាត និងការផ្សព្វផ្សាយពីគោលនយោបាយភូមិ ឃុំ មានសុវត្ថិភាព

- បទល្មើសព្រហ្មទណ្ឌកើតឡើង ៣៩០លើក ស្លាប់៤៦នាក់ របួស៥៧នាក់ ឃាត់ខ្លួន ៣៦១នាក់ ក្នុងនោះបទឧក្រិដ្ឋ ១៦២លើក ស្លាប់៤៦នាក់ របួស៣៤នាក់ ឃាត់ខ្លួន ១១៦ នាក់ និងបទមជ្ឈិមកើតឡើង២២៨លើក របួស២៣នាក់ និងឃាត់ខ្លួន២៤៥នាក់។
- លទ្ធផលបង្ក្រាបបទល្មើសព្រហ្មទណ្ឌៈ បង្ក្រាបបាន៦៣២លើក បណ្តាលឲ្យស្លាប់មនុស្ស០៦នាក់ និងឃាត់ខ្លួនបាន៩៦៦នាក់ ក្នុងនោះបទឧក្រិដ្ឋបង្ក្រាបបាន៣០១ លើក ឃាត់ខ្លួនបាន ៥២១នាក់ បទមជ្ឈិមបង្ក្រាបបាន ៣៣១លើក បណ្តាលឲ្យមនុស្សស្លាប់ ០៦ នាក់ និងឃាត់ខ្លួន ៤៤៥ នាក់។

ប៉ុន្តែទោះជាមានការដាក់ចេញនូវគោលនយោបាយផ្សេងៗ ការហាមឃាត់ និងការបង្ក្រាបយ៉ាងណាក៏បទល្មើសនៅក្នុងមូលដ្ឋាននៃខណ្ឌមានជ័យនៅតែកើតមាន គ្រាន់តែវាមានភាពតិចតួច។[18]

### ២.៧.១.៤. ប័ណ្ណមូលនិធិសមធម៌

ប័ណ្ណមូលនិធិសមធម៌ ត្រូវបានផ្តល់ឲ្យដោយសហគមន៍លើកកំពស់សុខុមាលភាពប្រជាជនខណ្ឌមានជ័យ ដែលត្រូវបង្កើតឡើងដោយលិខិតលេខ ០០១សលសប្រ ចុះថ្ងៃទី០៧ខែកុម្ភៈ ឆ្នាំ២០១១ ស្តីពីសុំចុះបញ្ជីរបស់សហគមន៍។

បានផ្តល់ប័ណ្ណមូលនិធិសមធម៌ដល់ប្រជាពលរដ្ឋក្រីក្រ ដើម្បីទទួលសេវាព្យាបាលជំងឺដោយឥតបង់ប្រាក់ តាមមន្ទីរពេទ្យ និងមណ្ឌលសុខភាពសរុបចំនួន ៥.០៣៦ គ្រួសារ។ ហើយសមាគមន៍នេះមានគោលដៅសំខាន់ៗដូចជាៈ

[17] សេចក្តីណែនាំរបស់ក្រសួងមហាផ្ទៃ ស្តីពី "ការចាត់តាំងអនុវត្តគោលនយោបាយ ភូមិឃុំ មានសុវត្ថិភាព" ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១០

[18] របាយការណ៍របស់ក្រុមប្រឹក្សាខណ្ឌមានជ័យអាណត្តិទី១ (២០០៩-២០១៣) ទំព័រទី១៥

- លើកស្ទួយសុខភាពប្រជាជនក្រីក្រឲ្យទទួលបានសេវាសុខភាពសាធារណៈដោយឥតបង់ប្រាក់តាមរយៈការផ្តល់មូលវិធិដោយសហាការជាមួយអង្គការនានា ដៃគូរអភិវឌ្ឍន៍ និងសប្បុរសជន
- លើកទឹកចិត្តបុគ្គលិកសុខាភិបាល ដើម្បីផ្តល់សេវា ឲ្យបានល្អប្រសើរដល់ប្រជាពលរដ្ឋ
- ធានាឲ្យអ្នកក្រីក្របានប្រើប្រាស់សេវាសុខភាពដែលមានគុណភាព
- បង្កើតយន្តការជាប្រព័ន្ធ និងពេញលេញមួយដែលគ្រប់គ្រងដោយមានរចនាសម្ព័ន្ធដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្រ និងការគាំពារសុខមាលភាពសង្គម។
- បង្កើនការប្រើប្រាស់សេវាសុខាភិបាលដោយពេញចិត្ត និងការចូលរួមរបស់ប្រជាជនក្រីក្រទូទៅក្នុងប្រពន្ធ័សុខាភិបាលសាធារណៈនៃសាលាខណ្ឌមានជ័យ
- ផ្តល់ឱកាសជូនប្រជាពលរដ្ឋក្រីក្រលើកសំណូមពរពីការខ្វះខាត និងចូលរួមផ្ទាល់ដើម្បីធ្វើឲ្យជីវភាពសុខុមាលភាពប្រសើរឡើង។[19]

**ទិសដៅក្នុងការបង្កើតគឺ**

ដើម្បីសម្រេចបាននូវគោលបំណងខាងលើនេះ សហគមន៍មានទិសដៅរបស់ខ្លួនដូចខាងក្រោមៈ

- បង្កើនអត្រាប្រើប្រាស់ និងជំនឿលើមូលដ្ឋានសុខាភិបាលសាធារណៈ
- រួមចំណែកកែលម្អគុណភាពនៃប្រពន្ធ័សុខាភិបាលសាធារណៈ
- ផ្តល់ជូនអ្នកក្រីក្រដើម្បីទទួលបាននូវសាវាសាធារណៈ
- សហការល្អជិតស្និទ្ធ ជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់លំដាប់ថ្នាក់ ការិយាល័យសុខាភិបាល ខណ្ឌ មន្ទីរពេទ្យ អង្គការនានា ដៃគូរអភិវឌ្ឍន៍ និងសប្បុរសជន ព្រមទាំងស្ថាប័នពាក់ព័ន្ធ
- ចុះអង្កេតកំណត់អត្តសញ្ញាណកម្មប្រជាជនក្រីក្រ
- សម្របសម្រួលការទំនាក់ទំនងក្រុមប្រឹក្សាសង្កាត់ មន្ទីពេទ្យ និងសហគមន៍
- គៀងគរកមូលនិធិពីអង្គការនានា ដៃគូអភិវឌ្ឍន៍ និងសប្បុរសជន។[20]

**២.៧.១.៥.សេវាសុខាភិបាល**

ស្ថិតិមូលដ្ឋានសេវាសុខាភិបាលរដ្ឋចំនួន ០៧ទីតាំង ។

[19] ប្រការ ៤ នៃលក្ខន្តិកៈសហគមន៍លើកកំពស់សុខុមាលភាពប្រជាជនខណ្ឌមានជ័យ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១១

[20] ប្រការ ៥ នៃលក្ខន្តិកៈសហគមន៍លើកកំពស់សុខុមាលភាពប្រជាជនខណ្ឌមានជ័យ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១១

- ស្ថិតិមូលដ្ឋានសេវាសុខាភិបាលឯកជនចំនួន ២២៩ទីតាំងក្នុងនោះមន្ទីរពេទ្យពហុព្យាបាល ០៦ទីតាំង កន្លែងពីគ្រោះ និងព្យាបាលជម្ងឺទូទៅ ១២០ ទីតាំង កន្លែងពិនិត្យ និង ព្យាបាលជម្ងឺមាត់ ធ្មេញ១១ទីតាំង និងឱសថស្ថាន ឱសថស្ថានរងចំនួន ៩២ទីតាំង។
- ពិនិត្យជម្ងឺទូទៅជូនប្រជាពលរដ្ឋចំនួន ៣៩១.២០២ នាក់ ។
- ចាក់ថ្នាំបង្ការការពារ ៧មុខ ដល់កុមារអាយុក្រោម ១ឆ្នាំ ចំនួន ១៧៩.០៩៦ នាក់។
- ពិនិត្យផ្ទៃពោះចំនួន ៩៩.៦១១ នាក់ ។
- ស្ត្រីសំរាលកូនចំនួន ១៧.១៣៥ នាក់ ។
- ពន្យាកំណើតចំនួន ៣៩.៦៣៥នាក់ ។
- ស្ត្រីចាក់ថ្នាំ TT មានផ្ទៃពោះចំនួន ៦៩.៣៥៨ នាក់
- ផ្តល់ថ្នាំជីវជាតិ A ដល់ទារកអាយុ ៦ខែ-១១ខែ ចំនួន ២៥.៣៣២ នាក់ ។
- ផ្តល់ថ្នាំជីវជាតិ A ដល់ទារកអាយុ ១២ខែ-៥៩ខែ ចំនួន ១៦៣.១១៣ នាក់ ។
- ពិនិត្យអេកូសាស្ត្រចំនួន ៣.៨៤២ នាក់ ។
- សកម្មភាពផ្នែករថយន្តគិលានសង្គ្រោះចំនួន ២.២៨៥លើក ។
- ចុះពិនិត្យ និងជម្រុញឲ្យសុំច្បាប់ និងបើកឱសថស្ថានចំនួន ៥០ កន្លែង។[21]

### ២.៧.១.៦. ការកសាងហេដ្ឋារចនាសម្ព័ន្ធក្នុងមូលដ្ឋាន

**តារាងទី៤៖** ការកសាងហេដ្ឋារចនាសម្ព័ន្ធក្នុងមូលដ្ឋាន

| ល.រ | ឈ្មោះសង្កាត់ | ចំនួនខ្សែ | ផ្ទៃក្រឡា(ម$^2$) | តំលៃសរុប | ថវិកា៥០% |
|---|---|---|---|---|---|
| ការងារកសាងផ្លូវចាក់បេតុង ឬស្បី | | | | | |
| ១ | និរោធ | ០៦ | ៥៤៧៦ | ២៨៣,៤៩៧,០០០រៀល | ១២១,៧៤៨,៥០០រៀល |
| ២ | ច្បារអំពៅទី១ | ០៨ | ១៣,២១៥ | ៥៦៣,៤៨០,០០០រៀល | ២៨១,៧៤០,០០០រៀល |
| ៣ | ច្បារអំពៅទី២ | ១១ | ៦,០៨៧ | ៣៧៨,៧៥៨,៥០០រៀល | ៣២៩,២៥៨,៥០០រៀល |
| ៤ | ព្រែកប្រា | ០៣ | ១០,៦៥០ | ៩៩៧,៥១៧,៥០០រៀល | ១៦០,១៥៨,៥០០រៀល |
| ៥ | ចាក់អង្រែលើ | ០៩ | ៦,៧៨៦ | ៨១៥,២៦៥,០០០រៀល | ២០៧,១៣២,៣០០រៀល |
| ៦ | ចាក់អង្រែក្រោម | ០២ | ១២,៦៨៤ | ១,១១០,១១៧,០០០រៀល | ៥៥៥,០៥៨,៥០០រៀល |
| ៧ | បឹងទំពុន | ១៧ | ៣២,២០៩ | ១,៧៤៩,១០៨,៥០០រៀល | ៨៧៤,៧០៥,១០០រៀល |
| ៨ | ស្ទឹងមានជ័យ | ២០ | ៣៨,៩៩៨ | ២,៧២០,២០៨,៤០០រៀល | ១,៣៦០,១០៤,៦០០រៀល |
| **សរុប** | | **៧៦** | **១២៥,៩៦៥** | **៧,២៥៣,៩៥១,៩០០រៀល** | **៨៨៩,៨៩៦,០០០រៀល** |
| ការងារកសាងប្រព័ន្ធលូ | | | | | |
| ១ | និរោធ | ០១ | ១១៣ | ១៣,៤៣៥,៧០០រៀល | ៦,៧១៧,៨៥០រៀល |

[21] របាយការណ៍របស់ក្រុមប្រឹក្សាខណ្ឌមានជ័យអាណត្តិទី១ (២០០៩-២០១៣) ទំព័រទី១១

| | | | | | |
|---|---|---|---|---|---|
| ២ | ច្បារអំពៅទី១ | ០ | ០ | ០រៀល | ០រៀល |
| ៣ | ច្បារអំពៅទី២ | ០៣ | ៧១៤ | ១១៥,៤៥៣,៨០០រៀល | ៥៧,៧២៦,៩០០រៀល |
| ៤ | ព្រែកប្រា | ០៤ | ១,១៤០ | ១៨២,២៨៦,០០០រៀល | ៩១,១៤៣,០០០រៀល |
| ៥ | ចាក់អង្រែលើ | ០៣ | ៧២៧ | ៨៣,៤៥៩,៦០០រៀល | ៤១,៧២៩,៨០០រៀល |
| ៦ | ចាក់អង្រែក្រោម | ០១ | ១៥០ | ២៤,២២៥,០០០រៀល | ១២,១២៧,៥០០រៀល |
| ៧ | បឹងទំពុន | ០៣ | ១,០២១ | ១៦៥,០៩៥,៧០០រៀល | ៨២,៥៤៧,៨៥០រៀល |
| ៨ | ស្ទឹងមានជ័យ | ០៦ | ១,៩២៧ | ៣១១,៥៩៥,៩០០រៀល | ១៥៥,៧៩៧,៩៥០រៀល |

**<u>ប្រភព៖</u>** *របាយការណ៍របស់ក្រុមប្រឹក្សាខណ្ឌមានជ័យអាណត្តិទី១*

### ២.៧.២.ការចូលរួមរបស់ប្រជាពលរដ្ឋ

សាលាខណ្ឌយល់ថា នៅក្នុងប្រទេសដែលប្រកាន់យកនូវរបបប្រជាធិតេយ្យ គឺមិនអាចខ្វះបានទេនូវការចូលរួមរបស់ប្រជាពលរដ្ឋបានទេ ព្រោះថាប្រជាពលរដ្ឋគឺជាកម្លាំងចលករដ៏សំខាន់ក្នុងការជួយជម្រុញនូវការកសាង និងអភិវឌ្ឍន៍សង្គមជាតិឲ្យរីកចម្រើនក៏ប៉ុន្តែការចូលរួមរបស់ ប្រជាពលរដ្ឋដល់កម្រិតណានោះ គឺវាអាស្រ័យទៅលើច្បាប់ដែលបានកំណត់នូវដែនកំណត់នៃសិទ្ធិរបស់ប្រជាពលរដ្ឋ ក្នុងការចូលរួមក្នុងការចូលរួមក្នុងសកម្មភាពសង្គម ហើយចំណុចទាំងអស់នេះហើយគឺជាមូលដ្ឋានគ្រឹះក្នុងការបង្កើតឲ្យមានអភិបាលកិច្ច និងការឆ្ពោះទៅរកប្រជាធិបតេយ្យពិតៗទើបសាលាខណ្ឌផ្តល់ឲ្យប្រជាពលរដ្ឋនូវការចូលរួមមួយដូចជា៖

#### ២.៧.២.១.ការចុះឈ្មោះ និងការពិនិត្យបញ្ជីឈ្មោះអ្នកបោះឆ្នោត

**តារាងទី៥៖** ការចុះឈ្មោះ និងការពិនិត្យបញ្ជីឈ្មោះអ្នកបោះឆ្នោត

| ល.រ | ការបរិយាយ | ចំនួន | | | | | |
|---|---|---|---|---|---|---|---|
| | | ២០០៩ | ២០១០ | ២០១១ | ២០១២ | ២០១៣ | សរុប |
| ១ | ប្រជាពលរដ្ឋដែលបានចុះឈ្មោះថ្មី | ៦.៨៥៦ | ៦.៧៧០ | ២១.៥៨១ | ២៥.៥៩៧ | ១.៨២៨ | ៦២.៦៣២ |
| ២ | ប្រជាពលរដ្ឋដែលត្រូវបានលុបឈ្មោះចេញពីបញ្ជីឈ្មោះអ្នកបោះឆ្នោត | ១.៧៣៩ | ៤.២១៩ | ២.៧៨១ | ៤.៤៦៣ | ១.៤៦៣ | ១៤.៦៣០ |
| ៣ | ប្រជាពលរដ្ឋសរុបដែលមានឈ្មោះបោះឆ្នោត (ចាស់ និងថ្មី ) | ១៤៩.៥៤៤ | ១៤៨.១០៣ | ១៩៧.៣៧៨ | ២០.១៥៧៥ | ២០២.៤១៩ | |

**<u>ប្រភព៖</u>** *របាយការណ៍របស់ក្រុមប្រឹក្សាខណ្ឌមានជ័យអាណត្តិទី១*

#### ២.៧.២.២.ការរៀបចំវេទិការសាធារណ:

ដើម្បីបង្កលក្ខណ:ងាយស្រួលដល់ប្រជាពលរដ្ឋក្នុងការចូលរួមក្នុងការបញ្ចេញមតិ និងបានរៀបចំវេទិកាសាធារណ:បានចំនួន៥០៤លើក មានមនុស្សចូលរួមចំនួន ៦៦២៦៥នាក់។

**២.៧.២.៣.ការចូលរួមរបស់ប្រជាពលរដ្ឋជានារីក្នុងមូលដ្ឋាន**

- **ការងារអប់រំផ្សព្វផ្សាយ**
  - បានផ្សព្វផ្សាយទប់ស្កាត់អំពើហឹង្សាក្នុងគ្រួសារ ការជួញដូរស្ត្រី និងកុមារ និងពលកម្មកុមារ ចំនួន ២៨៥លើក មានប្រជាពលរដ្ឋចូលរួមចំនួន ២៦.៨២៣នាក់ ។
  - បានផ្សព្វផ្សាយការគាំពារសុខភាពស្ត្រី និងកុមារចំនួន ២៦១ លើក មាន ប្រជាពលរដ្ឋចូល រួមចំនួន ២៧.០៤១ នាក់ ។
  - បានផ្សព្វផ្សាយអំពីសីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរចំនួន ៣៨៤ លើក មានប្រជាពលរដ្ឋចំនួន ២៣.៣៥០ នាក់ ។
- **ការងារអប់រំបណ្តុះបណ្តាល**
  - ពង្រឹងសមត្ថភាពស្ត្រីជាអ្នកដឹកនាំ បណ្តាលភូមិសុវត្ថិភាពចំនួន ១៦ លើក មានអ្នកចូលរួម ៤៩ នាក់ ។
- **ការជួយអន្តរាគមន៍**
  - បានផ្សះផ្សារសះជាចំនួន ១០២ ករណី
  - បានបញ្ជូនទៅតុលាការចំនួន ០៥ ករណី និងករណីរំលោភ ១០ ករណី។[22]

**២.៧.២.៤.ការងាររៀបចំដែនដី នគររូបនីយកម្ម និងសំណង់**

- ការងារចុះបញ្ជីដីធ្លីលក្ខណ:ប្រព័ន្ធចំនួន ៤.៧៨៨ប័ណ្ណ
- ការងារចុះបញ្ជីដីធ្លីលក្ខណ:ដាច់ដោយដុំចំនួន ៣៦៧ប័ណ្ណ
- ការងារចុះបញ្ជីដីធ្លីបំពេញបន្ថែមចំនួន ១១៣ប័ណ្ណ
- លក់ផ្តាច់ និងអំណោយផ្តាច់ដី និងផ្ទះចំនួន ៣.៥៦៣ប័ណ្ណ
- បញ្ជូនឯកសារស្នើសុំសាងសង់ផ្ទះចំនួន ២៤៥ច្បាប់
- ចូលរួមចុះពិនិត្យការដ្ឋានសុំសាងសង់ផ្ទះចំនួន ២២៩ទីតាំង

**២.៧.៣.ការពង្រឹងនីតិរដ្ឋ**

នីតិរដ្ឋក្នុងន័យនេះគឺ ផ្តោតសំខាន់ទៅលើ

- ឯកសាក្រមខណ្ឌច្បាប់
- ការអនុវត្តន៍ច្បាប់ ដោយមិនលំអៀង
- ការការពារសិទ្ធមនុស្ស
- តុលាការឯករាជ្យ និងយុត្តិធម៌

[22] របាយការណ៍របស់ក្រុមប្រឹក្សាខណ្ឌមានជ័យអាណត្តិទី១ (២០០៩-២០១៣) ទំព័រទី១១

- សមត្ថកិច្ចពង្រឹង ការអនុវត្តន៍ច្បាប់ដោយមិនលំអៀង និងមិនពុករលួយ ។ ទន្ទឹមនឹងនេះដែរមន្ត្រីគ្រប់រូបនៅក្នុងសាលាខណ្ឌមានជ័យ បានខិតខំប្រឹងប្រែងយ៉ាងពេញទំហឹងក្នុងការជួយពង្រឹងនីតិរដ្ឋក្នុងមូលដ្ឋានរបស់ខ្លួន តាមរយៈការយកច្បាប់រដ្ឋជាគោលក្នុងការសម្រេចអ្វីមួយ
- ច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាខណ្ឌ
- ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាសង្កាត់
- លិខិតបទដ្ឋានផ្សេងៗទៀតដូចជា

**ដីកា សេចក្តីសម្រេច និង លិខិត**

**តារាងទី៦៖** ដីកា សេចក្តីសម្រេច និង លិខិត

| ល.រ | ការបរិយាយ | ចំនួន | | | | | |
|---|---|---|---|---|---|---|---|
| | | ២០០៩ | ២០១០ | ២០១១ | ២០១២ | ២០១៣ | សរុប |
| ១ | ដីកាដែលបានដាក់ចេញ | ២ | ១ | ៣ | ១ | ០ | ៧ |
| ២ | សេចក្តីសម្រេចដែលបានដាក់ចេញ | ៩១ | ៩៣ | ៨៧ | ១២៩ | ៩១ | ៤៩១ |
| ៣ | លិខិតរដ្ឋបានដែលបានដាក់ចេញ | ២.៥៥៨ | ២.៧៧៦ | ២.៤៣៣ | ២.៨១៨ | ៣.០៦២ | ១៣.៦៤៧ |
| ៤ | លិខិតដែលបានទទួល | ២.៧៣៧ | ៣.០០៣ | ២.៨៥០ | ២.៩៥៥ | ២.៧២៥ | ១៤.២៧០ |

<u>**ប្រភព៖**</u> *របាយការណ៍របស់ក្រុមប្រឹក្សាខណ្ឌមានជ័យអាណត្តិទី១*

## ២.៧.៤.ការជម្រុញឲ្យមានតម្លាភាព និង ការឆ្លើយតប

សាលាខណ្ឌមានជ័យបានយល់ថា តម្លាភាព និងការឆ្លើយតប គឺជាកត្តាសំខាន់មួយសម្រាប់សបញ្ជាក់ពីភាពស្អាតស្អំនៃការធ្វើការសម្រេចចិត្តដោយគោរពទៅតាមច្បាប់ និងលិខិតបទដ្ឋាននានា និងផ្សព្វផ្សាយជាចំហរតាមរយៈប្រព័ន្ធសមស្របមួយទៅកាន់ក្រុមមនុស្ស ដែលអាចនឹងទទួលរងផលប៉ះពាល់នោះបានដឹងឮ និងដើម្បីបញ្ចៀសការរំលោភបំពានច្បាប់ និងរំលោភអំណាចណាមួយ។ និងចំពោះការឆ្លើយតបនោះ គឺសាលាខណ្ឌក៏បានយល់ថាការឆ្លើយតបពិតប្រាកដនៅក្នុងគោលការណ៍អភិបាលកិច្ចល្អនេះត្រូវទាមទាឲ្យស្ថាប័ន និងអង្គភាពប្រឹងប្រែងឲ្យអស់ពីសមត្ថភាពដើម្បីបម្រើដល់ប្រជាពលរដ្ឋ និងបុគ្គលដែលពាក់ព័ន្ធទាំងអស់ឲ្យស្មើរភាពគ្នា ហើយការឆ្លើយតបនេះត្រូវស្ថិតនៅក្នុងវេលាមួយសមស្រប និងសមហេតុផល។ ម៉្យាងវិញទៀតសាលាខណ្ឌក៏មានកាតព្វកិច្ចប្រាប់ពីមូលហេតុ ឬបញ្ហាទាំងឡាយដែលអាចឲ្យសេចក្តីសម្រេចផងដែរនោះជាប់គាំង និងត្រូវឈានទៅរកការស្វែងរកនូវដំណោះស្រាយ។ ដូចជាក្នុងករណីខណ្ឌមានជ័យ និងសង្កាត់ដែលជាសេនាធិការនៅពេលដែលប្រជាប្រជាពលរដ្ឋម្នាក់មានទំនាស់ រឺ មានតម្រូវការអ្វីមួយក្នុងមូលដ្ឋាន គាត់បានដាក់ដាក់សំណើរ ឬពាក្យបណ្តឹង នោះនៅសង្កាត់នេះគឺសង្កាត់តែងតែធ្វើការឆ្លើយតបដោយការដោះស្រាយ

ជាការសម្រុះសម្រួល ផ្សះផ្សារ ឬនីតិវិធីផ្សេងៗទៅពួកគាត់បានទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធភាព។ ចំពោះការឆ្លើយតបនេះខណ្ឌមានជ័យបានបង្កើតនូវសមិទ្ធផលនៃផែនការ និងសកម្មភាពជាច្រើនដូចជា ៖

សាលាខណ្ឌបានចុះទៅសំរុះសំរួលបណ្តឹងបរិស្ថានចប់ចំនួន ៧០ មូលដ្ឋាន និងតាមរយៈ៖

- ផ្តល់ការកសាងសមត្ថភាពដល់ ក្រុមប្រឹក្សា និងផ្តល់ការគាំទ្រអំពីការលើកកំពស់អភិបាលកិច្ចល្អ
- កសាងការយល់ដឹងរបស់សាធារណៈជនទាក់ទងនឹងសិទ្ធិរបស់ប្រជាពលរដ្ឋ។
- ពិនិត្យតាមដានក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីធានាឲ្យបានថា សេចក្តីសម្រេចត្រូវបានផ្សព្វផ្សាយ ហើយឯកសារ ត្រូវបើកឲ្យសាធារណជនពិនិត្យមើលនៅសាលាឃុំ សង្កាត់។
- ជម្រុញការបញ្ចូលប្រជាពលរដ្ឋទៅក្នុងគណៈកម្មាធិការនានា។
- បង្កើតប្រព័ន្ធទទួលស្គាល់តួនាទីគំរូ របស់ឃុំ សង្កាត់ នៅក្នុងអភិបាលកិច្ចល្អ។

**តារាងទី៧៖** ការជម្រុញឲ្យមានតម្លាភាព និង ការឆ្លើយតប

| ល.រ | ការបរិយាយ | ចំនួន | | | | | |
|---|---|---|---|---|---|---|---|
| | | ២០០៩ | ២០១០ | ២០១១ | ២០១២ | ២០១៣ | សរុប |
| ១ | ករណីដែលបានដោះស្រាយឬសម្រុះ សម្រួលរួច | ៥៤០ | ៥០៩ | ៥២៧ | ៤៨០ | ៥៤១ | ២.៥៩៧ |
| ២ | ករណីដែលបានបញ្ជូនទៅស្ថាប័នពាក់ព័ន្ធ | ៤៤ | ៣៦ | ២៦ | ២៧ | ៤៣ | ១៧៦ |

<u>ប្រភព៖</u> *របាយការណ៍របស់ក្រុមប្រឹក្សាខណ្ឌមានជ័យអាណត្តិទី១*

## កិច្ចប្រជុំក្រុមប្រឹក្សាឃុំសង្កាត់ និង គ.ក.ន.ក

**តារាងទី៨៖** កិច្ចប្រជុំក្រុមប្រឹក្សាឃុំសង្កាត់ និង គ.ក.ន.ក

| ល.រ | ការបរិយាយ | ចំនួន | | | | | |
|---|---|---|---|---|---|---|---|
| | | ២០០៩ | ២០១០ | ២០១១ | ២០១២ | ២០១៣ | សរុប |
| ១ | កិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សា | ១៤៤ | ១៤៤ | ១៤៤ | ១៤៤ | ១៤៤ | ៧២០ |
| ២ | កិច្ចប្រជុំវិសាមញ្ញរបស់ក្រុមប្រឹក្សា | ២២ | 17 | ៣២ | ៣៦ | ២៨ | ១៣៥ |
| ៣ | កិច្ចប្រជុំសម្ងាត់របស់ក្រុមប្រឹក្សា | 0 | 0 | 0 | 0 | ២ | ២ |
| ៤ | កិច្ចប្រជុំ គ.ក.ន.ក | ១៤៦ | ១៤៧ | ១៤១ | ១៣៥ | ១២៨ | ៦៩៧ |

<u>ប្រភព៖</u> *របាយការណ៍របស់ក្រុមប្រឹក្សាខណ្ឌមានជ័យអាណត្តិទី១*

## ២.៧.៥.ការទទួលខុសត្រូវ និងគណនេយ្យភាព

សាលាខណ្ឌមានជ័យ បានយល់ពីសារៈសំខាន់នៃភាពទទួលខុសត្រូវក្នុងការងារចំពោះមុខសាធារណៈជនទូទៅ និងចំពោះមុខថ្នាក់ដឹកនាំ។ ហេតុនេះហើយសាលាខណ្ឌមានជ័យបានមានគោលការណ៍ច្បាស់លាស់ក្នុងការងារក្នុងការសម្រេចចិត្តធ្វើនូវកិច្ចការអ្វីមួយ។ ក្របខណ្ឌច្បាប់វិមជ្ឈការ

ជាការផ្តោតទៅលើការពង្រឹងអភិបាលកិច្ច ដែលមានគណនេយ្យភាព និងតម្លាភាពរបស់ក្រុម-ប្រឹក្សា។ ការរៀបចំផែនការអភិវឌ្ឍន៍៥ឆ្នាំ ការរៀបចំកម្មវិធីវិនិយោគ៣ឆ្នាំរំកិល ការរៀបចំថវិកា របស់សង្កាត់ការដេញថ្លៃគម្រោង និងការគ្រប់គ្រងគម្រោង សុទ្ធតែបានអនុវត្តតាមនីតិវិធីដែលមានតម្លាភាព ការចូលរួមគណនេយ្យភាព ដោះស្រាយបាននូវសេចក្តីត្រូវការជាអាទិភាពរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន និងមានប្រសិទ្ធភាព ។

រាល់ការចំណាយទាំងអស់ រួមទាំងចំណាយខាងរដ្ឋបាល និងការអភិវឌ្ឍន៍ក្រុមប្រឹក្សាសង្កាត់ បានរៀបចំជារបាយការណ៍ប្រកបដោយតម្លាភាព។ ការប្រើប្រាស់ក្តារព័ត៌មានការផ្សព្វផ្សាយអំពីរបាយការណ៍ចំណាយការ ដែលប្រជាពលរដ្ឋអាចទទួលបាននូវព័ត៌មាននានាជុំវិញការអនុវត្តន៍ភារកិច្ច និងការផ្តល់សេវាសាធារណៈនានាត្រូវបានយកចិត្តទុកដាក់ពីក្រុមប្រឹក្សាសង្កាត់ទាំង១២។ ដើម្បីពង្រឹងគណនេយ្យភាពថ្នាក់ជាតិ និងថ្នាក់ក្រុង បានបំពាក់ប្រអប់សំបុត្រគណនេយ្យភាពនៅតាមទីស្នាក់ការសង្កាត់ទាំង១២ ផ្សារច្បារអំពៅ និងនៅទីស្នាក់ការសាលាខណ្ឌមានជ័យ ក្នុងគោលដៅដើម្បីប្រមូលព័ត៌មានពីភាពមិនប្រក្រតីនានា ដែលអាចកើតមាននៅក្នុងការអនុវត្តន៍គម្រោងមូលនិធិសង្កាត់នីមួយៗ។

## ២.៨.សមិទ្ធផលជារួមនៃសាលាខណ្ឌមានជ័យក្នុងអាណត្តិទីមួយ

- បានទទួលពាក្យបណ្តឹងសរុបចំនួន ២១៦ករណី ស្រាយចប់ ៨៣ករណី បង្វែរសំណុំរឿង និងតម្កល់ទុកចំនួន ៨០ករណី និងដោះស្រាយបន្តចំនួន ៥៣ករណី
- បានទទួលថវិកាមូលនិធិខណ្ឌចំនួន ៣.០៣៨.៤០០.០០០០រៀល បានរៀបចំផែនការអភិវឌ្ឍន៍ខណ្ឌ៥ ឆ្នាំ (២០១១-២០១៥) ០១ លើក
- បានរៀបចំកម្មវិធីវិនិយោគ ៣ឆ្នាំ រំកិលខណ្ឌ ចំនួន ០៣ លើក (២០១១-២០១៣ ២០១២-២០១៤ និង ២០១៣-២០១៥)
- បានរៀបចំផែនការសកម្មភាពសំខាន់ៗ របស់រដ្ឋបាលខណ្ឌមានជ័យចំនួន ១០ លើក
- បានរៀបចំសម្របសម្រួលការរៀបចំផែនការ កម្មវិធីវិនិយោគ និងថវិកាសង្កាត់ទាំង ១២ ចំនួន ០៤លើក
- បានរៀបចំសិក្ខាសាលាសមាហរណកម្មកម្មវិធីវិនិយោគសង្កាត់ប្រចាំឆ្នាំ ចំនួន ០៤លើក
- បានរៀបចំការដេញថ្លៃគំរោងមូលនិធិសង្កាត់ទាំង ១២ ប្រចាំឆ្នាំ ចំនួន ០៤លើក
- បានសហការរៀបចំវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពក្រុមប្រឹក្សាខណ្ឌគណៈ អភិបាលខណ្ឌ និងមន្ត្រីរបស់រដ្ឋបាលខណ្ឌចំនួន១៨ លើក
- បានស្ថាបនាផ្លូវបេទីមីឈឺចំនួន ០៣ខ្សែ ប្រវែង ១.៥៣៤ ម៉ែត្រ

បានស្ថាបនាផ្លូវ DBST ចំនួន ០៧ខ្សែ ប្រវែង ៤.២២១ ម៉ែត្រ

- បានស្ថាបនាផ្លូវបេតុងចំនួន ២៩៥ ខ្សែ ប្រវែង ១០៦.៤៦៨ ម៉ែត្រ
- បានស្តារប្រឡាយចំនួន ១១ ខ្សែ ប្រវែង ២៨.៣២០ ម៉ែត្រ
- បានរៀបចំចិញ្ចើមផ្លូវ និងកូរ៉ូឡាប្រវែង ៣.២៨៥ ម៉ែត្រ
- បានជួលជុលផ្លូវចាស់ដីស និងកំទេចថ្មចំនួ ៣៧ ខ្សែ ប្រវែង ១៥.៣៦៣ ម៉ែត្រ
- បានប្តូរខ្ទោះអណ្តូងលូចំនួន ៧០ កន្លែង
- បានដាក់បង្គោលភ្លើងចំនួន ១១៣ ដើម និងអំពូលភ្លើងបំភ្លឺផ្លូវសាធារណៈចំនួន ២៤៦ អំពូល
- បានសាងសង់សាលាសង្កាត់ក្បាលកោះ ១ខ្នង និងប៉ុស្តិ៍នគរបាលរដ្ឋបាលក្បាលកោះ ១ខ្នង
- បានទទួលសមិទ្ធផលរបស់រាជរដ្ឋាភិបាលរួមមាន ស្ពានព្រះមុន្នីវង្សថ្មី ស្ពានអាកាសក្បាលថ្នល់ ស្ពានស្ទឹងមានជ័យ ស្ពានអាកាសស្ទឹងមានជ័យ និងស្ពានព្រែកសំរោង
- កំពុងសាងសង់ស្ពានបាឡេ ០១ខ្សែ ប្រវែង ៧៣.២០ ម៉ែត្រx៧.៣៥ម៉ែត្រ
- បានរៀបចំពិធីប្រកាសចូលកាន់តំណែងក្រុមប្រឹក្សាខណ្ឌ អាណត្តិទី១
- បានរៀបចំកិច្ចប្រជុំសាមញ្ញក្រុមប្រឹក្សាខណ្ឌចំនួន៤៨ លើក និងវិសាមញ្ញចំនួន ០៧ លើក
- បានអនុម័តបង្កើតគណៈកម្មាធិកាសម្របសម្រួលបច្ចេកទេស
- បានអនុម័តបង្កើតគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ
- បានអនុម័តបង្កើតគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្ម ថ្នាក់ខណ្ឌ

ក្រៅពីសមិទ្ធផលដូចបានជំរាបជូនខាងលើ នៅមានសមិទ្ធផលសម្រេចបានជាច្រើនទៀតដែលមិនបានលើកឡើងនោះទេ។ ជាងនេះទៅទៀត ចំពោះសមិទ្ធផលដែលបានសម្រេចក្នុងការបង្កើតគណៈកម្មាធិការនៅ ខណ្ឌមានជ័យក៏បានរៀបរាប់សព្វគ្រប់ដែរ ដោយឡែកចំពោះគណៈកម្មាធិការលទ្ធកម្មនៅថ្នាក់ខណ្ឌ គឺមិនទាន់មាននៅឡើយទេ។ គណៈកម្មាធិការលទ្ធកម្ម មានតែនៅក្នុងថ្នាក់សង្កាត់តែប៉ុណ្ណោះ ដោយស្របតាមសេចក្តីសម្រេចរបស់ សាលារាជធានីភ្នំពេញ

# ជំពូកទី ៣
# ការវិភាគទៅលើសមិទ្ធផលនៃសាលាខណ្ឌមានជ័យ

ដើម្បីឲ្យការស្រាវជ្រាវមានលក្ខណៈកាន់តែល្អប្រសើរ និងកាន់តែមានភាពច្បាស់លាស់ គឺយើងមិនត្រឹមតែស្រាវជ្រាវទៅលើឯកសារ និងរបាយការណ៍ដែលមានក្នុងសាលាខណ្ឌតែប៉ុណ្ណោះទេ គឺយើងបានធ្វើការសាកសួរផ្ទាល់ពីសំណាក់ ប្រជាពលរដ្ឋ មន្ត្រីក្នុងសាលាខណ្ឌ និងមន្ត្រីក្នុងសង្កាត់ទាំងបួនផងដែរ។

## ៣.១. ការគិតគូរពីសេវាសាធារណៈ

សេវាសាធារណៈ គឺជាសេវាមួយដែលមានសារៈសំខាន់ណាស់ ចំពោះប្រជាពលរដ្ឋក្នុងមូលដ្ឋាន។ ដូចគ្នានេះដែរ មានសេវាជាច្រើនដែលស្ថិតនៅក្នុងចង្កោមនៃសេវាសាធារណៈនេះ ប៉ុន្តែយើងបានយកមកលើកឡើងតែពីសេវាសកម្មមួយចំនួន ដែលជាសេវាអាទិភាពដែលប្រជាពលរដ្ឋតែងតែមកទទួលសេវានេះជាញឹកញាប់នៅមូលដ្ឋានតែប៉ុណ្ណោះ។

### ៣.១.១. ការវិភាគលើសេវាអត្រានុកូលដ្ឋាន

ជាការពិតណាស់សេវាអត្រានុកូលដ្ឋាន ជាសេវាមួយដែលផ្តល់ជូនតាមរយៈចៅសង្កាត់ជាមន្ត្រីអត្រានុកូលដ្ឋាន ចំណែកស្មៀន និងមន្ត្រីសង្កាត់ ជាជំនួយការ ។ សំបុត្រអត្រានុកូលដ្ឋានដែលមន្ត្រីបានផ្តល់ឲ្យរួមមាន៖ សំបុត្រកំណើត សំបុត្រអាពាហ៍ពិពាហ៍ សំបុត្រមរណៈភាព។ ក្នុងករណីនេះដែរយើងបានធ្វើការសាកសួរ ទៅលើមន្ត្រីក្នុងខណ្ឌមានជ័យ ដែលទើបនឹងកាត់ចូលខណ្ឌមានជ័យចំនួនបួនសង្កាត់។ក្នុងនោះដែររួមមាន៖ សង្កាត់ចាក់អង្រែលើ សង្កាត់ចាក់អង្រែក្រោម សង្កាត់បឹងទំពុន សង្កាត់ស្ទឹងមានជ័យ។

**តារាងទី៩៖** សេវាអត្រានុកូលដ្ឋាន

| ល.រ | ការបរិយាយ | ចំនួន | | | | | |
|---|---|---|---|---|---|---|---|
| | | ២០០៩ | ២០១០ | ២០១១ | ២០១២ | ២០១៣ | សរុប |
| ១ | សំបុត្រកំណើត | ៣.០៩២ | ៣.៣៩៥ | ៣.២២៦ | ៣.៤៥៦ | ៤.០៧៨ | ១៧.១៩៧ |
| ២ | សំបុត្របញ្ជាក់កំណើត | ៤.៦៨៥ | ៥.២១៨ | ៥.០០១ | ៥.២១៨ | ៥.០៩៩ | ២៥.២២១ |
| ៣ | សេចក្តីចម្លងសំបុត្រកំណើត | ១.៥០៧ | ១.៧៣៨ | ១.៦៥៧ | ២.២៦៣ | ១.៧០៧ | ៨.៨៧២ |
| ៤ | សេចក្តីចម្លងសំបុត្របញ្ជាក់កំណើត | ១.៨៩៥ | ២.១៧៧ | ២.១៩៧ | ២.៤៤៣ | ១.៩៨៤ | ១០.៦៩៦ |
| ៥ | សំបុត្រអាពាហ៍ពិពាហ៍ | ១.៩៣៤ | ១.៣២៧ | ១.៩៦៦ | ១.៩១៦ | ១.៣៣៦ | ៦.៩៧៩ |
| ៦ | សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ | ៦៥៩ | 680 | ៧៣៩ | ១.០៣៣ | ៦០៩ | ៣.៧២០ |
| ៧ | សំបុត្រមរណភាព | ៥៣១ | ៥៩៦ | ៦០៩ | ៧៩៨ | ៧៥០ | ៣២៨៤ |
| ៨ | សេចក្តីចម្លងសំបុត្រមរណភាព | ៤៥០ | ៤០៧ | ៦៣០ | ៧៥១ | ៦៣០ | ២៨៥៨ |

<u>**ប្រភព៖**</u>*របាយការណ៍របស់ក្រុមប្រឹក្សាខណ្ឌមានជ័យអាណត្តិទី១*

របាយការណ៍ខាងលើនេះបានបង្ហាញពី សមិទ្ធផលការងាររបស់សង្កាត់នីមួយៗ ក្នុងសាលាខណ្ឌមានជ័យក្នុងអាណត្តិទីមួយដែលបានធ្វើកន្លងមក ស្តីពីការងារអត្រានុកូលដ្ឋាន។ យើងនឹងធ្វើការវិភាគទៅលើសមិទ្ធផលនេះ ជាមួយនិងមតិរបស់មន្ត្រីទាក់ទងនិងការងារអត្រានុកូលដ្ឋាននេះ។

បើយោងទៅលើ តារាងខាងលើបានបង្ហាញឲ្យយើងឃើញពីតម្រូវការរបស់ប្រជាពលរដ្ឋយ៉ាងលើសលប់ទាក់ទង និងការងារអត្រានុកូលដ្ឋាននេះគឺយើងឃើញថា ប្រជាពលរដ្ឋមានតម្រូវការទៅលើសំបុត្របញ្ជាក់កំណើតមានចំនួនច្រើនជាងសំបុត្រអត្រានុកូលដ្ឋានផ្សេងៗ និងមានការកើនឡើងជាលំដាប់រៀងរាល់ឆ្នាំ។ ផ្ទុយទៅវិញ សេចក្តីចម្លងសំបុត្រមរណៈភាពមានចំនួនតិចជាងគេ ប៉ុន្តែមានការកើនឡើងជាលំដាប់រៀងរាល់ឆ្នាំផងដែរ ។ ដូចនេះ វាបានសបញ្ជាក់ពីតម្រូវការរបស់ប្រជាពលរដ្ឋយ៉ាងច្រើនលើសលប់ក្នុងការទទួលសេវា បើប្រៀបធៀបទៅ និងការទទួល សេវាផ្សេងៗទៀតក្នុងមូលដ្ឋាន។ ជាងនេះទៅទៀតមន្ត្រីបានលើកឡើងថា ចំពោះបញ្ហាអត្រានុកូលដ្ឋាននេះ មន្ត្រីមានការយល់ដឹងច្រើនពីបញ្ហាអត្រានុកូលដ្ឋាននេះ ពីព្រោះមានការបណ្តុះបណ្តាលជា ញឹកញាប់តាមរយៈការអញ្ជើញ ឲ្យចូលរួមពីសំណាក់មន្ត្រីអង្គភាពមូលដ្ឋាន និងអង្គការ PLANE ។ ម៉្យាងវិញទៀត មានការធ្វើយុទ្ធនាការអត្រានុកូលដ្ឋាននៅក្នុងឆ្នាំ ២០០៥ របស់ក្រសួងមហាផ្ទៃ និងអង្គការ PLANE គឺចុះធ្វើសំបុត្រអត្រានុកូលដ្ឋាននេះដល់ប្រជាពលរដ្ឋបានគ្រប់ៗគ្នាដល់លំនៅឋានតែម្តង និងមិនមានការបង់សេវានោះទេ។ ជាងនេះទៅទៀត គឺរាល់ការធ្វើសំបុត្រអត្រានុកូលដ្ឋាននេះ គឺមន្ត្រីធ្វើឡើងដោយផ្អែកទៅតាមលិខិតគតិយុត្តិជាចម្បងដូចជា ច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ អនុក្រឹត្យលេខ ១៨៣ អណក្រ បក ចុះថ្ងៃទី០៣ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីអំពីការកំណត់បែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស អនុក្រឹត្យលេខ ១០៣ អនក្រ បក ស្តីពីអត្រានុកូលដ្ឋាន និងលិខិតបទដ្ឋានជាច្រើនទៀតដែលពាក់ព័ន្ធ មិនមានការពឹងផ្អែកទៅលើទំនៀមទំលាប់នោះទេ ។ លើសពីនេះទៅទៀត ចំពោះរយៈពេលនៃការផ្តល់សេវានេះ គឺមន្ត្រីមានការផ្តល់ជូនយ៉ាងទាន់ពេលវេលា និងតាមតម្លៃដែលសាលារាជធានីបានធ្វើសេចក្តីណែនាំ និងមានការធ្វើវិក័យបត្រ័ជូនផងដែរ វៀរលែងតែមានការខ្វះខាតសៀវភៅបញ្ជី ដែលក្រសួងមហាផ្ទៃផ្តល់ជូនដល់សាលាសង្កាត់តែប៉ុណ្ណោះ។ ក្នុងនោះដែរបើទោះបីជាមន្ត្រីមានការអះអាង ពីអត្ថប្រយោជន៍ជាច្រើនទាក់ទងទៅ និងយុទ្ធនាការរវាងក្រសួងមហាផ្ទៃ និងអង្គការ PLANE ក៏ប្រជាពលរដ្ឋមួយចំនួនតូច នៅតែគ្មានសំបុត្រអត្រានុកូលដ្ឋានដដែល គឺមិនបានគ្រប់ៗគ្នានោះទេ នេះបើយើងទៅលើ ការសាកសួរទៅលើប្រជាពលរដ្ឋផ្ទាល់។ នេះក៏បានសបញ្ជាក់ពីភាពខ្វះចន្លោះ បន្តិចបន្តួចនៃការអនុវត្តន៍ការងាររបស់មន្ត្រីមួយចំនួនដែរ ទើបបណ្តាលឲ្យមានបញ្ហាបែបនេះកើតឡើង ។ ម្យ៉ងវិញទៀត ដោយសារតែមន្ត្រីអនុវត្ត

ការងារអត្រានុកូលដ្ឋាននេះដោយមានការពឹងផ្អែក ទៅលើតែលិខិតបទដ្ឋានគតិយុត្តដែលមាន ជាធរមាន ទាក់ទងទៅ និងលក្ខខណ្ឌ និងឯកសារដើម្បីទទួលបាននូវលិខិតអត្រានុកូលដ្ឋាននេះ ទើបធ្វើឲ្យមន្ត្រី មានការទាមទានូវឯកសារច្បាប់គ្រប់គ្រាន់ ទើបមន្ត្រីសម្រេចធ្វើសំបុត្រ អត្រានុកូលដ្ឋាននេះជូន ប៉ុន្តែប្រជាពលរដ្ឋមួយចំនួនមិនបានយល់បែបនេះទេ បែរជាមានការអ៊ូរទាំ យល់ថារដ្ឋបាលមានលក្ខណៈស្មុគស្មាញទៅវិញ នេះហើយជាបញ្ហាប្រឈមចំពោះមន្ត្រី និង ប្រជាពលរដ្ឋ។

ដូចនេះ ក្នុងការងារអត្រានុកូលដ្ឋាន ក្នុងខណ្ឌមានជ័យ គឺមានការសហការល្អ និងមិនមាន ភាពបញ្ហាអវិជ្ជមានធ្ងន់ធ្ងរដែលមិនអាចស្វែងរកដំណោះស្រាយនោះទេ ម្យ៉ាងវិញទៀត ប្រជាពលរដ្ឋ ក៏បានបង្ហាញពីបញ្ហាវិជ្ជមានជាច្រើនទាក់ទងនិងការងារអត្រានុកូលដ្ឋាន ប៉ុន្តែទន្ទឹមនឹងនេះ បញ្ហា អវិជ្ជមានប្រាកដជាមានបន្តិចបន្តួចក្នុងការងារនេះ ដោយប្រជាពលរដ្ឋមួយចំនួនតូចមិនបានមកធ្វើ សំបុត្រអត្រានុកូលដ្ឋាន ដោយខ្លួនផ្ទាល់បែរជាពឹងទៅមន្ត្រីសង្កាត់ខ្លះជួយរត់ការខាងក្រៅ ហើយឲ្យ កំរៃសេវាលើសពីការកំណត់ក្នុងប្រកាសអន្តរក្រសួង និងសេចក្តីណែនាំរបស់ក្រសួងមហាផ្ទៃ ដែល កត្តាបែបនេះហើយទើបបានជាមាន អំពើពុករលួយកើតឡើងក្នុងមូលដ្ឋាន។ នេះជាបញ្ហាអវិជ្ជមាន ដែលបង្ករឡើងដោយ មន្ត្រី និងប្រជាពលរដ្ឋក្នុងមូលដ្ឋាន។

### ៣.១.២. ការវិភាគលើសេវាសុខាភិបាលក្នុងមូលដ្ឋាន

សាលាខណ្ឌមានជ័យបាន យកចិត្តទុកដាក់ទៅលើសេវាសុខាភិបាលយ៉ាងយកចិត្តទុកដាក់ ពីព្រោះ ដើម្បីរួមចំណែកក្នុងការថែរក្សាសុខុមាលភាពប្រជាពលរដ្ឋ និងដើម្បីចូលរួមចំណែកក្នុងការ កាត់បន្ថយភាពក្រីក្រផងដែរ។ សាលាខណ្ឌមានជ័យបានបង្កើតឲ្យមាននូវមណ្ឌលសុខភាពគ្រប់ សង្កាត់ទាំងអស់ក្នុងមូលដ្ឋាន។ លើសពីនេះទៅទៀត សាលាខណ្ឌមានជ័យបានសហការជាមួយ និងអង្គការURC ( University Research Co ) បង្កើតឲ្យមានប័ណ្ណមូលនិធិសមធម៌ជូនគ្រួសារ ប្រជាពលរដ្ឋក្នុងមូលដ្ឋានផ្ទាល់ ។ដោយក្នុងប័ណ្ណនេះ គឺមានការផ្តល់ជូនតែគ្រួសារនៃ ប្រជាពលរដ្ឋ ក្រីក្រក្នុងខណ្ឌមានជ័យតែប៉ុណ្ណោះ ហើយម្យ៉ាងវិញទៀតការទទួលបាននូវប័ណ្ណនេះមានន័យថា គ្រួសារ នៃប្រជាពលរដ្ឋក្រីក្រទាំងមូល មានអ្នកបង់សេវាសុខាភិបាលជំនួសតែម្តង បូករួមទាំងថ្លៃ បាយទឹក រាល់ពេលសំរាកពេទ្យ ការផ្តល់សេវាជូនអ្នកកំដរ និងសេវាសោហ៊ុយធ្វើដំណើរផងដែរ ហើយម្យ៉ាងវិញទៀត បណ្ណ័មូលនិធិសមធម៌នេះ មិនមានការដកហូតមកវិញ ក្នុងករណីគ្រួសារក្រីក្រ នោះមានជីវភាពប្រសើរឡើងជាងមុនក៏ដោយ ជាងនេះទៅទៀតការពិនិត្យ និងព្យាបាលសុខភាព តាមរយៈ បណ្ណ័សមធម៌នេះ គឺបើសិនជាក្នុងមណ្ឌលសុខភាពមិនមានលទ្ធភាពព្យាបាល នោះ

មណ្ឌលសុខភាពនោះ នឹងបញ្ជូនទៅព្យាបាលនៅមន្ទីពេទ្យរុស្សី។ ហេតុដូចនេះហើយទើបប្រជាពលរដ្ឋនៅក្នុងមូលដ្ឋាន មានភាពងាយស្រួលក្នុងការថែរក្សាសុខភាពរបស់ខ្លួនផ្ទាល់ ទោះបីជាប្រជាពលរដ្ឋដែលគ្មានប្រាក់ដើម្បីព្យាបាលជម្ងឺក៏ដោយ។ ទោះជាបែបនេះក្តី ដោយយោងទៅលើការសាកសួរពីសំណាក់មន្ត្រី និងប្រជាពលរដ្ឋក្នុងសង្កាត់ទាក់ទង និងបញ្ហាសុខាភិបាលនេះ យើងទទួលបានថាទោះជាមានការផ្តល់ជូនបែបនេះក្តី ប៉ុន្តែមានការកំណត់ចំនួនគ្រួសារក្រីក្រនៅក្នុងសង្កាត់ដែល ត្រូវបានទទួលបណ្ណ័នេះពីខាងសាលាខណ្ឌ ហេតុដូច្នេះហើយទើបបណ្តាលឲ្យប័ណ្ណមូលនិធិសមធម៌នេះមិនបានផ្តល់ជូនបានគ្រប់ចំនួននៃគ្រួសារក្រីក្រក្នុងសហគមន៍ទេ ។

ជាងនេះទៅទៀតក៏មានផលអវិជ្ជមានចំពោះ បញ្ហាឥរិយាបទ របស់គ្រូពេទ្យចំពោះអ្នកជម្ងឺផងដែរគឺមានការរើសអើងមួយចំនួនទៅលើអ្នកជម្ងឺ ដែលមានសភាពក្រីក្រខ្លាំងមានសំលៀកបំពាក់មិនសមរម្យនោះ ទោះជាក្រុមគ្រូពេទ្យនោះបានទទួលការ ណែនាំក្នុងពេលប្រជុំទាក់ទង និងបញ្ហានេះក៏ដោយ។ ដូចគ្នានេះដែរ ប្រជាពលរដ្ឋក៏ដូចគ្នា មានប្រជាពលរដ្ឋមួយចំនួនបានគិតថា អាងតែខ្លួនមានបណ្ណ័បានទាមទា និងបញ្ហាឲ្យពេទ្យផ្តល់នូវថ្នាំដែលខុសពីអាការៈនៃអ្នកជម្ងឺ ។ ដូចជាមានករណីជាក់ស្តែងមួយកើតឡើងក្នុងមណ្ឌលសុខភាពខណ្ឌមានជ័យ ដោយប្រជាពលរដ្ឋមកទទួលសេវានេះ មានជម្ងឺផ្តាសាយលក្ខណៈស្រាល ប៉ុន្តែបែជាទាមទាឲ្យគ្រូពេទ្យដាក់នូវសារ៉ូមជូន ប៉ុន្តែនៅពេលដែលគ្រូពេទ្យ លើកឡើងថាលេបតែថ្នាំតាមវិជ្ជបញ្ជា គឺវានឹងជាសះស្បើយ បែជាប្រជាពលរដ្ឋយល់ថាមិនមានការថែទាំបានល្អទៅវិញ។ ហេតុដូច្នេះហើយ ទើបមានការនិយាយតៗគ្នាពីបញ្ហានេះធ្វើឲ្យប្រជាពលរដ្ឋក្រីក្រដែលមានបណ្ណ័នេះ មិនបានមកទទួលសេវាសុខាភិបាលតាមរយៈបណ្ណ័នេះទេដោយទុកប័ណ្ណនេះចោល។ ដូចនេះយើងយល់ថា សេវាថែទាំសុខភាព នៅមិនទាន់មានភាពរលូននៅឡើយទេ ដែលកត្តាទាំងអស់នេះកើតឡើងពី មន្ត្រី និងប្រជាពលរដ្ឋខ្លួនឯងផ្ទាល់ និងទាមទារឲ្យមានការពន្យល់ណែនាំបន្ថែមពីសំណាក់ អជ្ញាធរដែលពាក់ព័ន្ធទៅលើមន្ត្រីសុខាភិបាលមូលដ្ឋាន និងប្រជាពលរដ្ឋបន្ថែមទៀត។

### ៣.១.៣. ការវិភាគលើសេវាអប់រំ

ការអប់រំ ក៏ជាវិស័យអាទិភាពមួយក្នុង ចំនោមចង្កោម នៃសេវាធារណៈ ហើយក៏ជាចំនុចចម្បងក្នុងការអភិវឌ្ឍន៍នៃ គោលការណ៍អភិបាលកិច្ចល្អផងដែរ។ ក្នុងនោះដែរសាលាខណ្ឌមានជ័យបានយកចិត្តទុកដាក់ជាទីបំផុត ក្នុងការបង្កើន ជម្រុញ និងបណ្តុះនូវធនធានមនុស្សនេះ។

តាមរយៈការយកចិត្តទុកដាក់នេះ សាលាខណ្ឌមានជ័យ បានបង្កើនគ្រឹះស្ថានអប់រំជាច្រើនកន្លែង និងមានការបង្កើតនូវកម្មវិធីមូលដ្ឋានផ្សេងៗ ក្នុងការផ្សព្វផ្សាយក្នុងកិច្ចនៃវិស័យអប់រំ ។

**ក. ស្ថិតិសាលារដ្ឋ**

- សាលាបឋមមានចំនួន ២៩ សាលា
- អនុវិទ្យាល័យមានចំនួន ០សាលា
- វិទ្យាល័យមានចំនួន ០៤ សាលា
- វិទ្យាស្ថានពាណិជ្ជសាស្ត្រចំនួន ០១

**ខ. ស្ថិតិសាលាឯកជន**

- សាលាមត្តេយ្យចំនួន ១១ សាលា
- សាលាបឋមមានចំនួន ២៣ សាលា
- សាកលវិទ្យាល័យចំនួន ០២ សាលា

**គ. ការងារសាងសង់**

- បានសាងសង់អគារសិក្សាចំនួន ០៤ខ្នង មាន ៥៧ បន្ទប់ អនុវិទ្យាល័យ ហ៊ុន សែន ព្រែកប្រា ០១ខ្នង សាលាបឋមសិក្សាហ៊ុន សែន ចាក់អង្រែ ០១ខ្នង អនុវិទ្យាល័យវត្តដំបូកខ្ពស់ និងអនុវិទ្យាល័យ ប៊ុន រ៉ានី ហ៊ុន សែន ព្រែកថ្មី ០១ ខ្នង ។

ដោយយោងទៅលើស្ថិតិ ដែលបានមកពីរបាយការណ៍ របស់ក្រុមប្រឹក្សាខណ្ឌមានជ័យអាណត្តិទីមួយខាងលើ បានស្តែងឲ្យឃើញពីសមិទ្ធផលជាច្រើនក្នុងការសាងសង់នូវគ្រឹះស្ថានអប់រំរបស់រដ្ឋ និងកិច្ចសហប្រតិបត្តការជាមួយ និងគ្រឹះស្ថានអប់រំឯកជន ជាងនេះទៅទៀតវាបានបង្ហាញពីកិច្ចខិតខំប្រឹងប្រែង របស់រាជរដ្ឋាភិបាល និងមន្ត្រីនៃសាលាខណ្ឌមានជ័យទាំងមូលក្នុងការបណ្តុះនូវធនធានមនុស្ស ក៏ប៉ុន្តែទន្ទឹម និងមាននូវគ្រឹះស្ថានដែលកើនឡើងជាបន្តបន្ទាប់នេះ ក៏មានការសហការពីប្រជាពលរដ្ឋតាមរយៈតម្រូវការរបស់ប្រជាពលរដ្ឋផ្ទាល់ ទើបជម្រុញឲ្យមានការបង្កើតនូវគ្រឹះស្ថានអប់រំនេះជាបន្តបន្ទាប់តាមតម្រូវការនេះ។ ផ្ទុយទៅវិញ បើសិនជាប្រជាពលរដ្ឋ មិនមានការយល់ដឹងពីអត្ថប្រយោជន៍នៃការអប់រំទេ ប្រជាពលរដ្ឋនឹងមិនបញ្ជូនកូនៗ ឲ្យទៅទទួលនូវសេវាអប់រំនេះនោះទេ។

ជាការពិតណាស់ ក្រៅអំពីការវិភាគទៅតាមតែរបាយការណ៍នេះ គឺយើងវិភាគទៅលើមតិរបស់មន្ត្រី និងប្រជាពលរដ្ឋក្នុងថ្នាក់មូលដ្ឋានផ្ទាល់ស្តីពី ការផ្តល់សេវាអប់រំនេះជូនប្រជាពលរដ្ឋ ។ មន្ត្រីបានលើកឡើងថា ដោយសារតែប្រទេសកម្ពុជាធ្លាប់បានឆ្លងកាត់នូវសង្គ្រាមរ៉ាំរ៉ៃជាច្រើនទសវត្ស

មកហើយ ហើយអ្វីដែលសំខាន់នោះក្នុងសម័យសង្គ្រាម នៃរបបកម្ពុជាប្រជាធិបតេយ្យ មានការសម្លាប់នូវបញ្ញាវន្ត័ និងធនធានមនុស្សជាច្រើន ស្ទើរតែគ្មានសេសសល់ ទើបបណ្តាលឲ្យមានការខ្វះខាតនូវធានធានមនុស្សក្នុងប្រទេសកម្ពុជា។ ជំហានដំបូង នៃការជម្រុញឲ្យមាននូវធនធានមនុស្សគឺមានការសាងសង់ជាគ្រឹះស្ថានក្នុងជំហានទីមួយ និងមានការផ្សព្វផ្សាយបន្ថែមទៀត ដើម្បីឲ្យប្រជាពលរដ្ឋបានដឹងពីអ្វីដែលមូលដ្ឋានកំពុងតែធ្វើ។ ហើយរហូតមកដល់ពេលនេះ គឺមានប្រជាពលរដ្ឋភាគច្រើនបានចូលគ្រឹះស្ថានអប់រំ។

ទោះជាយ៉ាងនេះក្តី ចំពោះការសាកសួរទៅលើប្រជាពលរដ្ឋមួយចំនួននោះ គឺបានបង្ហាញឲ្យយើងឃើញថា បញ្ហាធនធានមនុស្សនៅថ្នាក់មូលដ្ឋានពិតជាមានផលអវិជ្ជមានមួយចំនួនតូច។ ប្រជាពលរដ្ឋដែលស្ថិតក្នុងបន្ទាត់នៃភាពក្រីក្រខ្លាំងនោះ នៅតែមិនមានលទ្ធភាពបញ្ជូនកូន ឲ្យទៅសិក្សានៅសាលាអប់រំ បើទោះបីជាប្រជាពលរដ្ឋបានយល់ពីគុណសម្បត្តិ និងគុណវិបត្តិនៃចំនេះដឹងដែលបានមកពីគ្រឹះស្ថានអប់រំក៏ដោយ ដោយសារតែគ្មានលទ្ធភាពគ្រប់គ្រាន់។ លើសពីនេះទៅទៀតក៏មានបញ្ហាអវិជ្ជមានទាក់ទងទៅនឹងគ្រូបង្រៀននៅតាមគ្រឹះស្ថានអប់រំរដ្ឋផងដែរ គឺដោយសារតែប្រាក់បៀវត្សន៍មានកម្រិត ទើបធ្វើឲ្យគ្រូមួយចំនួនតូច បានប្រមូលលុយបន្ថែមក្នុងម៉ោងសិក្សា វាជាហេតុធ្វើឲ្យសិស្សមួយចំនួនដែលក្រីក្រ គ្មានលទ្ធភាពបានចូលរៀនដូចគេ ។

## ៣.២. ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន

ការចូលរួមនៅក្នុងបរិបទនៃ អភិបាលកិច្ចល្អ គឺសំដៅទៅលើការចូលរួមពីសំណាក់ប្រជាពលរដ្ឋទាំងប្រុសទាំងស្រីក្នុងដំណើរការធ្វើសេចក្តីសម្រេចនោះ។ ដូចគ្នានេះដែរបើយោងទៅតាមការសាកសួរពីសំណាក់មន្ត្រីក្នុងមូលដ្ឋាន ក្នុងខណ្ឌមានជ័យយើងឃើញថាមន្ត្រីសង្កាត់មានការខ្វាយខ្វល់និងជម្រុញឲ្យសម្មភាពចូលរួម កាន់តែមានភាពល្អប្រសើរឡើងតាមរយៈការផ្សព្វផ្សាយដល់ប្រជាពលរដ្ឋពីសំណាក់មន្ត្រី ក្នុងមូលដ្ឋាន អំពីសារៈសំខាន់ និងភាពចាំបាច់នៃការចូលរួមរបស់ប្រជាពលរដ្ឋខិតខំផ្សព្វផ្សាយពត៌មានស្តីពីកិច្ចប្រជុំ និងពត៌មានផ្សេងៗឲ្យបានទូលំទូលាយដល់ប្រជាពលរដ្ឋ និងបានកំណត់ពេលវេលា និងកន្លែងប្រជុំយ៉ាងសមស្រប ។

ជាងនេះទៅទៀត មន្ត្រីឃុំ សង្កាត់ តែងតែខិតខំស្វែងរកនូវឱកាសជាច្រើនដើម្បីឲ្យប្រជាពលរដ្ឋបានចូលរួមក្នុង មូលដ្ឋាន និងបានប្រើប្រាស់នូវភាពជាម្ចាស់នៃមូលដ្ឋានរបស់ខ្លួនយ៉ាងទូលំទូលាយបើកចំហរ និងគ្មានការគំរាមគំហែង។ កម្មវិធីដែលតែងតែមានការចូលរួមពីសំណាក់ប្រជាពលរដ្ឋក្នុងមូលដ្ឋានមានដូចជា ៖

- ការប្រជុំនៅ ថ្នាក់ភូមិ ក្នុងជំហានទី២ និងជំហានទី១១ នៃដំណើរការផែនការអភិវឌ្ឍន៍ ឬ កម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់។
- ការកំណត់ទីតាំងគម្រោង
- ការសិក្សាផលប៉ះពាល់បរិស្ថាន ក្នុងការធ្វើការអភិវឌ្ឍន៍
- ការប្រជុំដេញថ្លៃគម្រោង
- ការតាមដានត្រួតពិនិត្យលើការអនុវត្តន៍កិច្ចសន្យាឃុំសង្កាត់ជាមួយក្រុមហ៊ុនទទួលធ្វើ គម្រោង
- ការប្រជុំរបស់គណៈកម្មាការគ្រប់គ្រងគម្រោង
- ការផ្តល់ពត៌មាននានាជុំវិញការអនុវត្តន៍គម្រោង
- វេទិការសាធារណៈ

រាល់គម្រោងខាងលើ សុទ្ធតែមានការចូលរួមសហាការពីសំណាក់ប្រជាពលរដ្ឋ។ ប៉ុន្តែក្នុងការចូលរួមនេះដែរគឺ មានតែការចូលរួមក្នុង វេទិការសាធារណៈតែប៉ុណ្ណោះ ដែលប្រជាពលរដ្ឋចូលរួមបានច្រើនជាងគេ ដោយសារតែប្រជាពលរដ្ឋបានយល់យ៉ាងច្បាស់ពីផលប្រយោជន៍ទាក់ទងទៅនឹងវេទិការសាធារណៈនេះ ម៉្យាងវិញទៀតប្រជាពលរដ្ឋមានការចង់ដឹង ពីការប្រែប្រួលនៃសភាពការណ៍មូលដ្ឋាន និងអត្ថប្រយោជន៍នៃ ការជួបផ្ទាល់នៃថ្នាក់ដឹកនាំ។ ហេតុដូច្នេះហើយទើប មានការចូលរួមពីសំណាក់ប្រជាពលរដ្ឋយ៉ាងច្រើននៅក្នុង ការបញ្ចេញមតិផ្សេងៗនៅក្នុង វេទិកាសាធារណៈដែលមន្ត្រីសង្កាត់តែងតែអនុវត្តន៍ តាមរយៈសេចក្តីណែនាំរបស់សាលាក្រុងក្នុងការបើកវេទិកាសាធារណៈយ៉ាងតិចមួយដងក្នុងមួយខែ ប៉ុន្តែក្នុងសង្កាត់ខ្លះដោយសារមន្ត្រីបានដឹងពីបញ្ហាអវិជ្ជមានក្នុងមូលដ្ឋានច្រើនទើបមានការ បើកវេទិការសាធារណៈនេះក្នុងមួយខែ ពីរ ទៅ បីដង និងមានការសហាការគ្នាយ៉ាងស្អិតរមួតពីសំណាក់ប្រជាពលរដ្ឋតាមរយៈការផ្តល់ជាព័ត៌មាន និងបញ្ហាអវិជ្ជមានទាន់ពេលវេលា។ ទោះជាបែបនេះក្តី បញ្ហាមួយចំនួនក៏នៅតែកើតមានចំពោះ ប្រជាពលរដ្ឋក្នុងមូលដ្ឋាន។ នេះបើយោងតាមការសាកសួរផ្ទាល់ពីសំណាក់មន្ត្រីសាលាសង្កាត់គឺយើងឃើញថា មានប្រជាពលរដ្ឋភាគច្រើនហ៊ានបញ្ចេញមតិ គ្រប់បញ្ហាទាក់ទង និងផលវិបាក ទុក្ខកង្វល់ ឬ ការមិនពេញចិត្តមួយចំនួនក្នុងមូលដ្ឋាន ប៉ុន្តែចំពោះបញ្ហាគ្រឿងញៀន និងល្បែងខុសច្បាប់ដែលប្រជាពលរដ្ឋបានដឹងគឺ ប្រជាពលរដ្ឋនៅតែមានភាពភ័យខ្លាចពីសុវត្ថិភាពក្នុងការបញ្ចេញមតិក្នុង វេទិការជាសាធារណៈ ផ្ទុយទៅវិញប្រជាពលរដ្ឋតែងតែផ្តល់ពត៌មានដល់សង្កាត់តាមរយៈប្រអប់សំបុត្រ ឬតាមទូរស័ព្ទទៅមន្ត្រីសង្កាត់ ជាហេតុធ្វើឲ្យពេលខ្លះខាងសង្កាត់មានការយឺតពេលបន្តិចបន្តួចក្នុងការដោះស្រាយនូវបញ្ហានោះ ។ ម៉្យាងវិញទៀត ប្រជាពលរដ្ឋមួយចំនួនក្នុងមូលដ្ឋាន ដែលមានភាគតិច

មិនបានចូលរួមក្នុងការសម្រេចចិត្តផ្សេងៗដែលអាជ្ញាធរបានផ្តល់ឲ្យនោះ គឺដោយសារtEប្រជាពលរដ្ឋមួយចំនួននោះមានជីវភាពនៅមានកម្រិត ទើបមានការរវល់នឹង ស្វះស្វែងតែចំពោះបញ្ហាជីវភាព និងមិនខ្វាយខ្វល់ពីភាពជាម្ចាស់មូលដ្ឋានរបស់ខ្លួន ។

## ៣.៣ ការវិភាគនៅលើការទទួលខុសត្រូវ និងគណនេយ្យភាព

ចំពោះការទទួលខុសត្រូវ និងគណនេយ្យភាព ក្នុងមូលដ្ឋានពិតជាមានសារៈសំខាន់ណាស់ក្នុងការជម្រុញឲ្យមាន អភិបាលកិច្ចល្អក្នុងមូលដ្ឋាន។ ដែលក្នុងនេះដែរយើងបានលើកយកមកនូវវិភាគនូវការទទួលខុសត្រូវ និងគណនេយ្យភាពរបស់តំណាងរបស់ប្រជាពលរដ្ឋឃុំ សង្កាត់ ពីព្រោះតំណាងក្នុងមូលដ្ឋាននេះ បានកើតឡើងដោយការបោះឆ្នោត ដោយផ្ទាល់ពីសំណាក់ ប្រជាពលរដ្ឋក្នុងមូលដ្ឋាន។ ដែលតំណាងនោះរួមមាន ៖

- ក្រុមប្រឹក្សាឃុំ សង្កាត់
- គណៈកម្មាធិការកសាងផែនការ និងថវិកា
- គណៈកម្មាការលទ្ធកម្ម
- គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ
- ក្រុមប្រើប្រាស់ និងថែទាំលទ្ធផលគម្រោង
- គណៈកម្មាការធនធានធម្មជាតិ
- អង្គការសហគមន៍មូលដ្ឋាន ...។ ល ។

អ្នកតំណាងខាងលើ គឺជាអ្នកតំណាងរបស់ប្រជាពលរដ្ឋផ្ទាល់ ដោយធ្វើការសម្រេចចិត្តក្នុងនាមប្រជាពលរដ្ឋក្នុងមូលដ្ឋានរបស់ខ្លួន ។ ដោយយោងទៅតាមការសាកសួរ ពីសំណាក់មន្ត្រីមូលដ្ឋានបានបង្ហាញថា មន្ត្រីក្នុងមូលដ្ឋានតែងតែទទួលខុសត្រូវចំពោះទង្វើរបស់ខ្លួនជូនប្រជាពលរដ្ឋ តាមរយៈការរាយការណ៍ ព្រមទាំងបញ្ជាក់ពីមូលហេតុ ដែលខ្លួនបានធ្វើការសម្រេចចិត្ត និងអនុវត្តន៍។ មូលហេតុដែលមន្ត្រីហ៊ានអះអាងថាមាន ការទទួលខុសត្រូវ និងគណនេយ្យភាព ក្នុងមូលដ្ឋាននោះពីព្រោះ ក្នុងការប្រជុំកំណត់ទីតាំងគម្រោង ការអនុម័តនូវគម្រោង គឺមានការប្រជុំពីសំនាក់ប្រជា-ពលរដ្ឋគ្រប់មជ្ឈដ្ឋាន គ្រប់គណបក្សនយោបាយ និងក្រុមប្រឹក្សាដែលជាតំណាងប្រជាពលរដ្ឋក្នុងមូលដ្ឋានចូលរួម ។ បន្ទាប់ពីនោះ ក្រោយពេលអនុម័តគម្រោង ក៏មានការប្រជុំដេញថ្លៃម្តងទៀតដែលរួមមានតួអង្គដូចបានរៀបរាប់ខាងលើ និងមានគណៈកម្មាការលទ្ធកម្មឃុំ សង្កាត់ ចូលរួមផងដែរ។ ប៉ុន្តែផ្ទុយទៅវិញ នៅក្នុងការកំណត់ទីតាំងគម្រោង គឺប្រជាពលរដ្ឋមួយចចំនួនតូចក៏មានការមិនពេញចិត្តដែរ។ ដូចនេះយើងអាចបង្ហាញថា ការទទួលខុសត្រូវ ក្នុងថ្នាក់ឃុំ សង្កាត់ពិតជាមាន ប៉ុន្តែគ្រាន់តែមានភាពខ្វះចន្លោះមួយចំនួនតែប៉ុណ្ណោះ ។

## ៣.៤. ការវិភាគលើសមត្ថភាពមន្ត្រីក្នុងការជម្រុញអភិបាលកិច្ចល្អ

ជាការពិតណាស់ ក្នុងការអនុវត្តន៍នៃគោលការណ៍អភិបាលកិច្ចល្អនេះមានភាពប្រសើរណាស់ក្នុងសាសាខណ្ឌមានជ័យ ប៉ុន្តែក្នុងនោះដែរក៏មានកង្វះខាតមួយផ្នែកតូចដែលទាក់ទងទៅនិងមន្ត្រី និងប្រជាពលរដ្ឋ។

ចំពោះមន្ត្រីក្នុងសង្កាត់ ក៏ដូចជាមន្ត្រីនៃសាលាខណ្ឌមានជ័យសុទ្ធតែធ្លាប់បានអញ្ជើញឲ្យចូលរួមក្នុងការបណ្តុះបណ្តាល សិក្ខាសាលា និងវគ្គខ្លីៗ ស្តីពីអភិបាលកិច្ចល្អ ។ ការចូលរួមនេះដែរ គឺតាមរយៈ អង្គការមិនមែនរដ្ឋាភិបាល ដោយអង្គការទាំងនេះតែងតែគាំទ្រការបណ្តុះបណ្តាល និងការកសាងសមត្ថភាពជូនមន្ត្រី។ លើសពីនេះទៅទៀត ក៏មាននាយកដ្ឋានរដ្ឋបាលមូលដ្ឋាន របស់សាលារាជធានីភ្នំពេញដែលជាសេនាធិកាចំពោះការងារទាំងអស់ទាក់ទង វិមជ្ឈការ និងការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ។ នាយកដ្ឋាននេះទទួលការពិនិត្យតាមដាន ការវាយតម្លៃ រាយការណ៍អំពីសមត្ថភាព និងធនធានរបស់ក្រុមប្រឹក្សា ឃុំ សង្កាត់ និង ស្មៀន។ នាយកដ្ឋាននេះត្រូវបានធានាថាវិធានការត្រឹមត្រូវសម្រាប់ការបណ្តុះបណ្តាល និងកសាងសមត្ថភាព ដែលរួមមានការអប់រំសាធារណៈជនផងដែរ។

**តារាងទី១០៖** ការអភិវឌ្ឍន៍សមត្ថភាព

| ល.រ | ការបរិយាយ | ចំនួន | | | | | |
|---|---|---|---|---|---|---|---|
| | | ២០០៩ | ២០១០ | ២០១១ | ២០១២ | ២០១៣ | សរុប |
| ១ | វគ្គសិក្សា | ៩៤ | ១០០ | ៩០ | ៦៧ | ៨៣ | ៤៣៤ |
| ២ | សិក្ខាកាមសរុបដែលបានចូលរួមវគ្គសិក្សា | ៩៤៣ | ១.១០៩ | ១.០២៤ | ៩២៥ | ១.៣០១ | ៥.៣០២ |
| ៣ | សិក្ខាកាមជាស្ត្រីដែលបានចូលរួមវគ្គសិក្សា | ៥៩៧ | ៧១១ | ៧៦០ | ៧០៦ | ៧៥៥ | ៣.៥១១ |

**ប្រភព៖** *របាយការណ៍របស់ក្រុមប្រឹក្សាខណ្ឌមានជ័យអាណត្តិទី១*

ជាការពិតណាស់ សមិទ្ធផលដែលបានធ្វើកន្លងមកនេះខណ្ឌមានជ័យ បានធ្វើការកសាងសមត្ថភាពទៅលើមន្ត្រី យ៉ាងយកចិត្តទុកដាក់ និងមានការសហការពីមន្ត្រីជាច្រើន។ បើយើងក្រឡេកមើលទៅលើតារាងសមិទ្ធផលទាក់ទង និងសមត្ថភាពមន្ត្រីក្នុងការចូលរួមក្នុងសិក្ខាសាលាផ្សេងៗគឺយើងឃើញថា វគ្គសិក្សាសម្រាប់មន្ត្រីមានមានការថយចុះក្នុងឆ្នាំ២០១២ ប៉ុន្តែមានការកើនឡើងខ្ពស់ក្នុងឆ្នាំ២០១០ ហើយសិក្ខាកាមជាស្ត្រីក៏មានការកើនឡើងជាលំដាប់។

ជាក់ស្តែង ក្នុងការសាកសួរផ្ទាល់ពីសំណាក់មន្ត្រីក្នុងសង្កាត់ទាំងបួន ក្នុងខណ្ឌមានជ័យគឺយើងឃើញថា មន្ត្រីដែលទទួលបានការបណ្តុះបណ្តាលនេះ គឺបានទទួលនូវការយល់ដឹងយ៉ាងច្រើនទាក់ទង និងគោលការណ៍អភិបាលកិច្ចល្អនេះ ប៉ុន្តែទន្ទឹមនឹងនេះក៏មានបញ្ហាប្រឈមមួយចំនួន

ទាក់ទងនឹង ការកសាងសមត្ថភាពមន្ត្រីគឺ ចំពោះការអញ្ជើញពីសំណាក់ ស្ថាប័នរដ្ឋទាក់ទង និង សិក្ខាសាលាផ្សេងៗ និងវគ្គខ្លីៗគឺមិនមានការចូលរួមបានគ្រប់មន្ត្រីនោះទេ ភាគច្រើនអ្នកដែលចូលរួមទទួលនូវចំនេះដឹងទាក់ទងនឹងអភិបាលកិច្ចនេះគឺមានតែ ៖

- ចៅសង្កាត់
- ចៅសង្កាត់រងទីមួយ និងទីពីរ
- ក្រុមប្រឹក្សា
- និងស្មៀន

ផ្ទុយទៅវិញមេភូមិ មេឃុំ និងមន្ត្រីសង្កាត់ផ្សេងៗមិនបានចូលរួមនោះទេ ដោយឡែកមានតែអង្គការមិនមែនរដ្ឋាភិបាលទេ ដែលមានអញ្ជើញមេភូមិ និងមេឃុំឲ្យចូលរួម ។ ហេតុដូច្នេះហើយទើបយើងអាចវិភាគបានថា ការយល់ដឹងនូវគោលការណ៍ នៃអភិបាលកិច្ចល្អនៅថ្នាក់មូលដ្ឋាននេះពិតជានៅមានកម្រិតនៅឡើយ ។ លើសពីនេះទៅទៀតបើយើងក្រឡេកមើលទៅលើមូលដ្ឋាន គតិយុត្តិក្នុងការពង្រឹងអភិបាលកិច្ចល្អ គឺដោយយោងតាមការសាកសួរផ្ទាល់ពីមន្ត្រីសង្កាត់ មានការផ្អែកទៅលើសៀវភៅណែនាំរបស់សាលារាជធានី និង សេចក្តីណែនាំផ្សេងៗដូចជា សេចក្តីណែនាំរបស់សាលារាជធានីក្នុងការបង្កើតជាវេទិការសាធារណៈយ៉ាងតិច ១ដងក្នុង១ខែ និងសេចក្តីណែនាំស្តីពីការប្រមូលទុនចូលរួមរបស់មូលដ្ឋាននៃ គម្រោងអភិវឌ្ឍន៍មូលដ្ឋាន មិនមានការធ្វើសេចក្តីសម្រេចណាមួយ ដែលផ្អែកលើគោលការណ៍ ទំនៀមទំលាប់នោះទេ គឺយកច្បាប់ជាធំ ។

សរុបសេចក្តីមកចំពោះបញ្ហាប្រឈម ក្នុងការអនុវត្តន៍ក្នុងសាលាខណ្ឌមានជ័យគឺ មានភាពលំបាកមួយចំនួនទាក់ទងទៅ និងការអនុវត្តន៍គោលការណ៍អភិបាលកិច្ចគឺ ៖

- សមត្ថភាពរបស់មន្ត្រីនៅមានកម្រិត ពីព្រោះទាក់ទង និងការបណ្តុះបណ្តាល និងកម្រិតវប្បធម៌ ម៉្យាងវិញទៀតការបណ្តុះបណ្តាលចំពោះមន្ត្រី ក៏មិនមានភាពប្រសើរឡើយ គឺមន្ត្រីមិនបានទទួលការបណ្តុះបណ្តាញដល់គ្រប់មន្ត្រី ក្នុងស្ថាប័ននោះទេ
- ការយកចិត្តទុកដាក់របស់មន្ត្រី ក្នុងការងារនៅមានកម្រិត និងខ្វះឆន្ទៈក្នុងការងារពីព្រោះវាមានភាពទាក់ទងទៅយនិងកម្រិតជីវភាពរបស់មន្ត្រី ដោយមន្ត្រីមួយចំនួនដោយសារតែមានកង្វះខាតក្នុងជីវភាព ។ ម៉្យាងវិញទៀតចំពោះជំនួយការស្មៀន និងមន្ត្រីសង្កាត់មួយចំនួនមិនមានប្រាក់បៀវត្តន៍នោះទេ ហេតុដូច្នេះហើយការយកចិត្តទុកដាក់ក្នុង ការងាររដ្ឋបាលមានភាពខ្វះចន្លោះ និងគ្មានឆន្ទៈក្នុងការអនុវត្តន៍សេចក្តីសម្រេចផ្សេងៗ។
- ការចូលរួមរបស់ ប្រជាពលរដ្ឋក៏មិនមានភាពសហការបានគ្រប់នូវកម្មវិធីមូលដ្ឋាននោះដែរ គឺមានការចូលរួម ភាគច្រើនចំពោះតែ កម្មវិធីវេទិការសាធារណៈតែប៉ុណ្ណោះ ។ វាក៏

បានសបញ្ជាក់ពីបញ្ហាការយល់ដឹងរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន ទាក់ទងទៅ និងការចូលរួម និងភាពជាម្ចាស់នៃមូលដ្ឋាន។

- សេវាសាធារណៈ ក្នុងមូលដ្ឋានក៏បានបង្ហាញពី បញ្ហាអវិជ្ជមានមួយចំនួនផងដែរ ទាក់ទង និងសេវាមធ្យោបាយ ពេលវេលា និងការរើសអើង ។

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានធ្វើការសិក្សាទៅលើអភិបាលកិច្ចល្អនៅក្នុងថ្នាក់មូលដ្ឋានរួចមក យើងសង្កេតឃើញថាអភិបាលកិច្ចគឺជា វិធីសាស្ត្រក្នុងការគ្រប់គ្រង និងដឹកនាំយ៉ាងល្អបំផុត។ ក្នុងនោះដែរ យើងទាមទារឲ្យតួអង្គនៃ អភិបាលកិច្ចនោះព្យាយាមខិតខំពង្រឹង និងជម្រុញនូវគោលការណ៍អភិបាលកិច្ចល្អនេះឲ្យសមស្របទៅ និងគោលនយោបាយរបស់រាជរដ្ឋាភិបាល ដែលបានចាត់ទុកអភិបាលកិច្ចល្អជាយុទ្ធសាស្ត្រស្នូលនៃយុទ្ធសាស្ត្រចតុកោណ ក្នុងកំណែទម្រង់រដ្ឋបាលស៊ីជម្រៅ និងជាយុទ្ធសាស្ត្រក្នុងការកាត់បន្ថយភាពក្រីក្រ ។ ហើយក្នុងការអនុវតន៍នូវទ្រឹស្តីអភិបាលកិច្ចល្អនេះ ឲ្យមានប្រសិទ្ធភាពក៏ទាមទារ ពីការខិតខំប្រឹងប្រែងនៃ មន្ត្រីមួយចំនួនផងដែរដូចជាការលើកកម្ពស់នូវការដឹកនាំប្រកបដោយ តម្លាភាព ការឆ្លើយតប ការទទួលខុសត្រូវ គណនេយ្យភាពការចាត់ចែងល្អ ប្រសិទ្ធភាពខ្ពស់ ការព្រមព្រៀង ការឯកភាពគ្នា និងគិតគូរជាពិសេសនូវសេវាសាធារណៈជូនទៅប្រជាពលរដ្ឋគ្រប់រូបនៅក្នុងមូលដ្ឋាន ក៏ដូចជាសាធារណៈជនផ្សេងៗដែលពាក់ពន្ធ័។

ឆ្លងកាត់តាមការអនុវត្តន៍ក្នុងរយៈពេល១ អាណត្តិកន្លងមកនេះទោះបីជាសាលាខណ្ឌសម្រេចបានសមិទ្ធផលជាច្រើនក្តី ប៉ុន្តែយើងអាចវាយតម្លៃបានថា អភិបាលកិច្ចមូលដ្ឋានតាមបែបវិមជ្ឈការមានលក្ខណៈស្មុគស្មាញដែលទាមទារឲ្យមានការរៀបចំ និងការកែសម្រួលជាច្រើន និងត្រូវការពេលវេលាក្នុងការសម្រេចបាននូវទិសដៅដែលបានដាក់ចេញ។ នេះមានន័យថាដើម្បីធានាឲ្យក្រុមប្រឹក្សាឃុំ សង្កាត់នាអាណត្តិទី១នេះ អាចបំពេញកិច្ចតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ គណៈកម្មាធិការជាតិគាំទ្រ ឃុំ សង្កាត់ ក្រសួងមហាផ្ទៃ និងក្រសួង ស្ថាប័នពាក់ព័ន្ធនានាដោយមានការគាំទ្រពីដៃគូអភិវឌ្ឍន៍ជាតិ និងអន្តរជាតិផងនោះ បានចូលរួមយ៉ាងសកម្មនៅក្នុងការរៀបចំសេចក្តីណែនាំគោលនយោបាយ លិខិតបទដ្ឋានគិតយុត្តចាំបាច់នានា និងរៀបចំការបណ្តុះបណ្តាលជាច្រើន ដើម្បីគាំទ្រដល់ក្រុមប្រឹក្សាឃុំ សង្កាត់ ចាប់តាំងពីពេលដែលទើបបានជាប់ឆ្នោត ក្នុងគោលដៅឲ្យក្រុមប្រឹក្សាឃុំ សង្កាត់ទាំង១.៦២១ មានលទ្ធភាពអនុវត្តតួនាទី និងមុខងាររបស់ខ្លួនបានជាជំហានៗ។ ដូច្នេះនៅក្នុងការអនុវត្តន៍កំណែទម្រង់វិមជ្ឈការ នៅក្នុងអាណត្តិទីមួយរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ នៅកម្ពុជា រាជរដ្ឋាភិបាលបាន សម្រេចនូវសមិទ្ធផលជាវិជ្ជមានជាច្រើន។ តាមរយៈសមិទ្ធផលជាវិជ្ជមាននេះ និងដោយពិនិត្យឃើញនូវភាពចាំបាច់នៃកំណែទម្រង់ ដែលជាកត្តាស្លាប់រស់របស់កម្ពុជា ជាពិសេសកំណែទម្រង់រដ្ឋបាលសាធារណៈ ក្នុងគោលដៅធ្វើឲ្យសេវាសាធារណៈកាន់តែមានភាពសាមញ្ញងាយស្រួលតាមរយៈការបង្វិតរដ្ឋបាលសាធារណៈបច្ចុប្បន្ន កាន់តែជិតទៅរកប្រជាពលរដ្ឋតាមរយៈការបង្កើតនូវការិយាល័យច្រកចេញចូលតែមួយ។

រាជរដ្ឋាភិបាល បានយកចិត្តទុកដាក់បន្តពង្រឹង និងពង្រីកការអនុវត្តន៍គោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការឲ្យកាន់តែជ្រាលជ្រៅឡើង ដោយពិចារណាយ៉ាងល្អិតល្អន់លើការផ្ទេរអំណាចពីថ្នាក់លើមកថ្នាក់ក្រោមឲ្យបានឆាប់រហ័ស ហើយកំនត់ឲ្យបានកាន់តែច្បាស់លាស់នូវតួនាទី សិទ្ធិអំណាច និងការទទួលខុសត្រូវរបស់អាជ្ញាធរខេត្តក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ។ ឈរលើទស្សនទាននេះ រាជរដ្ឋាភិបាលបានដាក់ចេញនូវ ក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីកំណែទម្រង់វិមជ្ឈការ វិសហមជ្ឈការ កាលពីថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៥ កន្លងទៅ ដែលជាឯកសារគោលនយោបាយកំណត់អំពីចក្ខុវិស័យ និងគោលការណ៍ជាមូលដ្ឋានសម្រាប់ដឹកនាំដំណើរការកំណែទម្រង់ អភិបាលកិច្ចល្អនៅថ្នាក់ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំសង្កាត់ ។

ជាក់ស្តែងសាលាខណ្ឌមានជ័យ បានចូលរួមយ៉ាងសកម្មក្នុងការផ្តល់សេវាជូនប្រជាពលរដ្ឋប្រកបដោយតម្លាភាព ពង្រឹងសមត្ថភាពមន្ត្រី កាត់បន្ថយភាពក្រីក្រ និងធានានូវលក្ខខណ្ឌជីវភាពរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋានឲ្យមានភាពល្អប្រសើរឡើង។សាលាខណ្ឌមានជ័យ បានអនុវត្តន៍នូវផែនការ សកម្មភាពរបស់ខ្លួនរហូតដល់លេចចេញនូវសមិទ្ធផលជាច្រើន តាមរយៈការគោរពនូវនីតិរដ្ឋដើម្បីធានានូវភាពស្អាតស្អំនៃការធ្វើសេចក្តីសម្រេចផ្សេងៗ។

បើឆ្លងតាមការមើលពីសមិទ្ធផលនៅក្នុងសាលាខណ្ឌដែលបានធ្វើកន្លងមកនោះ គឺយើងអាចសរុបបានថា ការពង្រឹងអភិបាលកិច្ចក្នុងសាលាខណ្ឌមានជ័យពិតជាមាន តាមរយៈការខិតខំប្រឹងប្រែងរបស់មន្ត្រី និងការចូលរួមរបស់ប្រជាពលរដ្ឋ ។ តាមរយៈការពង្រឹងនូវគោលការណ៍អភិបាលកិច្ចល្អក្នុងខណ្ឌមានជ័យ គឺមានការសហការពីប្រជាពលរដ្ឋចូលរួម និង មានការពេញចិត្តនូវគោល-នយោបាយ និងគោលការណ៍អភិបាលកិច្ចល្អ មានភាគច្រើនដូចជា វេទិកាសាធារណៈ គឺប្រជា-ពលរដ្ឋភាគច្រើនគឺប្រជាពលរដ្ឋមានការហ៊ានបញ្ចេញនូវមតិផ្ទាល់ខ្លួនច្រើន និង ក្នុងការប្រជុំអនុម័តគំរោងអភិវឌ្ឍន៍មូលដ្ឋាន ក៏មានការចូលរួមជាច្រើនដែរ នេះសបញ្ជាក់ពីការយល់ដឹងរបស់ប្រជា-ពលរដ្ឋក្នុងមូលដ្ឋានស្តីពីកាតាព្វកិច្ចរបស់ខ្លួនក្នុងការចូលរួមជាមួយសង្គម និងអត្ថប្រយោជន៍នៃការចូលរួមនោះ។ ប៉ុន្តែទោះជាយ៉ាងណាកង្វះខាត គឺចំណុចខ្សោយគឺពិតជាមានបន្តិចបន្តួចមិនមានភាពល្អឥតខ្ចោះឡើយ។ ទាក់ទងទៅ នឹងការផ្តល់ជូននូវសេវាសាធារណៈ ការចូលរួមរបស់ប្រជាពលរដ្ឋ និងសមត្ថភាពមន្ត្រី។ ហេតុដូចនេះនៅក្នុងការពង្រឹង និងជម្រុញ គឺទាមទាឲ្យមានតួអង្គនៃអភិបាលកិច្ចចូលរួមជាមួយគ្នាដោយមិនអាចខ្វះតួអង្គណាម្នាក់បានឡើយ។

# អនុសាសន៍

ដោយផ្អែកទៅលើសេចក្តីសន្និដ្ឋានដូចបានរៀបរាប់ខាងលើ យើងខ្ញុំសូមផ្តល់ជាសាសន៍មួយចំនួនដើម្បី ជាយោបល់មួយក្នុងការជួយពង្រឹងនូវគោលការណ៍អភិបាលកិច្ចល្អក្នុងមូលដ្ឋាន៖

- គួរតែមានការពង្រឹងនូវធនធានមនុស្ស និងសមត្ថភាពមន្ត្រីក្នុងមូលដ្ឋានឃុំ សង្កាត់ ជាពិសេសគឺក្រុមប្រឹក្សា ឃុំ សង្កាត់ទាក់ទងនិងអភិបាលកិច្ចបែបវិមជ្ឈការ
- គួរតែបង្កើតនូវកម្មវិធី និងឱកាសដល់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន ជាពិសេសជនដែលងាយរងគ្រោះ ជនក្រីក្រ និងស្ត្រី ទាក់ទងនិងការចូលរួមក្នុងកិច្ចការសង្គម
- គួរតែបន្តជម្រុញឲ្យប្រជាពលរដ្ឋក្នុងមូលដ្ឋានបានដឹងពីសិទ្ធិ ក្នុងការចូលរួមក្នុងមូលដ្ឋាននៅក្នុងភាពជាម្ចាស់នៃមូលដ្ឋាន
- គួរមានការយកចិត្តទុកដាក់ទៅលើមន្ត្រី តំឡើងប្រាក់បៀវត្សន៍ និងលើកទឹកចិត្ត
- គួរមានការពិនិត្យតាមដានដល់បុគ្គលិក និង ការិយាល័យទាំងអស់នូវសេចក្តីសម្រេចដែលបានដាក់ចេញ ដើម្បីធានាបានថារាល់ការងារដែលបានដាក់ឲ្យចេញកន្លងមក គឺមានការអនុវត្តន៍ប្រកបដោយប្រសិទ្ធភាពខ្ពស់ និងការទទួលខុសត្រូវ
- គួរតែបន្តការកសាងនូវ លិខិតបទដ្ឋាននានា ក្នុងការជួយជម្រុញនូវគោលការណ៍អភិបាលកិច្ចល្អបែបវិមជ្ឈការ។

# ឯកសារពិគ្រោះ

## ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- ប្រកាសអន្តរក្រសួងស្តីពីការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាល
- ព្រះរាជក្រឹត្យលេខ នស/រកត/០៩១០/៧៦៣
- អនុក្រឹត្យលេខ ៥៧៩ អនក្រ.បក ស្តីពីការបង្កើតខណ្ឌច្បារអំពៅ នៃរាជធានីភ្នំពេញ
- យុទ្ធសាស្ត្រចតុកោណរបស់ រាជរដ្ឋាភិបាលកម្ពុជានីតិកាលទី៥ នៃរដ្ឋសភា ដំណាក់-កាលទី៣
- កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី ៥ នៃរដ្ឋសភា

## របាយការណ៍ប្រចាំឆ្នាំ

- របាយការណ៍របស់ក្រុមប្រឹក្សាខណ្ឌមានជ័យអាណត្តិទីមួយ (២០០៩ -២០១៣)
- លក្ខន្តិកៈសហគមន៍លើកកម្ពស់សុខុមាលភាព ប្រជាជនខណ្ឌមានជ័យ

## សៀវភៅតែងនិពន្ធ

- ឯកសារបណ្តុះបណ្តាលវិមជ្ឈការអភិបាលកិច្ចល្អ
- សៀវភៅសមត្ថ និងរបៀបរបបការងារនៅរដ្ឋបាលថ្នាក់ក្រោមជាតិ អនុបណ្ឌិត ហៀង សាង និង អនុបណ្ឌិត ប៉េង ឆុង
- សៀវភៅអភិបាលកិច្ចល្អរបស់អគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ខែធ្នូ ឆ្នាំ ២០០៨
- សៀវភៅអភិបាលកិច្ចល្អរបស់ក្រសួងមហាផ្ទៃ ២០១០

## គេហទំព័រ

- http://kdevevelop.wordpress.com